# សង្គ្រាការណ៍

ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



## រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង ការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ

ខែមេសា ឆ្នាំ២០១២

### មាតិកា

ការអានកថាខណ្ឌនានានៃដីកាដំណោះស្រាយ ១
ការសួរដេញដោលលើឯកសារ... ១៤
នួន ជា ស្នើសុំអង្គជំនុំជម្រះចូលរួម... ៣៣
ការស្នើសុំរបស់សហព្រះរាជអាជ្ញា... ៣៦
សំណើរបស់ អៀង សារី... ៣៩

ក្រុមសង្គ្រាការណ៍ :
ឆាយ ឈុនលី, ឌី សុជាតា,
លឹម ជ័យវ័ត្ត និង ចាន ប្រាថ្នា

*ទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច ឡើងធ្វើជាសាក្សីនៅក្នុង សំណុំរឿង០០២ (រូបថត : អ.វ.ត.ក)*



អៀង សារី ក្នុងបន្ទប់សវនាការ ឆ្នាំ២០១២ (រូបថត៖ អ.វ.ត.ក)

# សវនាការលើសំណុំរឿង០០២ ៖ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ

## ថ្ងៃទី១២-១៥ ខែមីនា ឆ្នាំ២០១២

*ឆាយ ឈុនលី, ឌី សុជាតា, ចាន់ ប្រាថ្នា និង លីម ជ័យទត្ត*

## សេចក្តីផ្តើម

ថ្ងៃទី១២-១៥ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការលើសំណុំរឿង០០២ ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការទាំងបួនថ្ងៃបានចាប់ផ្តើមដោយការអានកថាខណ្ឌនានានៃដីកាដំណោះស្រាយដោយក្រឡាបញ្ជី ចំនួនបីរូប ដែលកថាខណ្ឌទាំងនោះមានជាប់ពាក់ព័ន្ធនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង ការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទទាំងបីរូប រួមមាន នួន ជា អៀង សារី និង ខៀវ សំផន ។ បន្តមក អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យភាគីដេញដោលលើឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធចាប់ពីឧបសម្ព័ន្ធ A6 រហូតដល់ឧបសម្ព័ន្ធ A20 (លើកលែងតែឧបសម្ព័ន្ធA12 និង A13 ដោយសារកំពុងស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះ) ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញា ។ បន្ទាប់មក អង្គជំនុំជម្រះបានលើកយកសំណើរបស់ជនជាប់ចោទ នួន ជា សុំចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ ឌុច មកធ្វើការដេញដោល ។ ចុងក្រោយ គឺសវនាការស្តីពីសំណើសុំរបស់សហព្រះរាជអាជ្ញាដើម្បីស្តាប់សក្ខីកម្មពីចម្ងាយរបស់អ្នកជំនាញគឺសាស្ត្រាចារ្យ ប៊ែន ឃៀរនិន *(Ben Kiernan)* តាមរយៈប្រព័ន្ធសោតទស្សន៍ និងសំណើរបស់ អៀង សារី សុំឲ្យសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ផ្តល់ឯកសារបន្ថែមមុនពេលចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ គួរកត់សម្គាល់ថា នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលចេញនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ គឺមានរបៀបវារៈដែលគ្រោងនឹងធ្វើសវនាការស្តីពីបញ្ហាទាំងឡាយខាងលើរហូតដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ប៉ុន្តែដោយសារតែដំណើរការសវនាការប្រព្រឹត្តទៅលឿនជាងការគ្រោងទុកទើបកិច្ចដំណើរការនីតិវិធីបញ្ចប់នៅត្រឹមថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ។

## I. ការអានកថាខណ្ឌនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ ប្រធានអង្គជំនុំជម្រះសាលាដំបូងគឺលោកចៅក្រម និល ណុន បានបង្គាប់ឲ្យក្រឡាបញ្ជីចំនួនបីរូប អានអង្គហេតុផ្សេងៗពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២[១] តាមលំដាប់លំដោយ រួមទាំងស្តាប់ការជំទាស់ ឬការដាក់សំណើរបស់ក្រុមមេធាវីការពារក្តីចំពោះអង្គហេតុនីមួយៗដែលក្រឡាបញ្ជីបានអានជូន ។

### ១) រចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ

ចាប់ផ្តើមដំបូង ក្រឡាបញ្ជីបានអានដីកាដំណោះស្រាយទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់

[១] ដីការដំណោះស្រាយនៅក្នុងសំណុំរឿង០០២ អាចរកមើលបាននៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរយៈអាសយដ្ឋាន *http://www.eccc.gov.kh/en/articles/public-version-case-002-closing-order* ។

ពីកថាខណ្ឌ៣៣ រហូតដល់កថាខណ្ឌ៧១ ដែលនៅក្នុងនោះមាននិយាយអំពីរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មជ្ឈិម និងថ្នាក់មូលដ្ឋាន ។

### ក) រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មជ្ឈិម

#### ក.១) បក្សកុម្មុយនីស្តកម្ពុជា

បក្សកុម្មុយនីស្តកម្ពុជាត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈដែលដំបូងឡើយត្រូវបានអនុម័តក្នុងសមាជលើកទី១របស់បក្សនៅខែកញ្ញា ឆ្នាំ១៩៦០ ហើយលក្ខន្តិកៈថ្មីត្រូវបានអនុម័តដោយសមាជបក្សលើកទី៤ ក្នុងខែមករា ឆ្នាំ១៩៧៦ ។ នៅក្នុងលក្ខន្តិកៈថ្មីនេះបានរៀបរាប់អំពីមនោគមន៍វិជ្ជា លក្ខខណ្ឌនៃការចូលជាសមាជិក រចនាសម្ព័ន្ធ និងអង្គការចាត់តាំងនៃបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងចែងអំពីស្ថាប័នរដ្ឋមួយចំនួន ដូចជាកងទ័ពបដិវត្តន៍កម្ពុជា ប្រព័ន្ធគណៈកម្មាធិការថ្នាក់ជាតិ គណៈកម្មាធិការបក្សថ្នាក់ជាតិ គណៈមជ្ឈិមបក្ស រួមទាំងមន្ទីរ និងក្រសួងផ្សេងៗជុំវិញគណៈមជ្ឈិម ។ បក្សត្រូវបានគ្រប់គ្រងដោយគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម ។ នៅក្នុងលក្ខន្តិកៈនោះបានកំណត់ថាបក្សកុម្មុយនីស្តកម្ពុជា ត្រូវដើរតាមប្រព័ន្ធរបបដឹកនាំសមូហភាពដោយផ្អែកលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំមានន័យថាសមាជិកត្រូវធ្វើសេចក្តីសម្រេចរួមជាមួយសមាជិកផ្សេងៗទៀត និងមិនអាចធ្វើសេចក្តីសម្រេចជាលក្ខណៈបុគ្គលបានឡើយ ។ ក្នុងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ មានសមាជិកពេញសិទ្ធិ និងសមាជិកត្រៀម ដែលនៅក្នុងនោះសមាជិកពេញសិទ្ធិ គឺជាអ្នកដែលមានសិទ្ធិសម្រេចពិគ្រោះពិភាក្សា និងរួមមតិសម្រេចក្នុងគ្រប់វិស័យទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ស្ថាប័ននេះ ។ ចំណែកសមាជិកត្រៀមគឺមានឋានៈទាប ហើយមិនមានសិទ្ធិអំណាចក្នុងការសម្រេចកំទេចអ្នកណាម្នាក់បានឡើយ ។

មានស្ថាប័នផ្សេងៗទៀតដែលចំណុះឲ្យបក្ស ដូចជាសភាតំណាងប្រជាជន គណៈប្រធានរដ្ឋ ព្រមទាំងគណៈចាត់តាំងនៃគណៈមជ្ឈិមបក្សដែលត្រូវបានប្រគល់សិទ្ធិក្នុងការតាមដាន និងត្រួតពិនិត្យសមាជិកបក្ស និងចាត់ចែងបញ្ជូលទៅតាមមន្ទីរ និងក្រសួងនានា ។

#### ក.២) គណៈកម្មាធិការមជ្ឈិម

យោងលើលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា គណៈកម្មាធិការមជ្ឈិមមានតួនាទីក្នុងការអនុវត្តតាមមាគ៌ារបស់បក្ស និងលក្ខន្តិកៈរបស់បក្សទាំងមូល ព្រមទាំងណែនាំដល់អង្គការភូមិភាគ តំបន់ និងគ្រប់គ្រងចាត់ចែងកម្មាភិបាល និងបក្ខជនទាំងមូល ។ សមាជិកនៅក្នុងគណៈមជ្ឈិមមានដូចជា ប៉ុល ពត ជាលេខាគណៈ មជ្ឈិម, នួន ជា ជាអនុលេខាគណៈមជ្ឈិម, អៀង សារី, ខៀវ សំផន, កុយ ធួន, តាម៉ុក, ណៃ សារ៉ាន់ ហៅយ៉ា, សៀង, កែ ពក, សៀ វ៉ាស៊ី ហៅឌឿន ។ ឈឹម សំអោក ហៅប៉ង់ ពេលខ្លះត្រូវបានចាត់ទុកថាជាសមាជិកនៃគណៈមជ្ឈិម ហើយពេលខ្លះគ្រាន់តែជាជំនួយការនៃគណៈកម្មាធិការនេះប៉ុណ្ណោះ ។ ចំពោះលេខាភូមិភាគ លេខាតំបន់មួយចំនួន និងកម្មាភិបាលយោធាមួយចំនួនក៏ជាសមាជិកគណៈមជ្ឈិមដែរ ។ ក្នុងគណៈមជ្ឈិម មានគណៈយោធាពិសេសមួយ ឬគណៈយោធាជាន់ខ្ពស់ដែលមាន សមាជិកដើមដូចជា ប៉ុល ពត, នួន ជា, សុន សេន, សោ ភឹម, និងតាម៉ុក ។ ចំណែក វន វេត និង កែ ពក បានក្លាយជាសមាជិកយោធាគណៈមជ្ឈិមនៅពេលក្រោយ ។ ឌុច ធ្លាប់បានអះអាងថា សំ បិត និង សៀង (និងមានឈ្មោះមួយចំនួនទៀតដែលត្រូវបានកោសលុប)[៧] គឺជាជំនួយការដែលទទួលខុសត្រូវផ្នែកយោធា ។ សមាជិកនៅក្នុងគណៈមជ្ឈិមមានលើសពី៣០នាក់ដែលមានតួនាទីដឹកនាំការអនុវត្តឲ្យខ្ជាប់ខ្ជួនតាមគោលនយោបាយរបស់បក្សនៅក្នុងសង្គមគ្រប់ជាន់ថ្នាក់ និងធ្វើការផ្សព្វផ្សាយនយោបាយទៅតាមលំដាប់ឋានានុក្រម ហើយមានការប្រជុំគ្នារៀងរាល់៦ខែម្តង ។

#### ក.៣) គណៈកម្មាធិការអចិន្ត្រៃយ៍

គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាអង្គការមួយដែលមាន

[៧] ការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រើពាក្យថា «កោសលុប» នៅក្នុងដីកាដំណោះស្រាយ គឺជាពាក្យដែលសំដៅលើឈ្មោះរបស់សាក្សីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឬព័ត៌មានមួយចំនួនដែលអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គលដែលនឹងត្រូវទទួលវិធានការការពារ ឬអាចនឹងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។

សមាជិកតិចជាងគណៈកម្មាធិកាមជ្ឈិម ហើយសមាជិកនៅក្នុងអង្គការនេះសុទ្ធតែជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតរបស់បក្សកុម្មុនីស្តកម្ពុជា ។ តាមរយៈការលើកឡើងរបស់ ខៀវ សំផន គណៈកម្មាធិការអចិន្ត្រៃយ៍មានសិទ្ធិសម្រេចរាល់ការងារប្រចាំថ្ងៃ ហើយឧត្តមានុភាពរបស់អង្គការនេះបានបង្ហាញឡើងតាមរយៈការបញ្ជាឲ្យមានការចាប់ខ្លួនសមាជិករបស់គណៈមជ្ឈិម ។ ក្នុងនាមជាលេខាគណៈកម្មាធិការអចិន្ត្រៃយ៍ ប៉ុល ពត គឺជាអ្នកមានសិទ្ធិអំណាចខ្ពស់ ហើយរាល់ការសម្រេចរបស់គណៈអចិន្ត្រៃយ៍ត្រូវបានយកទៅផ្សព្វផ្សាយទៅដល់ថ្នាក់មូលដ្ឋាន ។ ឌុច បានបញ្ជាក់ថា នួន ជា គឺជាមនុស្សទី២ បន្ទាប់ពី ប៉ុល ពត នៅក្នុងឋានានុក្រមគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយបន្ទាប់មកទៀតគឺ តាម៉ុក ។ សមាជិកផ្សេងៗទៀតរបស់គណៈកម្មាធិការនេះ រួមមាន សោ ភឹម, អៀង សារី, វន វេត, រស់ ញឹម និង សុន សេន ។ ប៉ុន្តែ វន វេត និង សុន សេន អាចជាសមាជិកពេញសិទ្ធិឬសមាជិកត្រៀម ។ ទោះបីជា ខៀវ សំផន មិនមែនជាសមាជិកផ្លូវការនៃគណៈអចិន្ត្រៃយ៍ក្នុងពេលកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ខៀវ សំផន ទំនងជាបានចូលរួមចំណែកដល់ការងាររបស់គណៈអចិន្ត្រៃយ៍ដូចដែលមានការរៀបរាប់នៅក្នុងដីកាដំណោះស្រាយដែលមាននិយាយអំពី ខៀវ សំផន[៣] ។

នៅក្នុងអង្គប្រជុំមួយថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិកាអចិន្ត្រៃយ៍បានផ្តល់ភារកិច្ចដល់កម្មាភិបាលជាន់ខ្ពស់របស់បក្សនូវការទទួលខុសត្រូវលើវិស័យផ្សេងៗក្នុងសកម្មភាពរបស់រដ្ឋាភិបាល ដូចជាផ្នែកយោធា សេដ្ឋកិច្ច សន្តិសុខ កិច្ចការបរទេស និងសង្គមកិច្ច ។ នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនោះបានសរសេរថា "ក្នុងការលើកគម្រោងត្រូវសួរយោបល់អចិន្ត្រៃយ៍ដើម្បីសម្រេច និងអនុម័ត" ។ តាមការអះអាងរបស់ ខៀវ សំផន ការប្រជុំរបស់គណៈអចិន្ត្រៃយ៍បានធ្វើឡើងញឹកញាប់ ដែលមានរយៈពេលប្រាំពីរទៅដប់ថ្ងៃ ។ សាក្សីម្នាក់ទៀតបានបញ្ជាក់ថា គណៈអចិន្ត្រៃយ៍នឹងធ្វើការកោះប្រជុំនៅពេលដែលមានកិច្ចការសំខាន់ណាមួយត្រូវពិភាក្សា និងសម្រេច ។

## ក.៤) មន្ទីរ៨៧០

៨៧០ ជាលេខកូដមួយដែលគេសំដៅលើថ្នាក់ខ្ពស់បំផុតរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយនៅក្នុងករណីខ្លះគឺសំដៅលើ ប៉ុល ពត ។ មានអង្គភាពជាច្រើនដែលជាប់ទាក់ទងនឹងលេខកូដ ៨៧០ ប៉ុន្តែនៅក្នុងនោះមានស្ថាប័នពីរដែលជាស្ថាប័នសំខាន់គឺមន្ទីរនយោបាយ៨៧០ និងមន្ទីររដ្ឋបាលស-៧១ ឬក្រសួងស-៧១ ។

មន្ទីរនយោបាយ៨៧០ គឺគ្រប់គ្រងដោយ សឿ វ៉ាសុី ហៅ ឌឿន ។ មន្ទីរនេះមានភារកិច្ចទទួលបន្ទុកផ្នែកនយោបាយ និងមានតួនាទីសំខាន់ក្នុងការធ្វើទំនាក់ទំនងរវាងបុគ្គលនានាដែលមានអំណាចសម្រេចរបស់មជ្ឈិម ព្រមទាំងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានា ។ កំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍បានបង្ហាញពីការិយាល័យ៨៧០ ដែលដឹកនាំដោយ ស៊ឹម សុន ហៅ យ៉ែម ដែលនៅក្នុងនោះ យ៉ែម គឺជាអ្នកធ្វើកំណត់ហេតុនៃកិច្ចប្រជុំនានារបស់គណៈអចិន្ត្រៃយ៍និងគណៈមជ្ឈិម ។ មន្ទីរស-៧១ ដឹកនាំដោយ ឈឹម សំអោក ហៅ ប៉ាំង ហើយតាមរយៈការអះអាងរបស់សាក្សីមួយរូបបានបញ្ជាក់ថា មន្ទីរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ។ តាមការអះអាងរបស់ ឌុច មុខងាររបស់មន្ទីរស-៧១ គឺការពារមន្ទីរមជ្ឈិម កម្មាភិបាលនៃមន្ទីរមជ្ឈិម និងទទួលបន្ទុកខាងទទួលភ្ញៀវ ទូរគមនាគមន៍ ភស្តុភារ ស្បៀងនិងការដឹកជញ្ជូន ។ តួនាទីមួយទៀតរបស់មន្ទីរនេះក្នុងនាមគណៈអចិន្ត្រៃយ៍គឺមានភារកិច្ចតាមដានសមាជិករបស់បក្ស ក្រសួងនានា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ខ្លួនឯង ក្នុងករណីមានការសង្ស័យ ការចាប់ខ្លួនជនក្បត់ និងបញ្ជូនទៅមន្ទីរស-២១ ។

មន្ទីរស-៧១នេះមានមន្ទីរចំណុះមួយចំនួនដែលមានឈ្មោះសម្ងាត់ដោយប្រើព្យញ្ជនៈ "ក" ដូចជា មន្ទីរក-១ មន្ទីរក-៣ មន្ទីរក-៧ និងមន្ទីរក-១៨ ។ មន្ទីរក-១ គឺជាបរិវេណស្នាក់អាស្រ័យ និងធ្វើការរបស់ ប៉ុល ពត ។ ទន្ទឹមនឹងនេះដែរ សាក្សីមួយចំនួនបានអះអាងថា វាគ្រាន់តែជាកន្លែងធ្វើការរបស់ ប៉ុល ពត ប៉ុណ្ណោះ ។ ប៉ុន្តែមានសាក្សីខ្លះទៀតអះអាងថា នៅពេលខ្លះ នួន ជា

---

[២] កថាខណ្ឌ៤៥ នៃដីកាដំណោះស្រាយក្នុងសំណុំរឿង០០២

និង ខៀវ សំផន បានស្នាក់នៅ និងធ្វើការជាមួយ ប៉ុល ពត នៅទីនោះដែរ ។ សាក្សីមួយចំនួនបានអះអាងថា មន្ទីរក-៣ ត្រូវបានគេប្រើប្រាស់ជាកន្លែងធ្វើការរបស់ នួន ជា, ខៀវ សំផន, អៀង សារី, សុន សេន និង វន វេត ហើយពេលខ្លះ ប៉ុល ពត បានទៅប្រជុំនៅទីនោះដែរ ។ មន្ទីរក-៧ គឺជាអង្គភាពនិរសារដែលជាកន្លែងឆ្លងកាត់ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរនានាដែលផ្ញើទៅកាន់គណៈ៨៧០ ឬមន្ទីរ៨៧០ មុននឹងបញ្ជូនទៅឲ្យ ប៉ុល ពត នៅមន្ទីរក-១ក៏ដូចជាទៅឲ្យគណៈ៨៧០ ឬសមាជិកពាក់ព័ន្ធរបស់គណៈ៨៧០ អាស្រ័យលើការទទួលខុសត្រូវតាមផ្នែករបស់ខ្លួន ។ មន្ទីរក-១៨ គឺជាអង្គភាពសារទូរលេខ ដែលមានភារកិច្ចទទួលការទាក់ទងតាមវិទ្យុរួចបញ្ជូនទៅកាន់មន្ទីរក-១ ។ មិនទាន់មានភស្តុតាងបង្ហាញច្បាស់ថា បុគ្គលណាខ្លះដែលជាអ្នកទទួលលិខិតដែលបានផ្ញើរទៅមន្ទីរ៨៧០នោះ ។ តាមការអះអាងរបស់ ឌុច និងសាក្សីមួយចំនួនទៀតបានបញ្ជាក់ថា មន្ទីរ៨៧០គឺសំដៅទៅលើ ប៉ុល ពត, នួន ជា, អៀង សារី, វន វេត, សុន សេន និង ថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតដោយរួមទាំង ខៀវ សំផន ។ តាមរយៈភស្តុតាងផ្សេងៗទៀតបានបន្ថែមថា មានមន្ទីរផ្សេងទៀតដូចជាមន្ទីរក-៦ ដែលគេហៅថាបុរីកីឡា មន្ទីរក-៨ទទួលបន្ទុកដាំដុះបន្លែ មន្ទីរក-១១ ជាមន្ទីរពេទ្យ និងមន្ទីរក-១២ គឺជាអង្គភាពរៀបចំយានជំនិះ និងអ្នកបើកបរសម្រាប់មជ្ឈិមបក្ស ។

ជាសរុបមក ទាំង ឌុច, ខៀវ សំផន និងសាក្សីផ្សេងទៀតបានបញ្ជាក់ថាពាក្យ មន្ទីរ៨៧០, អង្គការ៨៧០ និងគណៈ៨៧០ ឬអង្គការ ត្រូវបានប្រើប្រាស់ដោយមិនមានការបែងចែកដើម្បីសំដៅដល់ស្ថាប័នដឹកនាំនានារបស់មជ្ឈិមបក្សឡើយ ។

### ក.៥) ក្រសួងនានា

តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានធ្វើការកំណត់សមាសភាពរបស់ស្ថាប័នរដ្ឋដើម្បីបង្កើតរដ្ឋាភិបាលផ្លូវការជំនួសឲ្យរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយមានការប្រកាសថា «រដ្ឋាភិបាលត្រូវតែជាអង្គការរបស់បក្សសុទ្ធសាធជារដ្ឋរបស់យើងផ្ទាល់» ។ ឈ្មោះរបស់រដ្ឋមន្ត្រីទាំងអស់ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ ។ ទោះបីជាសមាសភាពអាចត្រូវបានផ្លាស់ប្តូរក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យក៏ដោយ ជាគោលការណ៍រដ្ឋាភិបាលត្រូវរៀបចំឡើងក្នុងបែបផែនដូចតទៅនេះ ៖

- ប៉ុល ពត ជានាយករដ្ឋមន្ត្រីទទួលបន្ទុកទូទៅលើផ្នែកយោធា និងផ្នែកសេដ្ឋកិច្ច
- អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស
- សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ
- វន វេត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច



ការប្រជុំគណៈអចិន្ត្រៃយ៍បក្សនៅស្តាតអូឡាំពិក

- នួន ជា ជាប្រធានសភាតំណាងប្រជាជន
- ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ
- យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងអប់រំ
- តូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណៈការ ដឹកជញ្ជូន និងប្រៃសណីយ៍
- កុយ ធួន ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

- អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច
- (ឈ្មោះកោសលុប) ជារដ្ឋមន្ត្រីទទួលបន្ទុកសុខាភិបាលនិង
- ខៀវ  សំផន ជាប្រធានគណៈប្រធានរដ្ឋដែលធ្លាប់ទទួលបន្ទុកផ្នែកពាណិជ្ជកម្មទាក់ទងនឹងគណនេយ្យ និងការកំណត់តម្លៃ ។

### ខ) រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការកំណត់ទីតាំងត្រូវបានបែងចែកជាផ្នែកតូចៗ ទៅតាមអង្គភាពរដ្ឋបាលដែលមាន



ឋានានុក្រមបន្តគ្នា ហើយទាក់ទងទៅនឹងសន្ទាក់នៃការបញ្ជាតាមរយៈខ្សែបណ្តោយដែលគ្រប់គ្រងដោយគណៈមជ្ឈិម ។ ភូមិភាគធំៗមួយចំនួនគឺស្ថិតនៅក្រោមគណៈមជ្ឈិមដោយផ្ទាល់ ហើយភូមិភាគទាំងនេះត្រូវបានបែងចែកជាតំបន់តំបន់បែងចែកជាស្រុកមួយចំនួន ហើយស្រុកត្រូវបានបែងចែកជាឃុំ និងសហករណ៍ ។ គ្រប់ភូមិភាគ តំបន់ ស្រុក និងឃុំត្រូវបានគ្រប់គ្រងដោយ“គណៈ” ហើយគណៈនីមួយៗត្រូវបានដឹកនាំដោយលេខា ។ ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ភូមិភាគត្រូវបានបែងចែកជា៦ ដូចជាភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគឦសាន ភូមិភាគនិរតី ភូមិភាគបស្ចឹម និងភូមិភាគបូព៌ា ។ នៅឆ្នាំ១៩៧៧ ភូមិភាគឧត្តរត្រូវបានដាក់ឈ្មោះសាជាថ្មីថាជាភូមិភាគកណ្តាល និងបានបង្កើតឲ្យមានភូមិភាគឧត្តរថ្មីមួយទៀត ។ ក្រៅពីបែងចែកភូមិភាគទាំងនេះ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតតំបន់ស្វយ័តដែលអាចរាយការណ៍ផ្ទាល់ទៅថ្នាក់មជ្ឈិមដោយមិនចាំបាច់ឆ្លងកាត់ការអនុញ្ញាតពីថ្នាក់ភូមិភាគឡើយ ។ តំបន់ស្វយ័តទាំងអស់នោះរួមមានតំបន់ស្វយ័ត១០៣(ខេត្តព្រះវិហារ) តំបន់ស្វយ័ត១០៥ (ខេត្តមណ្ឌលគិរី) តំបន់ស្វយ័ត១០៦(ខេត្តសៀមរាប) តំបន់ស្វយ័ត៥០៥(ខេត្តក្រចេះ) និងតំបន់ស្វយ័តទីក្រុងកំពង់សោម ។ ទីក្រុងភ្នំពេញត្រូវបានចាត់ថ្នាក់ជាទឹកដីផ្សេងពីគេដោយសារវាមិនស្ថិតនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានជាផ្លូវការ ហើយត្រូវរាយការណ៍ផ្ទាល់ទៅថ្នាក់មជ្ឈិម ។

ចំពោះលេខាភូមិភាគ គឺត្រូវបានតែងតាំងដោយគណៈមជ្ឈិម ។ លេខាភូមិភាគ និងលេខាតំបន់ស្វយ័តជាអ្នកអនុវត្តតាមការសម្រេចរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ។ ចំពោះគោលនយោបាយ និងសេចក្តីណែនាំរបស់គណៈមជ្ឈិមត្រូវបានផ្សព្វផ្សាយទៅដល់គ្រប់លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត ដើម្បីធ្វើការផ្សព្វផ្សាយបន្តទៅដល់ថ្នាក់តំបន់ និងស្រុក ។ ចំណែកការរាយការណ៍ទាំងឡាយត្រូវធ្វើចាប់ពីថ្នាក់ឃុំ ឡើងរហូតដល់គណៈភូមិភាគ ។ ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់បក្សកម្មុយនីស្តកម្ពុជា រាល់ភារកិច្ចនិងមុខងាររបស់គណៈភូមិភាគ គឺដឹកនាំអនុវត្តភារកិច្ចដោយយោងតាមគោលការរបស់បក្ស គឺការចុះទៅជាប់ជាមួយថ្នាក់តំបន់ ស្រុក និងឃុំ ។ ក្នុងការអនុវត្តការងារទាំងនេះ គណៈភូមិភាគត្រូវបានផ្តល់អំណាចឲ្យកំណត់ការងារថ្មីៗតាមមាគ៌ានយោបាយរបស់បក្ស មានន័យថាភូមិភាគទាំងឡាយត្រូវទទួលខុសត្រូវចំពោះស្ថានភាពសន្តិសុខផ្ទៃក្នុងដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន ។ សិទ្ធិអំណាចមួយទៀតរបស់គណៈភូមិភាគ គឺការជ្រើសរើសសមាជិកថ្មីសម្រាប់ការដឹកនាំថ្នាក់ភូមិភាគដោយមានការយល់ព្រមពីគណៈមជ្ឈិម ។ ក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាកំណត់ថា គណៈតំបន់ គណៈស្រុក និងគណៈឃុំ គឺតម្រូវឲ្យអនុវត្តសេចក្តីណែនាំដែលបក្សបានដាក់ និងធ្វើសេចក្តីរាយការណ៍ត្រឡប់

ទៅរដ្ឋបាលថ្នាក់លើវិញ ។ ក្រៅពីនោះ លេខាភូមិភាគតែងតែចូលរួមប្រជុំប្រចាំឆ្នាំជាមួយគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើឡើងនៅទីក្រុងភ្នំពេញ ហើយពេលខ្លះថ្នាក់មជ្ឈិមបានប្រជុំជាមួយសមាជិកភូមិភាគ តំបន់ និងស្រុក ហើយគណៈតំបន់នានានឹងត្រូវរៀបចំកិច្ចប្រជុំជាមួយលេខាស្រុក និងឃុំដើម្បីផ្សព្វផ្សាយសេចក្តីណែនាំនោះបន្តទៀតដល់អង្គភាពរបស់ខ្លួន ។

## ២) ប្រព័ន្ធទំនាក់ទំនងការងារ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា គឺជាក្បាលម៉ាស៊ីននៃប្រព័ន្ធទំនាក់ទំនងការងាររបស់បក្សទូទាំងប្រទេស និងជាចំណុចប្រមូលផ្តុំប្រព័ន្ធព័ត៌មានជាប់លាប់រវាងផ្នែកនីមួយៗនៃឋានានុក្រមរដ្ឋបាល ។ ទាក់ទងនឹងចំណុចនេះ ក្រឡាបញ្ជីបានបន្តការអានដីកាដំណោះស្រាយចាប់ពីកថាខណ្ឌ៧២ រហូតដល់កថាខណ្ឌ១១២ ដែលនៅក្នុងនោះមានរៀបរាប់អំពីបណ្តាញទំនាក់ទំនងនិងមធ្យោបាយនៃការធ្វើទំនាក់ទំនង ។

### ក) បណ្តាញទំនាក់ទំនងការងារ

បណ្តាញទំនាក់ទំនងការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានរៀបចំយ៉ាងម៉ត់ចត់នៅថ្នាក់មជ្ឈិម (រវាងក្រសួងនានានិងមន្ទីរនានាដែលនៅជុំវិញមជ្ឈិមក្នុងចំណោមកងទ័ពរបស់មជ្ឈិម និងនៅក្នុងមន្ទីរសន្តិសុខរបស់មជ្ឈិម) រវាងមជ្ឈិមនិងភូមិភាគ ភូមិភាគទៅតំបន់ និងស្រុកទំនាក់ទំនងក្រៅប្រទេស និងតាមរយៈកិច្ចប្រជុំនៅមជ្ឈិមដើម្បីសិក្សារៀនសូត្រ ។

### *ក.១) បណ្តាញទំនាក់ទំនងរវាងមជ្ឈិម និងភូមិភាគ*

ភូមិភាគ និងតំបន់ស្វយ័តបានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍អំពីស្ថានភាពកសិកម្មដូចជាការធ្វើស្រែ ប្រព័ន្ធធារាសាស្ត្រ ជីវភាពប្រជាជន ស្ថានភាពរបស់ខ្មាំង និងស្ថានភាពយោធា ។ មានសារទូរលេខមួយចំនួនបានរាយការណ៍ពីការរត់ចោលជួរនិងការមិនគោរពវិន័យរបស់កងទ័ព ជម្លោះជាមួយវៀតណាម (ដោយមានការបញ្ជាក់ពីចំនួនខ្មាំងដែលត្រូវបានសម្លាប់ និងសម្ភារៈដែលរឹបអូសបាន) អំពីស្ថានភាព និងការសួរចម្លើយគិញវៀតណាម (ដោយបានបញ្ជាក់ពីការប្រើប្រាស់ទារុណកម្ម) អំពីបញ្ហាសន្តិសុខផ្ទៃក្នុង (ដោយបានបញ្ជាក់ពីបុគ្គលដែលត្រូវបានសង្ស័យ ឬជនក្បត់) និងបានរាយការណ៍ប្រាប់មន្ទីរ៨៧០ អំពីផែនការណ៍ប្រយុទ្ធនិងចលនារបស់ខ្មាំងជាដើម ។ លេខាភូមិភាគម្នាក់ៗត្រូវមានតារាងពេលវេលាសម្រាប់ទំនាក់ទំនងការងារដែលកំណត់ដោយមជ្ឈិម ដែលតារាងនេះបញ្ជាក់ពីពេលវេលាសម្រាប់ទាក់ទងជាមួយមជ្ឈិម ។ សារទូរលេខជាច្រើនត្រូវបានផ្ញើចេញពីភូមិភាគចំនួនមួយ ឬពីរដងក្នុងមួយថ្ងៃនៅពេលព្រឹក និងពេលល្ងាច ហើយក្នុងកាលៈទេសៈពិសេសសារទូរលេខអាចត្រូវបានផ្ញើនៅម៉ោងណាក៏បាន ។ អ្នកប្រតិបត្តិការសារទូរលេខម្នាក់ក្នុងចំណោមអ្នកប្រតិបត្តិសារទូរលេខជាច្រើននៅភូមិភាគកណ្តាលបានបញ្ជាក់ថា គាត់បានទទួលសារទូរលេខពីមជ្ឈិម(មន្ទីរ៨៧០) ប្រហែលបួនទៅប្រាំសាក្នុងមួយថ្ងៃ ។ ក្នុងកំឡុងឆ្នាំ១៩៧៨ ទំនាក់ទំនងរវាងមជ្ឈិម និងភូមិភាគមានការកើនឡើង ដោយសារមានការរីកចម្រើនផ្នែកបច្ចេកទេស ។ សាក្សីជាច្រើនបានបង្ហាញថា "មានគោលការណ៍ដ៏តឹងរឹងមួយ គឺហាមមិនឲ្យមានទំនាក់ទំនងដោយផ្ទាល់រវាងភូមិភាគ និងភូមិភាគឡើយ ពោលគឺរាល់ទំនាក់ទំនងរវាងភូមិភាគនិងភូមិភាគត្រូវឆ្លងកាត់តាមរយៈមជ្ឈិម..." ។

### *ក.២) បណ្តាញទំនាក់ទំនងរវាងភូមិភាគទៅតំបន់និងស្រុក*

តំបន់នីមួយៗមានអង្គភាពសារទូរលេខផ្ទាល់ខ្លួន ប៉ុន្តែរាល់ការបញ្ជូនសារទូរលេខរបស់តំបន់ត្រូវឆ្លងកាត់តាមរយៈភូមិភាគ ។ មានតែតំបន់ស្វយ័តប៉ុណ្ណោះដែលអាចទាក់ទងដោយផ្ទាល់ជាមួយមជ្ឈិម ។ សាក្សីម្នាក់ដែលធ្វើការជាអ្នកប្រតិបត្តិការសារទូរលេខនៅក្នុងតំបន់ស្វយ័ត១០៥បញ្ជាក់ថា មន្ទីរស្រុកភាគច្រើនបានរាយការណ៍ពីគម្រោងសាងសង់ទំនប់ និងប្រឡាយទឹក សុខភាពរបស់ប្រជាជន ការត្រួតពិនិត្យកងកម្លាំងសមាសភាពល្អនិងមិនល្អ សមាសភាពក្បត់ ឬសន្តិសម្ព័ន្ធជាដើម ។ បន្ទាប់ពីទទួលបានរបាយការណ៍ទាំងនេះ លេខាតំបន់បានរៀបចំនិងផ្ញើរបាយការណ៍ទាំងនេះទៅមជ្ឈិមជាប្រចាំ ។

ក្រៅពីអង្គភាពសារទូរលេខ និរសារជាច្រើនក៏ត្រូវបានប្រើប្រាស់ជាចម្បងនៅក្នុងទំនាក់ទំនងការងារ រវាងតំបន់ និងស្រុកដែរ ។ ដូចបានចង្អុលបង្ហាញដោយប្រភពអាមេរិកកាំង (របាយការណ៍ stony beach) បានបញ្ជាក់ថា "ស្រុកនីមួយៗ និងតំបន់នៅក្នុងភូមិភាគបូព៌ា មានបណ្តាញនិរសារមួយ ។ បណ្តាញនេះធ្វើ

*តាមរបចនាសម្ព័ន្ធដ៏តឹងរ៉ឹងមួយដែលឆ្លុះបញ្ចាំងពីខ្សែសង្វាក់បញ្ជារបស់ភូមិភាគ ។ ឧទាហរណ៍ ទោះបីមានអង្គភាពនិរសារថ្នាក់ស្រុកដែលមានទីតាំងនៅជិតអង្គភាពភូមិភាគក៏ដោយ ក៏អង្គភាពថ្នាក់ស្រុកដំបូងត្រូវផ្ញើសារទៅបញ្ជាការកណ្ដាលរបស់ពួកគេ រួចទើបផ្ញើទៅមន្ទីរនិរសារភូមិភាគ ។ បន្ទាប់មកសារបានចូលដល់បណ្ដាញភូមិភាគ ។ និរសារបញ្ជូនសារសំខាន់ៗទាក់ទងការងារសន្តិសុខ ការងារបក្ស ការងារយោធា ព្រមទាំងធ្វើទំនាក់ទំនងផ្ទាល់ខ្លួនឲ្យបុគ្គលដែលនៅតាមទីតាំងនីមួយៗ» ។*

### ក.៣) បណ្ដាញទំនាក់ទំនងក្រៅប្រទេស

របបកម្ពុជាប្រជាធិបតេយ្យមានមធ្យោបាយបច្ចេកទេសដើម្បីទំនាក់ទំនងជាមួយប្រទេសក្រៅ ហើយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជូនសារទូរលេខទៅប្រទេសផ្សេងៗទៀតដែលភាគច្រើនគឺជារដ្ឋសង្គមនិយមពេញមួយរបបកម្ពុជាប្រជាធិបតេយ្យដើម្បីផ្ដល់យោបល់ និងអបអរសារទរចំពោះព្រឹត្តការណ៍នានា ឬដើម្បីពន្យល់ថាអ្វីៗប្រព្រឹត្តទៅបានល្អប្រសើរ ។

ព័ត៌មានក្រៅប្រទេស ត្រូវបានបក្សកុម្មុយនីស្តផ្សព្វផ្សាយតាមរយៈស្ថានទូតនៅទីក្រុងប៉េកាំង ហើយក្រសួងឃោសនាការត្រូវបានណែនាំឲ្យផ្ដល់ព័ត៌មានដល់មេដឹកនាំជាន់ខ្ពស់ជាប្រចាំថ្ងៃដោយសង្ខេបអំពីអ្វីដែលកើតមាននៅក្នុងពិភពលោក ។

### ក.៤) ទំនាក់ទំនងការងារតាមរយៈកិច្ចប្រជុំសិក្សារៀនសូត្រនៅគណៈមជ្ឈិម

សាក្សីជាច្រើនបានលើកឡើងថា កម្មាភិបាលមកពីគណៈភូមិភាគ គណៈតំបន់ រួមទាំងកងទ័ពត្រូវបាន នួន ជា, ប៉ុល ពត ឬមន្ទីរ៨៧០ កោះហៅមកចូលរួមកិច្ចប្រជុំសិក្សារៀនសូត្រនៅទីក្រុងភ្នំពេញ ឬនៅមជ្ឈិម ។ មជ្ឈិមត្រូវធ្វើការប្រជុំប្រចាំខែនៅមន្ទីរក-១ដែលការប្រជុំនេះមានការចូលរួមដោយកម្មាភិបាលមកពីគណៈស្រុក គណៈតំបន់ និងគណៈភូមិភាគ ។ ជារឿយៗកិច្ចប្រជុំនេះត្រូវបានដឹកនាំដោយ ប៉ុល ពត និង សុន សេន និងចូលរួមដោយកម្មាភិបាលជាន់ខ្ពស់របស់បក្ស និងមេបញ្ជាការនានាពាក់ព័ន្ធនឹងផ្នែកយោធា ។

## ខ) មធ្យោបាយនៃទំនាក់ទំនងការងារ

តាមរយៈភស្តុតាងមួយចំនួន និងការពិនិត្យរបាយការណ៍ដែលធ្វើឡើងដោយកម្មាភិបាលថ្នាក់ក្រោមទៅថ្នាក់លើ សេចក្ដីណែនាំពីថ្នាក់លើទៅថ្នាក់ក្រោមបង្គាប់ និងការស្នើសុំផ្ដល់ព័ត៌មានផ្សេងៗបានបង្ហាញថា ទំនាក់ទំនងជាចម្បងរវាងមន្ទីរនិងមន្ទីរ ឬរវាងបុគ្គលនិងបុគ្គល ត្រូវបានធ្វើឡើងតាមរយៈសំបុត្រ សារទូរលេខ និងនិរសារ ។ ទំនាក់ទំនងការងារជាផ្លូវការក៏ត្រូវបានធ្វើឡើងតាមរយៈការប្រជុំនានាដែលរៀបចំឡើងនៅតាមថ្នាក់រដ្ឋបាលនីមួយៗ និងតាមរយៈការប្រមូលផ្ដុំប្រជុំគ្នាដ៏ធំនៅទីក្រុងភ្នំពេញ ។ បន្ថែមលើនេះទៅទៀតបក្សកុម្មុយនីស្តកម្ពុជាបានផ្សព្វផ្សាយនូវសេចក្ដីណែនាំផ្សេងៗ និងឯកសារបណ្ដុះបណ្ដាលមនោគមន៍វិជ្ជានយោបាយនៅទូទាំងប្រទេស ។ ឯកសារផ្សព្វផ្សាយបែបនេះត្រូវបានបញ្ជូនពីថ្នាក់មជ្ឈិមទៅកម្មាភិបាលថ្នាក់ក្រោមដែលជាអ្នកផ្សព្វផ្សាយបន្តទៅប្រជាជននៅតាមភូមិភាគ និងតំបន់នានា ។

### ខ.១) មធ្យោបាយទំនាក់ទំនងការងារតាមរយៈសំបុត្រនិងនិរសារ

មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី បានប្រើប្រាស់សំបុត្រមួយចំនួនជាមធ្យោបាយក្នុងការធ្វើទំនាក់ទំនងការងារ ។ សំបុត្រត្រូវបានបញ្ជូនតាមរយៈនិរសារទៅឲ្យលេខាភូមិភាគ និងតំបន់នានា ។ និរសារត្រូវបានប្រើប្រាស់ជាចម្បងដើម្បីនាំ យកសេចក្ដីរាយការណ៍ ឬសារទូរលេខពីអង្គភាពនាំសារទៅកាន់ក្រសួងនានា ឬត្រូវបានប្រើសម្រាប់ទាក់ទងគ្នាពាកក់ព័ន្ធនឹងការចាប់ខ្លួនជនណាម្នាក់

### ខ.២) មធ្យោបាយទំនាក់ទំនងការងារតាមរយៈសារទូរលេខ

គណៈអចិន្ត្រៃយ៍បានសម្រេចអំពីរបៀបដំណើរការនៃអង្គភាពសារទូរលេខនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ។ អង្គភាពនេះត្រូវបានបែងចែកជាពីរផ្នែក គឺមួយផ្នែកទទួលខុសត្រូវក្នុងការបញ្ជូនសារ និងទទួលសារ និងមួយផ្នែកទៀតទទួលខុសត្រូវក្នុងការដាក់លេខសម្ងាត់ និងបកប្រែខ្លឹមសារសារទូរលេខ ។ សាក្សីជាច្រើនបានបញ្ជាក់ថា *«សារទូរលេខដែលផ្ញើចេញពីមជ្ឈិម ជាដំបូងត្រូវផ្ញើមកផ្នែកបកប្រែសារទូរលេខ ដែលមានទីតាំងនៅមន្ទីរមជ្ឈិមបក្សក-១ ដើម្បីបកប្រែទៅជាលេខកូដសម្ងាត់ ។ បន្ទាប់មកសារដែលមានលេខកូដសម្ងាត់នេះត្រូវបានបញ្ជូនទៅក្រុមប្រតិបត្តិការ*

*នៅមន្ទីរក-១៨ ដែលជាអ្នកត្រូវបញ្ជូនសារនោះ ជាលេខកូដសម្ងាត់ទៅអ្នកទទួលដែលជាអ្នកបកប្រែទៅជាខ្លឹមសារអត្ថបទធម្មតា ។ សារទូរលេខដែលផ្ញើចូលពីភូមិភាគនានា ដំបូងត្រូវចូលទៅក-១៨ដើម្បីឲ្យក្រុមអ្នកវាយអត្ថបទបំប្លែងជាលាយលក្ខណ៍អក្សរ ។ បន្ទាប់មកសារជាលេខកូដសម្ងាត់នោះត្រូវបានបញ្ជូនទៅក-១ដើម្បីបកប្រែសារទូរលេខ ហើយត្រូវបញ្ជូនទៅកម្មាភិបាលបក្សដែលជាអ្នកត្រូវទទួល...» ។*

**ខ.៣) មធ្យោបាយទំនាក់ទំនងការងារតាមរយៈការបោះពុម្ពផ្សាយឯកសារនយោបាយ**

ចំពោះមធ្យោបាយក្នុងការអប់រំគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺតាមរយៈការបោះពុម្ពផ្សាយទស្សនាវដ្តីទង់បដិវត្ត ទស្សនាវដ្តីយុវជនយុវនារីបដិវត្ត និងតាមរយៈការចាក់ផ្សាយតាមវិទ្យុ ឬបង្កើតខ្សែភាពយន្ត និងការថតរូបជាដើម ។

ទស្សនាវដ្តីទង់បដិវត្ត ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត គឺជាឧបករណ៍យោនាមួយដែលត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងអំពីនយោបាយរបស់បក្សមួយដងក្នុងមួយខែ ។ មានតែបក្ខជនប៉ុណ្ណោះដែលមានសិទ្ធិទទួលបានទស្សនាវដ្តីទាំងនេះ ហើយទស្សនាវដ្តីនេះត្រូវបានផ្សព្វផ្សាយដើម្បីបង្រៀនដល់កម្មាភិបាលទាំងផ្នែកនយោបាយ និងយោធា ។ បន្ទាប់មកកម្មាភិបាលទាំងនោះត្រូវផ្សព្វផ្សាយគោលនយោបាយបន្តទៅអ្នកនៅក្រោមបង្គាប់ខ្លួន ។ សាក្សីមួយចំនួនបានលើកឡើងថា *«គោលការណ៍ដែលណែនាំនៅក្នុងទស្សនាវដ្តីទាំងនោះត្រូវបានបង្ហាញពីរបៀបធ្វើការដឹមតំបត់ ហើយប្រសិនបើមនុស្សណាម្នាក់មិនសម្របខ្លួនតាមខ្លឹមសារទស្សនាវដ្តីទេនោះ អ្នកនោះនឹងត្រូវចាត់ទុកថាជាខ្មាំងដោយស្វ័យប្រវត្តិ»* ។

បន្ទាប់ពីលោកប្រធានអង្គជំនុំជម្រះបានប្រកាសសម្រាកនៅពេលព្រឹករយៈពេល២០នាទី លោក អាង ឧត្តម មេធាវីការពារក្តី អៀង សារី បានក្រោកឈរដើម្បីស្នើសុំឲ្យកូនក្តីរបស់ខ្លួនចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោទស្សន៍នៅបន្ទប់ខាងក្រោម ដោយសារបញ្ហាសុខភាពមិនអាចឲ្យជនជាប់ចោទរូបនេះចូលរួមសវនាកាដោយផ្ទាល់បាន ។ ប៉ុន្តែសំណើនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះបដិសេធ ដោយលោកបានផ្តល់ហេតុផលថា សវនការនាពេលនេះគឺទាក់ទងនឹងការចោទប្រកាន់ជនជាប់ចោទនៅក្នុងសវនាការដំណាក់កាលទី២ ដូច្នេះវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការគឺជារឿងសំខាន់ ដើម្បីធានាថាជនជាប់ចោទបានស្តាប់អង្គហេតុដែលបានចោទប្រកាន់មកលើខ្លួន ។

បន្ទាប់ពីបញ្ចប់ការអានរបស់ក្រលាបញ្ជីទាក់ទីងប្រព័ន្ធទំនាក់ទំនងការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យក្រឡាបញ្ជីម្នាក់ទៀតឡើងអានដីកាដំណោះស្រាយបន្តទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ៣) តួនាទីរបស់ជនជាប់ចោទនីមួយៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### ក) តួនាទី និងមុខងាររបស់ជនជាប់ចោទ នួន ជា

ទាក់ទងតួនាទីរបស់ជនជាប់ចោទ នួន ជា ក្រឡាបញ្ជីបានចាប់ផ្តើមអានពីកថាខណ្ឌ៨៦៩រហូតដល់កថាខណ្ឌ៨៩២ ដែលនៅក្នុងនោះរួមមានតួនាទីជនជាប់ចោទជាសមាជិកគណៈមជ្ឈិមនិងគណៈអចិន្ត្រៃយ៍ តួនាទីនៅក្នុងផ្នែកសន្តិសុខ និងតួនាទីផ្សេងៗទៀត ។

**ក.១) តួនាទី និងមុខងារជាសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍**

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា គឺជាសមាជិករបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ។ ក្នុងនាមជាសមាជិកគណៈមជ្ឈិម នួន ជា មានតួនាទីជាអនុលេខាមជ្ឈិមបក្ស ចាប់តាំងពីឆ្នាំ១៩៦០ រហូតពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែការប្រកាសជាសាធារណៈពីតួនាទីរបស់ នួន ជា ត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ។ នួន ជា ត្រូវបានគេស្គាល់ថាជាបងធំទីពីរបន្ទាប់ពី ប៉ុល ពត ដែលមានសិទ្ធិពិគ្រោះ និងចូលរួមសម្រេចលើបញ្ហាទាំងអស់ជាមួយ ប៉ុល ពត ។ ឌុច បានអះអាងថា នួន ជា គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តរាល់សេចក្តីសម្រេចដែលធ្វើឡើងដោយ ប៉ុល ពត ។

យោងលើកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍បានបញ្ជាក់ថា រាល់ការប្រជុំម្តងៗតែងតែមានវត្តមានរបស់ នួន ជា ដែលជាអ្នកផ្តល់យោបល់ ធ្វើការណែនាំ និងចេញបទបញ្ជាផ្សេងៗ ។ ក្រៅពីនេះ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំផ្សេងៗទៀតរបស់

បក្សដែលបានធ្វើឡើងជាប្រចាំនៅមន្ទីរក-១និងក-៣ ។ កិច្ចប្រជុំប្រចាំខែត្រូវធ្វើឡើងនៅមន្ទីរក-១ ជាមួយកម្មាភិបាលមួយចំនួនមកពីភូមិភាគ តំបន់ និងស្រុក ។ បន្ថែមលើនេះ នួន ជា មានការប្រជុំជាមួយកម្មាភិបាលមកពីតំបន់ស្វយ័តដែរ ។

**ក.២) តួនាទីនៅក្នុងផ្នែកសន្តិសុខ**

ស្របពេលជាមួយគ្នានេះដែរ ជនជាប់ចោទ នួន ជា មានតួនាទីផ្សេងទៀតពាក់ព័ន្ធនឹងផ្នែកសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាសមាជិកគណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម សមាជិកគណៈចាត់តាំងមជ្ឈិម និងទទួលខុសត្រូវលើការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ ជានាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាប្រធានសភាប្រជាជន និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ។

◆ **តួនាទីជាសមាជិកគណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម**

តាមការបញ្ជាក់របស់ អៀង សារី បានបង្ហាញថា នួន ជា គឺជាសមាជិកនៅក្នុងគណៈកម្មាធិការយោធា ។ ក្រៅពីនេះ វត្តមានរបស់ នួន ជា ត្រូវបានឃើញនៅពេលធ្វើសុន្ទរកថានៅក្នុងឱកាសបុណ្យខួបលើកទី៩នៃកងទ័ពបដិវត្តន៍កម្ពុជាក្នុងនាមគណៈកម្មាធិការយោធារបស់បក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា បានបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានអង្គភាពយោធាដែលមានតួនាទីការពារជាតិ និងបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ។

តាមរយៈការអះអាងរបស់សាក្សីមួយចំនួនបានបង្ហាញថា នួន ជា ទទួលខុសត្រូវលើកិច្ចការសន្តិសុខ ដោយធ្វើការណែនាំជាប្រចាំទាក់ទងនឹងការងារសន្តិសុខ និងធ្វើបទឧទ្ទេសនាមនៅក្នុងវគ្គរៀនសូត្រនយោបាយដល់សមាជិកកងទ័ពបដិវត្តន៍កម្ពុជា ។ លើសពីនេះទៅទៀត ឌុច បានអះអាងថា គ្រប់ការងារទាំងអស់ត្រូវតែឆ្លងកាត់ នួន ជា ដែលរួមទាំងការងារក្នុងវិស័យយោធាផង ។ តាមរយៈសាក្សីម្នាក់ដែលធ្លាប់បំរើការងារជាអ្នកកាន់ទូរស័ព្ទ សុន សេន បានអះអាងថាខ្លួនមិនដែលឃើញមានការធ្វើទំនាក់ទំនងតាម



សារទូរលេខរវាង សុន សេន និង នួន ជា ឡើយ ដោយសារអ្នកទាំងពីរតែងតែជួបគ្នារាល់ថ្ងៃ ។ មុខងារមួយទៀតរបស់ នួន ជា ក្នុងឋានៈជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ គឺទាក់ទងនឹងបញ្ហាសន្តិសុខអន្តរជាតិដូចជាការចូលរួមក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងគោលនយោបាយយុទ្ធសាស្ត្រអំពីបញ្ហាព្រំដែនកម្ពុជា និងស្ថានភាពជម្លោះព្រំដែនជាមួយវៀតណាម ។ ជនជាប់ចោទក៏ធ្លាប់បានចរចាជាមួយអាជ្ញាធរវៀតណាម ព្រមទាំងគាត់តែង "សៀវភៅខ្មៅ" ដែលនិយាយអំពីគោលនយោបាយការបរទេសវៀតណាម ហើយ នួន ជា មានសិទ្ធិអំណាចក្នុងការផ្ញើសេចក្តីណែនាំទាក់ទងនឹងបញ្ហាសន្តិសុខអន្តរជាតិទៅថ្នាក់ក្រោមតាមរយៈសារទូរលេខ និងលិខិតផ្សេងៗ ថែមទៀតផង ។

**◆ មន្ទីរសន្តិសុខស-២១ និងការដ្ឋាន ស-២៤**

យោងលើកិច្ចសម្ភាសន៍ជាច្រើនដែលធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានបដិសេធថា ខ្លួនពិតជាមិនបានដឹងថាមានមន្ទីរសន្តិសុខស-២១ នៅមុនឆ្នាំ១៩៧៩ ឡើយ ប៉ុន្តែមានភស្តុតាងជាច្រើនដែលអាចបញ្ជាក់បានថា នួន ជា ជាអ្នកទទួលបន្ទុកគ្រប់គ្រងលើមន្ទីរសន្តិសុខស-២១ និងការដ្ឋានស-២៤ (ព្រៃស) របស់មន្ទីរស-២១ ។ ឌុច បានអះអាងថា ក្នុងពេលបំពេញការងារនៅមន្ទីរស-២១ ទោះបីជាខ្លួនមិនមានទំនាក់ទំនងផ្ទាល់ជាមួយ នួន ជា ក៏ដោយ ក៏ខ្លួនអាចយល់បានថា នួន ជា ទទួលខុសត្រូវលើមន្ទីរ ស-២១តាមរយៈការធ្វើទំនាក់ទំនងជាមួយ សុន សេន "...សុន សេន មាន នួន ជា ជាថ្នាក់លើ ហើយ នួន ជា នៅក្រោមប៉ុល ពត" ។ ឌុច បន្ថែមថា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ សុន សេន បានចាកចេញពីភ្នំពេញទៅកាន់សមរភូមិមុខក្នុងពេលមានជម្លោះជាមួយវៀតណាម ។ នៅខណៈនោះ នួន ជា បានហៅខ្លួន (ឌុច) ទៅការិយាល័យមួយនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយចាប់តាំងពីពេលនោះមកខ្លួនធ្វើការរាយការណ៍ទៅ នួន ជា ដែលជាថ្នាក់លើផ្ទាល់របស់ខ្លួន ហើយខ្លួននៅតែរក្សាទំនាក់ទំនងជាមួយ សុន សេន តាមរយៈទូរស័ព្ទរាល់សប្តាហ៍ ឬរាល់មួយខែម្តង ។

**◆ សមាជិកគណៈចាត់តាំងមជ្ឈិម និងការទទួលខុសត្រូវលើការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ**

ឌុច បានអះអាងថា នួន ជា ទទួលខុសត្រូវខាងគណៈចាត់តាំងមជ្ឈិមបក្ស និងមានអំណាចតាមដាននិងត្រួតពិនិត្យ តែងតាំងចំពោះបុគ្គលិកថ្មីនៅតាមមន្ទីរ និងក្រសួងនានារួមទាំងការតែងតាំងលេខាតំបន់ ឬភូមិភាគទៀតផង ។ នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ នួន ជា ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ ។ ក្នុងសេចក្តីសម្រេចនេះ ឌុច ចាត់ទុកថា នួន ជា ត្រូវបានដាក់ឲ្យទទួលខុសត្រូវលើក្រសួងចំនួនបួន គឺក្រសួងឃោសនាការ ក្រសួងអប់រំ ក្រសួងសង្គមកិច្ច និងក្រសួងវប្បធម៌ ហើយមូលហេតុនៃការតែងតាំងនេះគឺដោយសាររដ្ឋមន្ត្រីនៃក្រសួងទាំងបួនមិនមែនជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិម ។ តាមរយៈការអះអាងរបស់សាក្សីពីររូបដែលធ្លាប់ធ្វើការនៅក្រសួងពត៌មាននិងឃោសនាការ បានបង្ហាញថា នួន ជា ធ្វើជារដ្ឋមន្ត្រីនៃក្រសួងនេះចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។ តាមរយៈបទសម្ភាសន៍មួយ នួន ជា បានទទួលស្គាល់ថា មុនថ្ងៃ១៧ មេសា ១៩៧៥ ខ្លួនមានជាប់ពាក់ព័ន្ធនឹងការបោះពុម្ពផ្សាយ និងសរសេរទស្សនាវដ្តីទង់បដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានអះអាងបន្ថែមថា "នួន ជា ទទួលបន្ទុកកិច្ចការប្រចាំថ្ងៃនៅក្នុងបក្ស ។ ខ្ញុំនៅចាំបានថា ការងារនយោបាយរបស់បក្ស គឺផ្តោតជាសំខាន់លើការរៀនសូត្រប្រចាំឆ្នាំ" ។ នៅទីក្រុងភ្នំពេញ នួន ជា បានបង្រៀនវគ្គនយោបាយជាច្រើនដល់មហាជនដោយបានបង្រៀនមាគ៌ា ឬគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ។ ការប្រជុំរៀនសូត្រនោះធ្វើឡើងនៅបុរីកីឡា ដោយមានការចូលរួមពីសំណាក់កម្មាភិបាលដែលមកពីតាមភូមិភាគ តំបន់ គណៈស្រុក ប្រធានសហករណ៍ គណៈឃុំផ្សេងៗ និងសមាជិកកងទ័ពបដិវត្តកម្ពុជា ។

នួន ជា ធ្លាប់បានចូលរួមនៅក្នុងកិច្ចប្រជុំមួយស្តីអំពីការងារសង្គមកិច្ច និងសុខាភិបាល ដែលធ្វើឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ដែលនៅក្នុងនោះ អៀង ធីរិទ្ធ និងកម្មាភិបាលនៅក្រសួងសង្គមកិច្ច បានរាយការណ៍លម្អិតទាក់ទងនឹងការងាររបស់ក្រសួង ហើយក្នុងពេលនោះដែរ នួន ជា ក៏បានផ្តល់ជាយោបល់ខ្លះៗ ដែរនៅក្នុងកិច្ចប្រជុំនោះ ។

**◆ តួនាទីជានាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ**

បន្ទាប់ពីមានការប្រកាសជាផ្លូវការពីការសម្រាករបស់ ប៉ុល ពត ដើម្បីព្យាបាលសុខភាព នួន ជា ត្រូវបានប្រកាសតែងតាំងជានាយករដ្ឋមន្ត្រីស្តីទីរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយចាប់តាំងពីខែមករាដល់ខែកញ្ញា ឆ្នាំ១៩៧៧ នួន ជា ត្រូវបានប្រកាសជាញឹកញាប់ដោយសារព័ត៌មានបក្សកុម្មុយនីស្តកម្ពុជាពីតួនាទីជានាយករដ្ឋមន្ត្រីស្តីទីជាពិសេសនៅពេលធ្វើសុន្ទរកថាក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៩នៃកងទ័ពបដិវត្តកម្ពុជានៅថ្ងៃ១៦ ខែមករា ឆ្នាំ១៩៧៧ ។

**◆ តួនាទីជាប្រធានសភាតំណាងប្រជាជននិងប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន**

ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល នួន ជា មានតួនាទីជាប្រធានសភាតំណាងប្រជាជន និងជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ហើយការជ្រើសរើសឲ្យធ្វើជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន បានធ្វើឡើងនៅក្នុងសម័យប្រជុំសភាពេញអង្គលើកទី១ នៅថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ។ នៅក្នុងឋានៈទាំងពីរនេះ នួន ជា ត្រូវបានស្គាល់ជាសាធារណៈថា មានតួនាទីដឹកនាំគណៈប្រតិភូរបស់បក្សកុម្មុយនីស្តកម្ពុជាទៅធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសចិន និងកូរ៉េខាងជើង ធ្វើការទាក់ទងជាមួយមេដឹកនាំបរទេសនានា ព្រមទាំងចេញសេចក្តីសម្រេចនានា ។

**ក.៣) តួនាទីផ្សេងៗ**

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជនជាប់ចោទ នួន ជា ក៏មានតួនាទីជាលេខាភូមិភាគក្នុងមួយរយៈពេលខ្លីបន្ទាប់ពីមានការចាប់ខ្លួនលេខាភូមិភាគមួយចំនួន ។ នួន ជា ធ្វើជាលេខានៅភូមិភាគឦសាន ដែលកាលពីមុនគ្រប់គ្រងដោយ ឈ្មោះ ម៉ែន សាន ហៅ យ៉ា ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ ។ ក្រៅពីនោះទៀត នួន ជា ធ្វើជាលេខានៅភូមិភាគបូព៌ា គឺបន្ទាប់ពីមានការធ្វើអត្តឃាតរបស់ សោ ភឹម នៅខែមិថុនា ឆ្នាំ១៩៧៨ ។ ក្រៅពីតួនាទីទាំងនេះក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ ជនជាប់ចោទ នួន ជា ក៏មានភារកិច្ចរួមចំណែកទទួលខុសត្រូវនៅមន្ទីរនយោបាយ ៨៧០ និងមន្ទីរស-៧១ ។

**ខ) តួនាទីរបស់ជនជាប់ចោទ អៀង សារី**

ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រឡាបញ្ជីបានបន្តអានដីកាដំណោះស្រាយចាប់ពីកថាខណ្ឌ១០០២ដល់កថាខណ្ឌ១០១៥ នៅក្នុងនោះ អៀង សារី មានតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាពេញមួយរបបគ្រប់គ្រងនេះ ។ ក្នុងឋានៈជាសមាជិករបស់គណៈអចិន្ត្រៃយ៍ អៀង សារី បានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ ។ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យគឺមានតែ១៩ប៉ុណ្ណោះ ដែលនៅក្នុងនោះមានកំណត់ហេតុ១០ ដែលបញ្ជាក់ថា អៀង សារី បានចូលរួមប្រជុំ ប៉ុន្តែ អៀង សារី អាចចូលរួមប្រជុំច្រើនជាងនេះដោយយោងតាមការលើកឡើងរបស់ ខៀវ សំផន ដែលថាគណៈអចិន្ត្រៃយ៍កោះប្រជុំរវាងពី៧ទៅ១០ថ្ងៃម្តង ហើយកិច្ចប្រជុំកាន់តែ


អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ញឹកញាប់នៅពេលមានភាពចាំបាច់ ។

កំណត់ហេតុដែលនៅសេសសល់នោះបានបង្ហាញថា អៀង សារី ធ្លាប់ធ្វើបទឧទ្ទេសនាមលើបញ្ហានានាដូចជាបញ្ហាឧស្សាហកម្ម ពាណិជ្ជកម្ម ការដឹកជញ្ជូន ការចូលរួមសន្និសីទជាមួយបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងកូឡុំបូ ជំនួយបរទេស ជម្លោះជាមួយប្រទេសវៀតណាម ការអំពាវនាវដល់ប្រជាជនកម្ពុជាដែលនៅបរទេសឲ្យវិលត្រឡប់មកវិញ និងទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសផ្សេងៗ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី មានតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស និងតួនាទីផ្សេងៗមួយចំនួនទៀត ។

### ១.១) តួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៥ វិទ្យុនៅភ្នំពេញបានផ្សាយថា អៀង សារី ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ ការតែងតាំងនេះត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបក្សបានកត់ត្រាការតែងតាំងនេះនៅក្នុងឯកសារមួយមានចំណងជើងថា “សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន” ។ ការតែងតាំងនេះត្រូវបានគាំទ្រដោយសភាតំណាងប្រជាជនកម្ពុជានៅខែបន្ទាប់ ។ តែទោះបីជាយ៉ាងណាក៏ដោយ អៀង សារី បានលើកឡើងថា ខ្លួនទទួលយកតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៅក្នុងកំឡុងខែមេសា ឆ្នាំ១៩៧៦ ។

ក្រសួងការបរទេសដែលជាទូទៅត្រូវបានស្គាល់ថាមានអក្សរសម្គាល់ “ប-១” ត្រូវបានបង្កើតឡើង និងសម្ពោធជាផ្លូវការនៅខែធ្នូ ឆ្នាំ១៩៧៥ ។ សាក្សីម្នាក់បានអះអាងថា ប-១ មានមនុស្សធ្វើការជាងមួយពាន់នាក់ ដែលបុគ្គលិកទាំងនោះត្រូវបានជ្រើសរើសពីក្រុមមនុស្សដែលមានសមាសភាព “ស្អាតស្អំ” ។ មន្ទីរ ៨៧០ ជាអ្នកទទួលបន្ទុកជ្រើសរើសបុគ្គលិកឲ្យក្រសួងនេះ ។ បុគ្គលិកទាំងនោះត្រូវបានជ្រើសរើសមកពីភូមិភាគផ្សេងៗ ដោយផ្អែកលើវណ្ណៈ ឬសមត្ថភាព និងមកពីមូលដ្ឋានបដិវត្តចាស់ៗ...។ បុគ្គលិកមួយចំនួនក៏ត្រូវបានជ្រើសរើសចេញពីក្រុមបញ្ញវន្តដែលត្រឡប់មកពីបរទេសដែរ ។ បន្ថែមលើនេះទៅទៀត អៀង សារី បានជ្រើសរើសកុមារកម្មាភិបាលមួយចំនួនដែលមិនបានទទួលការសិក្សាអប់រំ ហើយមានអាយុចាប់ពី៨ ទៅ១៥ឆ្នាំ ។

នៅក្នុងសៀវភៅទិនានុលេខដែលនិយាយពីមន្ទីរប-១ មានចំណងជើង “សន្និបាតសាខា” ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៦ បានលើកឡើងថា “អៀង សារី ជាប្រធានសាខាបក្ស ហើយចំពោះទិដ្ឋភាពរដ្ឋបាល គាត់ជាគណៈប្រធានដឹកនាំទូទៅ និងជាប្រធានផ្នែកនយោបាយ...” ។ តាមរយៈអតីតកម្មាភិបាលជាន់ខ្ពស់ម្នាក់ដែលធ្វើការនៅមន្ទីរប-១ បានលើកឡើងថា “អៀង សារី ជាប្រធានផ្នែកនយោបាយ បានដឹកនាំអង្គប្រជុំនានាក្នុងកម្រិតក្រសួង ដឹកនាំអង្គប្រជុំបក្សនៅក្នុងក្រសួងដឹកនាំការផ្សាយ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងផ្សាយជាភាសាអង់គ្លេសនៃវិទ្យុកម្ពុជាប្រជាធិបតេយ្យ និងផ្តល់ការណែនាំទៅថ្នាក់ក្រោមបន្ទាប់អំពីការរៀបចំវគ្គរៀនសូត្រដល់បុគ្គលិកក្រសួង..” ។ តាមរយៈអតីតកម្មាភិបាលជាន់ខ្ពស់ម្នាក់ទៀតដែលធ្វើការនៅមន្ទីរប-១ដែរបានលើកឡើងថា “អៀង សារី គឺជាអ្នកដឹកនាំរួមនៅប-១ ដែលមានន័យថា គាត់ក៏ដឹកនាំសាខាបក្សក្នុងក្រសួងទទួលខុសត្រូវកិច្ចការផ្ទៃក្នុងរបស់ក្រសួង ផ្សព្វផ្សាយបទបញ្ជាពីថ្នាក់លើ ជាពិសេសពី ប៉ុល ពត និង នួន ជា បានជួបប្រជុំជាមួយបញ្ញវន្តដែលជាបុគ្គលិកស្ទើររៀងរាល់ថ្ងៃ គ្រប់គ្រងមន្ទីរអប់រំកែប្រែដែលជាសាខារបស់ក្រសួង ដូចជាមន្ទីរនៅប្រាំងចំរេះ និងព្រែកប្រា...” ។

ក្នុងតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស អៀង សារី បានធ្វើដំណើរទៅបរទេសជាច្រើនដង ដោយបានទៅធ្វើទស្សនកិច្ចនៅប្រទេសចិន វៀតណាម គុយបា បារាំង សហរដ្ឋអាមេរិក និងប្រទេសមួយចំនួនទៀត ហើយ អៀង សារី តែងតែទទួលគណៈប្រតិភូបរទេស រៀបចំពិធីជប់លៀង ចូលរួមប្រជុំពិភាក្សាពីទំនាក់ទំនងអន្តរជាតិនិងពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងអមដំណើរគណៈប្រតិភូទាំងនោះទៅទស្សនកិច្ចនៅទូទាំងប្រទេសកម្ពុជា ។

### ១.២) តួនាទីផ្សេងៗទៀត

ក្រៅពីតួនាទីដូចបានរៀបរាប់ខាងលើ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនិស្តកម្ពុជា អៀង សារី បានចូលរួមទទួលខុសត្រូវលើមន្ទីរនយោបាយ៨៧០ និងមន្ទីរ

ស-៧១ ។ ក្រៅពីនេះ អៀង សារី មានតួនាទីជាអ្នកខទ្ទេសនាមមនុស្សឲ្យចូលបក្ស ដឹកនាំគណៈកម្មការកិច្ចការបរទេសនៃគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិករបស់របស់គណៈកម្មាធិការនានាដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហានានា (ដូចជា ធនាគារ ការទិញសម្ភារ និងឃ្លាំងរដ្ឋនៅភ្នំពេញ) ។ បន្ថែមលើនេះ អៀង សារី អាចជាអ្នកដែលបានចូលរួមរៀបចំទស្សនាវដ្តីឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា ។

**គ) តួនាទីរបស់ជនជាប់ចោទ ខៀវ សំផន**

តាមរយៈបទចោទដែលបានអានដោយក្រឡាបញ្ជីនៅក្នុងសវនាការថ្ងៃនេះ ជនជាប់ចោទ ខៀវ សំផន មានតួនាទីនិងមុខងារជាច្រើននៅក្នុងអង្គភាពមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជាដូចជាគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ ប្រធានគណៈប្រធានរដ្ឋ អង្គភាពចំណុះមន្ទីរ៨៧០ ក្រសួងពាណិជ្ជកម្ម និងតួនាទីផ្សេងៗមួយចំនួនទៀត ។

**គ.១) តួនាទីជាសមាជិកគណៈមជ្ឈិម និងការចូលរួមក្នុងការងារគណៈអចិន្ត្រៃយ៍**

ខៀវ សំផន ត្រូវបានបញ្ចូលជាសមាជិកត្រៀមនៃគណៈមជ្ឈិមនៅឆ្នាំ១៩៧១ ហើយបានក្លាយជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៧៦ ។ ក្នុងនាមជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិម ខៀវ សំផន អាច «ពិគ្រោះ ពិភាក្សា និងរួមមតិសម្រេច» រាល់បញ្ហាដែលពាក់ព័ន្ធ ។ ខៀវ សំផន ធ្លាប់បានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍មួយចំនួន ។ ក្នុងចំណោមកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ដែលនៅសល់ទាំង១៩ គឺមានតែកំណត់ហេតុ១៥ប៉ុណ្ណោះ ដែលមានបញ្ជាក់ពីវត្តមានរបស់អ្នកចូលរួមប្រជុំ ហើយក្នុងចំណោមកំណត់ហេតុ១៥នេះ គឺមានតែកំណត់ហេតុ១៣ប៉ុណ្ណោះដែលបញ្ជាក់ថា ខៀវ សំផន បានចូលរួមប្រជុំ ។ ខៀវ សំផន បានចូលរួមប្រជុំជាញឹកញាប់ជាមួយ ប៉ុល ពត, នួន ជា, អៀង សារី និង ប៉ន់ នៅមន្ទីរក-១ ដែល




កិច្ចប្រជុំនេះមានការចូលរួមពីកម្មាភិបាលមកពីភូមិភាគ តំបន់ និងស្រុកនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មាភិបាល ថ្នាក់ក្រោម ។

**គ.២) តួនាទីជាប្រធានគណៈប្រធានរដ្ឋ**

ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានប្រមុខរដ្ឋនៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩៧៦ ក្នុងសម័យប្រជុំដំបូងនៃសភាតំណាងប្រជាជនកម្ពុជា ។ អង្គហេតុនៅក្នុងដីកាដំណោះស្រាយបានលើកឡើងថា «ការទទួលខុសត្រូវចម្បងនានារបស់ ខៀវ សំផនក្នុងតំណែងនេះគឺដើម្បីជួយលើកស្ទួយគោលនយោបាយផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជាលើឆាកអន្តរជាតិ ។ គាត់បានផ្ញើ និងទទួលលិខិតឆ្លើយឆ្លង និងសារគាំទ្រពីបណ្តាមេដឹកនាំ និងឯកអគ្គរដ្ឋទូតផ្សេងៗលើពិភពលោក ។ ...គាត់ធ្លាប់បានថ្លែងសុន្ទរកថានៅសន្និសីទកំពូលលើកទី៥របស់បណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡំបូក្នុងឆ្នាំ១៩៧៦ ។ ...និងបានអមដំណើរប្រតិភូបរទេសធ្វើទស្សនកិច្ចនៅជុំវិញប្រទេសកម្ពុជា ហើយបានរាយការណ៍ប្រាប់គណៈប្រតិភូទាំងនោះអំពីការកសាងប្រទេសឡើងវិញអំពីសហករណ៍និងបដិវត្តកសិកម្មជាដើម» ។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានដឹកនាំសកម្មភាពនានាដូចជា ប្រកាសឲ្យប្រើបទប្បញ្ញត្តិដែលកំណត់អំពីការប្រព្រឹត្តទៅរបស់សភាតំណាងប្រជាជនកម្ពុជា និងគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ។

### ក.៣) តួនាទីនៅអង្គភាពចំណុះមន្ទីរ៨៧០

ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន គឺជាកម្មាភិបាលដឹកនាំមួយរូបនៃអង្គភាពរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលមានឈ្មោះជាផ្លូវការថា "មន្ទីរនយោបាយ៨៧០" ។ ឌុច បានអះអាងថា "ខៀវ សំផន បានកាន់តួនាទីជាប្រធានមន្ទីរនយោបាយ៨៧០ នៅឆ្នាំ១៩៧៦ នៅពេលដែល ឌឿន ចាកចេញទៅគ្រប់គ្រងនៅក្រសួងពាណិជ្ជកម្ម..." ។ តែទោះបីជាយ៉ាងណាក៏ដោយ ខៀវ សំផន បានបញ្ជាក់ថា ខ្លួនមិនដែលធ្លាប់ធ្វើជាប្រធានមន្ទីរនយោបាយ៨៧០ឡើយ ដោយអះអាងថា ការងាររបស់ខ្លួននៅក្នុងមន្ទីរនេះគឺផ្តោតទៅលើបញ្ហាសេដ្ឋកិច្ច ការផ្គត់ផ្គង់ស្បៀងអាហារនៅទូទាំងប្រទេសកម្ពុជា... ។

### ក.៤) តួនាទីនៅក្រសួងពាណិជ្ជកម្ម

ខៀវ សំផន ត្រូវបានតែងតាំងឲ្យទទួលខុសត្រូវ "ពាណិជ្ជកម្មខាងបញ្ជីនិងតម្លៃ" ក្នុងកំឡុងពេលកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ។ ខៀវ សំផន បានអះអាងជាសាធារណៈថា ការទទួលខុសត្រូវរបស់គាត់រួមមានធ្វើការងារជាមួយនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសសម្រាប់ការនាំចេញនិងនាំចូលទំនិញ អនុវត្តសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទាក់ទងនឹងការបែកស្បៀងអាហារនៅទូទាំងប្រទេស និងរៀបចំតម្លៃផលិតផលដែលបានទទួលពីសហករណ៍ ។

### ក.៥) តួនាទីផ្សេងៗទៀត

ក្រៅពីតួនាទីដូចបានរៀបរាប់ខាងលើ ខៀវ សំផន មានតួនាទីមួយចំនួនទៀតដូចជា តួនាទីជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិ និងប្រជាជនកម្ពុជា ។ ប៉ុន្តែ ឌុច បានលើកឡើងថា "ខៀវ សំផន គ្រាន់តែជាប្រធានកិត្តិយសរបស់គណៈកម្មាធិការយោធា ជារូបភាពបង្ហាញសាកលលោកទេ រីឯ ប៉ុល ពត មានអំណាចពិតប្រាកដនៅក្នុងវិស័យយោធា" ។ ក្រៅពីនេះ ខៀវ សំផន ក៏មានភារកិច្ចពាក់ព័ន្ធកិច្ចការបរទេស អ្នកធ្វើមាតុភូមិនិវត្ត ទទួលបន្ទុកក្នុងការថ្លែងសុន្ទរកថាក្នុងនាមបក្សកុម្មុយនីស្តកម្ពុជា និងការបង្រៀននយោបាយជាដើម ។

### II. ការសួរដេញដោលលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A6 ដល់ A20

បន្ទាប់ពីការបញ្ចប់ការអានកថាខណ្ឌនានានៃដីកាដំណោះស្រាយដោយក្រឡាបញ្ជី អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុមលើកឡើងការជំទាស់របស់ខ្លួនទាក់ទងនឹងឯកសារទាំងឡាយដែលដាក់ចូលក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញា ។ ឯកសារដែលអង្គជំនុំជម្រះបើកឲ្យមានការដេញដោលរួមមានឯកសារមាននៅក្នុងឧបសម្ព័ន្ធ A6 រហូតដល់ឧបសម្ព័ន្ធ A20 លើកលែងឧបសម្ព័ន្ធ A12 និង A13 ។

- ឧបសម្ព័ន្ធ A6 ប្រវត្តិរូបអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
- ឧបសម្ព័ន្ធ A7 បញ្ជីឯកសារពាណិជ្ជកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យ
- ឧបសម្ព័ន្ធ A8 សេចក្តីរាយការណ៍ផ្សេងៗទាក់ទងនឹងស្រុកត្រាំកក់
- ឧបសម្ព័ន្ធ A9 កំណត់ត្រាអ្នកទោសនៅស-២១
- ឧបសម្ព័ន្ធ A10 ចម្លើយសារភាពពីស-២១
- ឧបសម្ព័ន្ធ A11 កំណត់ហេតុជាលាយលក្ខណ៍អក្សរពេលជំនុំជម្រះនៃសំណុំរឿង០០១
- ឧបសម្ព័ន្ធ A14 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង
- ឧបសម្ព័ន្ធ A15 ដែនទី និងរូបថត
- ឧបសម្ព័ន្ធ A16 ខ្សែអាត់សម្លេង និងវីដេអូ
- ឧបសម្ព័ន្ធ A17 ទំនាក់ទំនងអន្តរជាតិ
- ឧបសម្ព័ន្ធ A18 សេចក្តីរាយការណ៍ពីសារព័ត៌មានអន្តរជាតិ
- ឧបសម្ព័ន្ធ A19 អត្ថបទស្រាវជ្រាវ របាយការណ៍វិភាគ និងសៀវភៅ
- ឧបសម្ព័ន្ធ A20 របាយការណ៍ស្តីពីដីកាចាត់ឲ្យស៊ើបសួរជំនួស

គួរកត់សម្គាល់ថា សវនាការស្តីពីការដេញដោលលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A6 រហូតដល់ឧបសម្ព័ន្ធ A20 គឺបន្តពីសវនាការស្តីពីការសួរដេញលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ

A1 រហូតដល់ខបសម្ព័ន្ធ A5 កាលពីថ្ងៃទី១៦-១៩ ខែកុម្ភៈ ឆ្នាំ ២០១២ កន្លងទៅ ។

## ១) ការជំទាស់ទៅនឹងឯកសារដោយក្រុមមេធាវីការពារក្តី

### ក) មេធាវីការពារក្តីជនជាប់ចោទ នួន ជា

លោក ស៊ុន អរុណ មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា បានអះអាងថា លោកបានទាត់ចោលឯកសារជាច្រើនរួចមកហើយតាំងពីការចាប់ផ្តើមសវនាការ ដូចជាឯកសារថតចម្លង និងឯកសារស្កេនដែលពុំមានប្រភពច្បាស់លាស់ ។ ហេតុនេះ ក្រុមមេធាវីការពារក្តី នួន ជា នៅតែឲ្យសហព្រះរាជអាជ្ញាត្រូវតែបង្ហាញឯកសារដើម ។ ចំពោះឯកសារនៅក្នុងខបសម្ព័ន្ធ A7 ដែលជាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីបណ្ណសារដ្ឋានជាតិហើយត្រូវបានសហព្រះរាជអាជ្ញាដាក់ចូលក្នុងសំណុំរឿង លោកមេធាវីបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការផ្ទៀងផ្ទាត់ឲ្យបានច្បាស់លាស់រវាងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងឯកសារដែលទទួលបានមកពីបណ្ណសារដ្ឋានជាតិ ។ រីឯឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A8 លោកមេធាវីអះអាងថា គឺជាឯកសារដែលមានគុណភាពមិនល្អមិនអាចអានបាន និងទាមទារឲ្យមានការផ្ទៀងផ្ទាត់ជាមួយនឹងឯកសារដើម ។ ចំពោះឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A10 លោកបានស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធសម្តីរបស់ ឌុច ទាំងស្រុង ដោយលោកបានលើកឡើងថា ឌុច គ្រាន់តែជាប្រធានគុកមួយរូបប៉ុណ្ណោះ ហេតុអ្វីក៏ ឌុច បានដឹងពីរឿងរបស់គណៈមជ្ឈិមបក្សយ៉ាងច្បាស់ ហាក់បីដូចជារូប ឌុច នោះគឺជា ប៉ុល ពត ។ ចំពោះខបសម្ព័ន្ធ A14 លោកមេធាវីសុំបដិសេធចោលទាំងស្រុង ដោយលោកបានអះអាងថា ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាស្ថាប័នមួយដែលធ្វើការដោយលម្អៀងដោយសារតែការិយាល័យនេះធ្វើការតែជាមួយការិយាល័យសហព្រះរាជអាជ្ញា ។ លោកមេធាវីក៏បានស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធចោលចំពោះឯកសារថតចម្លងទាំងអស់ដែលបានដាក់ចូលក្នុងសំណុំរឿង ។ បន្ទាប់ពីការជំទាស់របស់ខ្លួន លោកមេធាវី ស៊ុន អរុណ បានប្រគល់ វេទិកាជូនសហភាគីរបស់ខ្លួនដើម្បីឡើងបន្តធ្វើការជំទាស់ទៅនឹងឯកសារដែលមាននៅក្នុងខបសម្ព័ន្ធផ្សេង ទៀត ។




លោក អេនដ្រូ អ៊ីនូហ្ស៊ី មេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានបន្តធ្វើការជំទាស់ ដោយបានលើកឡើងពីសារណាដែលក្រុមមេធាវីការពារក្តី នួន ជា ដាក់ជូនអង្គជំនុំជម្រះ ដោយស្នើសុំឲ្យអញ្ជើញអ្នកនិពន្ធអត្ថបទ ឬឯកសារដែលសហព្រះរាជអាជ្ញាប្រើប្រាស់អត្ថបទទាំងនោះឲ្យចូលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ លោកមេធាវីក៏បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកម្រិតចំពោះឯកសារទាំងឡាយដែលមាននៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះ ដោយជ្រើសរើសយកតែឯកសារណាដែលពាក់ព័ន្ធនឹងដំណាក់កាលទីមួយនៃសំណុំរឿង០០២ ប៉ុណ្ណោះ ។

ឆ្លើយតបនឹងការដាក់ឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកមេធាវី អ៊ីនូហ្ស៊ី បានលើកឡើងថា លោកសុំធ្វើការជំទាស់នឹងឯកសារដែលដាក់ដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយសារឯកសារ ៩ ក្នុងចំណោមឯកសារចំនួន១០ គឺមិនមានការជាប់ទាក់ទងនឹងសវនាការដំណាក់កាលទីមួយនៃសំណុំរឿង០០២ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A6 លោក

មេធាវី អ៊ីនូហ្ស៊ី បានបញ្ជាក់ថា ក្រុមមេធាវីការពារក្តី នួន ជា ជំទាស់ចំពោះការដាក់ឯកសារទាំងអស់នោះចូលក្នុងសំណុំរឿង ដោយសារវាជាឯកសារចម្លើយសារភាពដែលធ្វើឡើងដោយសារការធ្វើទារុណកម្ម និងដោយការបង្ខំ ។ លោកមេធាវីបានបន្ថែមថា បើយោងលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមាននៅក្នុងប្រតិចារិកនៃសំណុំរឿង០០១ បានច្រានចោលភស្តុតាងទាំងឡាយដែលធ្វើឡើងដោយការធ្វើទារុណកម្ម និងដោយបង្ខំ ។ ដូច្នេះការប្រើប្រាស់ចម្លើយសារភាពគឺជារឿងដែលមិនអាចទទួលយកបាន ។ ម្យ៉ាងទៀត ឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ គឺមិនមានជាប់ទាក់ទងនឹងដំណាក់កាលមួយ ដែលនិយាយពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារទេ ។ ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A9 ដែលនិយាយអំពីការអនុវត្តគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ក៏មិនមានការជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារដែរ ។

លោកមេធាវី អ៊ីនូហ្ស៊ី ក៏បានធ្វើការជំទាស់នឹងឯកសារមួយចំនួនផ្សេងទៀត ដូចជាឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A10 ទាក់ទងនឹងចម្លើយសារភាពពីស-២១, ឧបសម្ព័ន្ធ A14 ទាក់ទងនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, A15 ទាក់ទងនឹងផែនទី និងរូបថតផ្សេងៗ A16 ឯកសារទាក់ទងនឹងខ្សែអាត់សំឡេង និងវីដេអូ ។ ការជំទាស់នេះត្រូវបានលោកមេធាវីដោយផ្តល់ហេតុផលថា ឯកសារទាំងនោះ មិនមានការជាប់ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនិងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកបានបន្តទៀតថា ខ្សែអាត់សំឡេង និងវីដេអូ អាចមានការកែប្រែនៅខាងក្រោយក៏ថាបាន ។ លោកមេធាវី អ៊ីនូហ្ស៊ី មិនត្រឹមតែជំទាស់ឯកសារប៉ុណ្ណោះទេ ប៉ុន្តែលោកបានស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាទៅលើឯកសារមួយចំនួនទៀត ដូចជាឯកសារ D210/5 និង E109/1.01 និង កិច្ចសម្ភាសន៍ជាមួយលោក អ៊ុក ប៊ុនឈឿន ក្នុងឆ្នាំ១៩៧៩ ក៏ដូចជាការសម្ភាសសមាជិកព្រឹទ្ធសភាដែលបដិសេធមិនចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ, ឯកសារពាក់ព័ន្ធនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារពាក់ព័ន្ធនឹងសំណុំរឿង០០៣ និង០០៤ IS 21.74 សារទូរលេខផ្ញើរពី មាស មុត IS 19.71 កិច្ចសម្ភាសន៍ជាមួយលោក ហោ ណាំហុង ដែលសព្វថ្ងៃជារដ្ឋមន្ត្រីក្រសួងការបរទេស ដែលបានបដិសេធមិនចូលខ្លួនចំពោះមុខអង្គជំនុំជម្រះ ។ មេធាវីក៏បានស្នើសុំឲ្យអង្គជំនុំជម្រះចាត់វិធានការប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលពេលថ្មីៗនេះបានចោទប្រកាន់កូនក្តីខ្លួនថា ជាមនុស្សប្រផេងប្រផើង និងឯកសារ E1.71 ដោយទាមទារឲ្យមានការកែតម្រូវ ។

### ខ) មេធាវីការពារក្តីជនជាប់ចោទ អៀង សារី

លោក ម៉ៃឃើល ខាណាវ៉ាស់ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី បានច្រានចោលឯកសារមួយចំនួនរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយលើកឡើងថា សហព្រះរាជអាជ្ញាគ្រាន់តែចង់ឲ្យអង្គជំនុំជម្រះទទួលស្គាល់ឯកសាររបស់ខ្លួនដោយមិនមានបង្ហាញភស្តុតាងទាល់តែសោះ ។ ម្យ៉ាងវិញទៀត សកម្មភាពទាំងឡាយរបស់ជនជាប់ចោទដែលសាក្សីលើកឡើងអាចទទួលយកបានលុះត្រាតែសាក្សីនោះត្រូវបានសួរនាំនៅចំពោះមុខអង្គជំនុំជម្រះ ។ លោកបានបន្តថា នៅតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក៏បានអនុវត្តដូច្នេះដែរ ។

លោកមេធាវី ខាណាវ៉ាស់ បានគាំទ្រចំពោះការលើកឡើងរបស់ក្រុមមេធាវីរបស់ជនជាប់ចោទ នួន ជា ដោយលោកបានអះអាងថា មានឯកសារប្រវត្តិរូបជាច្រើនមិនអាចទទួលយកបានដោយសារតែឯកសារប្រវត្តិរូបទាំងនោះបានមកដោយសារការធ្វើទារុណកម្ម ។ លោកបានបន្ថែមថា សហព្រះរាជអាជ្ញាត្រូវតែបង្ហាញឲ្យបានច្បាស់ថា ឯកសារដែលខ្លួនបានដាក់គឺជាឯកសារសំខាន់ដែលអាចធ្វើឲ្យក្រុមមេធាវីការពារក្តីយល់ឃើញថាអាចទទួលយកបាន ។ លោកមេធាវីបានស្នើសុំអង្គជំនុំជម្រះថា រាល់ឯកសារដែលផ្តល់ឲ្យដោយសាក្សីនឹងត្រូវយកមកពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះ លុះត្រាតែសាក្សីរូបនោះត្រូវបានសួរដេញដោល នៅក្នុងបន្ទប់សវនាការជាមុនសិន ។

លោកមេធាវី ខាណាវ៉ាស់ បានបដិសេធឯកសារដែលទាក់ទងជាមួយជនជាប់ចោទ អៀង ធីរិទ្ធ ដោយលោកអះអាងថា ដោយសារជនជាប់ចោទ អៀង ធីរិទ្ធ មិនមានជាប់ពាក់ព័ន្ធនឹងសវនាការនាពេលនេះ ។ លោកបានបដិសេធឯកសារដែលជា

ចម្លើយសារភាពនៅមន្ទីរស-២១ ដោយយល់ស្របជាមួយក្រុមមេធាវី នួន ជា ដែរថា វាមានលក្ខណៈផ្ទុយពីច្បាប់អន្តរជាតិ ។ លោកមេធាវីបានច្រានចោលឯកសារដែលជាប្រតិចារិកនៅក្នុងសំណុំរឿង០០១ លើកលែងតែសាក្សីដែលផ្តល់សក្ខីកម្មនៅក្នុងសំណុំ រឿង០០១ មកផ្តល់សក្ខីកម្មម្តងទៀតនៅក្នុងសំណុំរឿង ០០២នេះ ។ លោកបានបន្តបដិសេធចំពោះឯកសារដែលជារបាយការណ៍កំណត់អំពីអត្តសញ្ញាណទីកន្លែងដែលសាក្សីបានផ្តល់សក្ខីកម្មទាក់ទងនឹងបញ្ហានេះ ។ លោកបានអះអាងថា ការផ្តល់សក្ខីកម្មបែបនេះ គឺមិនអាចទុកចិត្តបាន ដោយសារគេមិនអាចដឹងថាតើសាក្សីរូបនោះមានការចងចាំច្បាស់លាស់ប៉ុណ្ណាឡើយ ដោយសារនៅក្នុងអំឡុងឆ្នាំ១៩៧៥ សាក្សីខ្លះទើបតែមានអាយុមិនលើសពី១០ឆ្នាំផង ប៉ុន្តែបានផ្តល់សក្ខីកម្មហាក់បីដូចជាខ្លួនមានការចងចាំខ្លាំង ។ ដូច្នេះក្រុមមេធាវីការពារក្តី អៀង សារី សុំធ្វើការបដិសេធឯកសារទាក់ទងនឹងការកំណត់ពីអត្តសញ្ញាណទីកន្លែងលើកលែងតែសាក្សីទាំងនោះត្រូវបានអង្គជំនុំជម្រះកោះអញ្ជើញមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ លោកបានបន្ថែមទៀតថា ចំពោះបុគ្គលដែលបានផ្តល់ឯកសារជូនអង្គជំនុំជម្រះ ប៉ុន្តែមិនទាន់បានធ្វើសម្បថ គឺមិនត្រូវទទួលស្គាល់ឯកសារនោះឡើយ ។

លោកមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី បានជំទាស់ចំពោះខ្សែអាត់សំឡេង និងវីដេអូ ដោយសម្អាងលើហេតុផលស្រដៀងគ្នានឹងហេតុផលខាងលើដែរ គឺទាមទារឲ្យមានការសាកសួរសាក្សីដែលផ្តល់ព័ត៌មានប្រភេទនេះ ។ ដើម្បីកុំឲ្យមានការបកស្រាយណាមួយចោទប្រកាន់មកលើកូនក្តីរបស់ខ្លួន ហេតុនេះអង្គជំនុំជម្រះត្រូវតែកោះហៅសាក្សីទាំងនោះមកសាកសួរនៅក្នុងសវនាការ ។

ប្រភេទឯកសារទំនាក់ទំនងអន្តរជាតិ មាន៨ឯកសារ ។ ឯកសារទាំងនេះមិនត្រូវទទួលយកទេ លុះត្រាតែមានការបង្ហាញថាឯកសារទាំងនេះមានភាពស៊ីសង្វាក់គ្នា ។ ឧទាហរណ៍ដូចជាឯកសារទាក់ទងនឹងប្រវត្តិរូប វាមិនមែនជាឯកសារទាក់ទងនឹងទំនាក់ទំនងអន្តរជាតិទេ ។ មួយទៀត ឯកសារព្រះរាជក្រឹត្យលើកលែងទោស អៀង សារី ក៏មិនស្ថិតនៅក្នុងប្រភេទឯកសារទំនាក់ទំនងអន្តរជាតិដែរ ។ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញពីឯកសារ


ទិដ្ឋភាពក្នុងសវនាការ (រូបថត ៖ អ.វ.ត.ក)

ដែលខ្លួនបានដាក់ មិនមែនទុកឲ្យមេធាវីជាអ្នកធ្វើការបង្ហាញនោះទេ ។ រីឯឯកសារដែលជាប្រព័ន្ធសារព័ត៌មានអន្តរជាតិ លោកមេធាវីបានអះអាងថា អង្គជំនុំជម្រះមិនគួរទទួលយកឡើយ លុះត្រាតែឯកសារទាំងនោះមានភាពស៊ីសង្វាក់គ្នាយ៉ាងសុក្រឹតរវាងបណ្តាញសារព័ត៌មាននីមួយៗ ។

នៅមុនពេលបញ្ចប់សេចក្តីជំទាស់របស់ខ្លួន លោកមេធាវីខាណារ៉ាស់ បានស្នើសុំទាមទារឲ្យអ្នកដែលផ្តល់ឯកសារក៏ដូចជាអ្នកនិពន្ធឯកសារជាដើមចូលខ្លួនមកធ្វើសក្ខីកម្ម បើសិនជាឯកសារទាំងនោះត្រូវបានទទួលស្គាល់ ។ ឯកសារទាំងនោះមានដូចជាឯកសារស្រាវជ្រាវ វិភាគ និងសៀវភៅ មិនគួរទទួលយកនោះទេ លុះត្រាតែអ្នកនិពន្ធចូលមកផ្តល់សក្ខីកម្ម ព្រោះអ្នកសរសេរទាំងអស់នោះធ្វើការសម្ភាសន៍ ហើយសរសេរចូលទៅក្នុងសៀវភៅ ។ រីឯឯកសារដែលវិភាគដោយសហព្រះរាជអាជ្ញាត្រូវតែបដិសេធចោល លុះត្រាតែអញ្ជើញអ្នកធ្វើរបាយការណ៍វិភាគទាំងនោះមកផ្តល់សក្ខីកម្ម លើកលែងតែសាក្សីនៅឆ្ងាយមិនអាចមកផ្តល់សក្ខីកម្មបាន ។ ឧទាហរណ៍លោក ក្រេក អ៊ិចឆេសិន ជាដើម ព្រោះគាត់ធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០១ម្តងរួចមកហើយ ដូចនេះលោក អ៊ិចឆេសិន គួរតែចូលខ្លួនមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការសំណុំរឿង០០២ម្តងទៀត ។ លោកមេធាវីបានបន្តលើកឡើងទាក់ទងនឹងឯកសារបទសម្ភាសន៍ដែលនិយាយពីសកម្មភាព និងតួនាទីរបស់ អៀង សារី ដោយលោកស្នើឲ្យអង្គជំនុំជម្រះត្រូវតែកោះហៅអ្នកផ្តល់សម្ភាសន៍ទាំងនោះមកផ្តល់សក្ខីកម្ម ។ ឯកសារដែលទាក់ទងនឹងនិស្សិតថ្នាក់អនុបណ្ឌិតម្នាក់ដែលរៀននៅសាកលវិទ្យាល័យ យ៉ែល ដែលបានធ្វើទាក់ទងនឹងឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជាអង្គជំនុំជម្រះត្រូវតែកោះអញ្ជើញបុគ្គលនោះមកផ្តល់សក្ខីកម្ម ព្រោះបុគ្គលនោះអាចចាត់ទុកថាគឺ ជាអ្នកជំនាញមួយរូប ។

ចំពោះរបាយការណ៍ចាត់ឲ្យសួរជំនួស លោកមេធាវីលើកឡើងថាមិនត្រូវទទួលស្គាល់នោះឡើយ បើទទួលស្គាល់ត្រូវរៀបចំរបាយការណ៍ទាំងអស់នោះឲ្យមានមូលដ្ឋានអាចទទួលយកបាន ។ លោកបានចោទប្រកាន់សហព្រះរាជអាជ្ញាថាបានព្យាយាមលួចដាក់ឯកសារបន្ថែមចូលទៅក្នុងសំណុំរឿង ។

## គ) មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន

លោក គង់ សំអុន មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ជំទាស់នឹងការដាក់ឯកសារភស្តុតាងរបស់សហព្រះរាជអាជ្ញា ដែលមាននៅក្នុងឧបសម្ព័ន្ធពី A6 រហូតដល់ឧបសម្ព័ន្ធ A20 ។ លោកលើកឡើងថា ការដាក់ឯកសារភស្តុតាងរបស់សហព្រះរាជអាជ្ញា គឺធ្វើឡើងមុនពេលអង្គជំនុំជម្រះចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី និងក្រោយពេលសហចៅក្រមស៊ើបអង្កេតចេញដីកា




ដំណោះស្រាយ ដែលធ្វើឲ្យមានចំណោទជាច្រើនសម្រាប់ក្រុមមេធាវីការពារក្តី ។ គួរកត់សម្គាល់ថា ការបំបែកកិច្ចដំណើរការនីតិវិធី គឺដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចធ្វើការជំនុំជម្រះលើជនជាប់ចោទទៅតាមអង្គហេតុដែលតុលាការកំណត់យកមកកាត់សេចក្តី ដោយបំបែកអង្គហេតុនោះចេញពីអង្គហេតុទាំងមូលដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអនុញ្ញាតឲ្យអង្គជំនុំជម្រះចេញសាលក្រមសម្រេចលើពិរុទ្ធភាពរបស់ជនជាប់ចោទ

ភ្លាមៗ បន្ទាប់ពីការបញ្ចប់នីតិវិធី ។ ដូច្នេះភាគីទាំងអស់ត្រូវដាក់តែឯកសារ ឬភស្តុតាងណាមួយដែលជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់យកមកធ្វើការជំនុំជម្រះតែប៉ុណ្ណោះ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន យល់ថា ការដែលសហព្រះរាជអាជ្ញាដាក់ឯកសារចូលក្នុងសំណុំរឿង មុនពេលអង្គជំនុំជម្រះសាលាដំបូងចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី បានធ្វើឲ្យឯកសារភាគច្រើនរបស់សហព្រះរាជអាជ្ញាមិនមានជាប់ពាក់ព័ន្ធ



រូបថត៖ អ.វ.ត.ក

នឹងសវនាការដំណាក់កាលដំបូង ដែលអង្គជំនុំជម្រះកំណត់យកមកធ្វើការជំនុំជម្រះ ។ លោកមេធាវី សំអុន បានបញ្ជាក់ថា ឯកសារមួយចំនួនដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាពុំមានជាប់ទាក់ទងនឹងសវនាការដំណាក់កាលដំបូងនេះទេ ប៉ុន្តែវាអាចនឹងជាប់ទាក់ទងនឹងសវនាការដំណាក់កាលក្រោយៗ ។ លោកបានបន្តថា ឯកសារថ្មីៗជាច្រើនដែលត្រូវបានដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធនានាដោយសហព្រះរាជអាជ្ញា មានរហូតដល់ ៣៨១៦ឯកសារ ដែលឯកសារទាំងនេះមិនគួរត្រូវលើកយកមកជំទាស់នៅក្នុងសវនាការដំណាក់កាលនេះឡើយ ។ ដូច្នេះ ក្រុមមេធាវីការពារក្តី ខៀវ សំផន នឹងធ្វើការដេញដោលឯកសារទាំងអស់នោះនៅពេលក្រោយ ។ លោកបានបន្ថែមថា សហព្រះរាជអាជ្ញាត្រូវតែដកឯកសារណាដែលមិនពាក់ព័ន្ធចេញជាមុន ដើម្បីចំណេញពេលវេលាដល់ក្រុមមេធាវីការពារក្តីក្នុងការពិនិត្យមើលឯកសារ ។ រីឯបញ្ហាឯកសារទាក់ទងនឹង អៀង ធីរិទ្ធ ក្រុមមេធាវីការពារក្តី ខៀវ សំផន នឹងមិនលើកយកមកពិភាក្សាទេ ។

លោកមេធាវីបានបន្តទៀតថា ចំពោះឯកសារទាំងឡាយដែលមានជាប់ទាក់ទងនឹងសកម្មភាព និងអាកប្បកិរិយារបស់ជនជាប់ចោទ អង្គជំនុំជម្រះត្រូវតែហៅជនដែលសរសេរអត្ថបទទាំងនោះមកធ្វើការដេញដោលនៅក្នុងសវនាការ ដើម្បីដឹងពីមូលហេតុនៃការសរសេរនោះ ព្រោះនៅក្នុងច្បាប់អន្តរជាតិ អនុញ្ញាតអង្គជំនុំជម្រះអាចធ្វើដូច្នេះបាន ។ បន្ទាប់មកលោកមេធាវី គង់ សំអុន បានប្រគល់វេទិកាជូនសហភាគីអន្តរជាតិរបស់ខ្លួន គឺកញ្ញាមេធាវី អង់តា ហ្គីសេ ឡើងបន្តធ្វើការជំទាស់ ។

មេធាវី អង់តា ហ្គីសេ បានលើកឡើងថា ខ្លួននឹងមិនធ្វើការជំទាស់ច្រំដែលលើឯកសារដែលក្រុមមេធាវីផ្សេងទៀតបានលើកឡើងរួចមកហើយនោះទេ ។ មេធាវី អង់តា ហ្គីសេ បានបដិសេធឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A6 ទាក់ទងនឹងប្រវត្តិរូបសង្ខេបនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយគាំទ្រទាំងស្រុងចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន នឹងធ្វើការជំទាស់ដោយផ្តោតទៅលើការរក្សាទុក ឬខ្សែសង្វាក់នៃការទទួល និងទុកដាក់ឯកសារ ។ មេធាវី ហ្គីហ្សេ បានលើកយកឯកសារមួយចំនួនមកបង្ហាញ និងបានអះអាងថា ឯកសារទាំងនោះមិនដឹងថាមានប្រភពមកពីទីណា ថែមទាំងមិនអាចទុកចិត្តបានទៀតផង និងស្នើសុំអង្គជំនុំជម្រះឲ្យបដិសេធឯកសារវិភាគរបស់លោក ក្រេក អ៊ិចឆេសិន ។ ទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A7 ដែលជារបាយការណ៍ពាណិជ្ជកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យ ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំធ្វើការច្រានចោលឯកសារទាំងនោះ ដោយស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យមើលការលើកឡើងរបស់លោកមេធាវី គង់ សំអុន

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ទាក់ទងនឹងខ្វះសង្វាក់នៃការទទួល និងរក្សាទុកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវី ហ្គីសេ ក៏បានស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យលើចំណារដែលសរសេរដោយដៃ និងការរក្សាទុកឯកសាររបស់បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ពាក់ព័ន្ធនឹងឧបសម្ព័ន្ធ A8 មេធាវី ហ្គីសេ គាំទ្រចំពោះការជំទាស់របស់ក្រុមមេធាវី អៀង សារី ដោយសារនៅក្នុងឧបសម្ព័ន្ធ A8 មិនឃើញមានឯកសារដើមរបស់សាស្ត្រាចារ្យ ប៉ែន ឃៀរនិន ។ ដូច្នេះឯកសាររបស់សាស្ត្រាចារ្យ ប៉ែន ឃៀរនិន គួរតែត្រូវបានបដិសេធ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏សុំបដិសេធឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A9 និង A10 ដែលជាឯកសារចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម ដោយយល់ស្របជាមួយនឹងហេតុផលដែលក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី លើកឡើង ។ មេធាវី ហ្គីសេ បានបញ្ជាក់ថា ឯកសារទាំងនោះមិនអាចទទួលយកបានទេ ហើយក៏មិនជាប់ពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងនេះដែរ ។

ទាក់ទងនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរក្នុងពេលជំនុំជម្រះនៃសំណុំរឿង ០០១ ដូចជាឯកសារជាប្រតិចារិកដែល ឌុច បាននិយាយនៅក្នុងសវនាការដែលមាននៅក្នុងឧបសម្ព័ន្ធ A11 មេធាវី ហ្គីសេ សុំប្រានចោលទាំងអស់លុះត្រាតែ ឌុច ត្រូវបានកោះហៅមកធ្វើការសួរដេញដោលតទល់ជាមួយជនជាប់ចោទនៅក្នុងសវនាការ ។ កញ្ញាមេធាវី បានជំទាស់នឹងសេចក្តីថ្លែងការណ៍របស់លោក រ៉ាអ៊ូល ម៉ាក ហ្សេណា (Raoul Marc Jennar) ដែលបានលើកឡើងពីឈ្មោះកូនក្តីរបស់ខ្លួនជាច្រើនដងនៅក្នុងសៀវភៅដែលលោកបានសរសេរ និងថាអង្គជំនុំជម្រះត្រូវតែកោះហៅលោកមកសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។

ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A14 ទាក់ទងនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្ម និង A15 ទាក់ទងនឹងផែនទី និងរូបថត ក្រុមមេធាវីការពារ ខៀវ សំផន បានបដិសេធឯកសារអស់នេះ ដោយផ្តល់ហេតុផលថា ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A14 និង A15 ពុំមានការជាប់ទាក់ទងនឹងសវនាការដំណាក់កាលដំបូងទេ ។ មេធាវី ហ្គីសេ បានបន្ថែមថា ប្រសិនបើឯកសារទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង អង្គជំនុំជម្រះត្រូវតែកោះហៅជនដែលសរសេរឯកសារទាំងអស់នោះដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ កញ្ញាមេធាវី បានស្នើសុំឲ្យអង្គជំនុំជម្រះប្រានចោលឯកសារ និងផែនទីដែលបានមកពីបណ្ណសាររបស់វៀតណាម ដោយអះអាងថា ឯកសារទាំងនោះមិនដឹងថាមានប្រភពមកពីទីកន្លែងណា និងបានចោទជាសំណួរថា តើមានប្រយោជន៍អ្វីដែលត្រូវដាក់បញ្ចូលផែនទីបណ្តាញផ្លូវថ្នល់ដែលធ្វើឡើងកាលពីឆ្នាំ២០០១ចូលទៅក្នុងសំណុំរឿងនោះ?

ទាក់ទងនឹងឯកសារក្នុងឧបសម្ព័ន្ធ A16 ទាក់ទងនឹងខ្សែអាត់សំឡេង និងវីដេអូ កញ្ញាមេធាវី ហ្គីសេ បានលើកឡើងថា មានឯកសារច្រើនណាស់នៅក្នុងបញ្ជីនេះដែលមិនមានភាពជាប់ទាក់ទងនឹងសវនាការក្នុងដំណាក់កាលដំបូង ។ ឧទាហរណ៍ដូចជា ឯកសារបទសម្ភាសន៍ដែលធ្វើឡើងដោយលោក ស៊ីវ ហេដឌ័រ ជាមួយនឹងលោក អ៊ុក ប៊ុនឈឿន និងឯកសារសម្ភាសន៍ដែលធ្វើឡើងដោយសាស្ត្រាចារ្យ ប៉ែន ឃៀរនិន នៅក្នុងទសវត្សរ៍ទីឆ្នាំ១៩៩០ ។ មេធាវី ហ្គីសេ ក៏ជំទាស់នឹងវីដេអូស្តីពីបទសម្ភាសន៍ និងប្រតិចារិកជាលាយលក្ខណ៍អក្សរ រួមទាំងឯកសារសម្ភាសន៍ជាមួយនឹង ខៀវ សំផន នៅឆ្នាំ១៩៩៨, ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្តល់ឲ្យសហព្រះរាជអាជ្ញា និងឯកសារមួយចំនួនទៀតនៅក្នុងឧបសម្ព័ន្ធនេះដែលមិនទាន់បានធ្វើអត្ថាធិប្បាយពន្យល់ឲ្យបានពេញលេញ ។

ពាក់ព័ន្ធនឹងឯកសារនៃឧបសម្ព័ន្ធ A18 ដែលជាសេចក្តីរាយការណ៍ពីសារព័ត៌មានអន្តរជាតិ មេធាវី ហ្គីសេ បានអះអាងថា ក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្លាប់បានជំទាស់ម្តងរួចទៅហើយកាលពីសវនាការពេលមុន ។ ហេតុនេះខ្លួននឹងមិនធ្វើការជំទាស់បន្ថែមទៀតទេ គឺគ្រាន់តែបង្ហាញឯកសារមួយចំនួននៅក្នុងបញ្ជីឯកសារដែលខ្លួនយល់ឃើញថា មិនអាចទទួលយកបានដោយសារតែមិនមានឯកសារដើម និងមិនមានភាពច្បាស់លាស់ ដែលនាំឲ្យមិនអាចយកឯកសារទាំងនេះធ្វើជាមូលដ្ឋានបាន ។

ទាក់ទងនឹងឯកសារនៃឧបសម្ព័ន្ធ A19 ដែលជាអត្ថបទស្រាវជ្រាវ និងរបាយការណ៍វិភាគ និងសៀវភៅ ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំគាំទ្រចំពោះការជំទាស់របស់ក្រុមមេធាវី

អៀង សារី ដែលជំទាស់ឯកសារវិភាគរបស់លោក ក្រេក អ៊ិចឆេសិន ដោយសាររបាយការណ៍នោះមានភាពចម្រូងចម្រាស់ ។ មេធាវី ហ៊្គីសេ បានបន្តថា បើសហព្រះរាជអាជ្ញាចង់ពិនិត្យឯកសារនោះ លុះត្រាតែលោក ក្រេក អ៊ិចឆេសិន ត្រូវបានកោះហៅមកសួរដេញដោលនៅក្នុងសវនាការ ។

ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏ជំទាស់ចំពោះឯកសារនៃឧបសម្ព័ន្ធ A20 ដែលជាប់ទាក់ទងនឹងរបាយការណ៍ស្តីពីដីកាចាត់ឲ្យស៊ើបសួរជំនួស ដោយអះអាងថា មិនត្រូវប្រើប្រាស់របាយការណ៍ដែលចាត់ឲ្យស៊ើបសួរជំនួស ដោយពុំមានការសួរដេញដោលឲ្យបានត្រឹមត្រូវនោះទេ ។

ចំពោះឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០ គឺមានតែឯកសារ១ប៉ុណ្ណោះ ដែលជាប់ទាក់ទងនឹងសវនាការដំណាក់កាលដំបូង គឺឯកសាររបស់សាស្ត្រាចារ្យ ប៉ែន យៀរនិន ប៉ុន្តែអង្គជំនុំជម្រះត្រូវតែពិនិត្យទៅលើឯកសារមួយនេះ ដោយសារតែនៅពេលដែលលោក ប៉ែន យៀរនិន សរសេរឯកសារនោះ លោកទើបនឹងមានអាយុ២១ឆ្នាំ និងគ្រាន់តែជានិស្សិតមួយរូបប៉ុណ្ណោះ ។ មេធាវី ហ៊្គីសេ បានស្នើសុំកុំឲ្យមានការដាក់ឯកសារច្រើនពេក និងអះអាងថា មេធាវីមិនមែនចេះតែធ្វើការជំទាស់នោះទេ ប៉ុន្តែវាជាកាតព្វកិច្ចរបស់ភាគីនៅក្នុងសំណុំរឿង ។

បន្ទាប់ពីក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានបញ្ចប់សេចក្តីជំទាស់របស់ខ្លួន ប្រធានអង្គជំនុំជម្រះ លោក ចៅក្រម និល ណុន បានផ្តល់ឱកាសដល់សហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការជំទាស់ឯកសារដែលដាក់ដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ ភ្លាមៗនោះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានក្រោកឈរ និងជម្រាបជូនអង្គជំនុំជម្រះថា ក្រុមរបស់ខ្លួននឹងមិនជំទាស់ឯកសារដែលដាក់ដោយក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីក្រុមទេ ។

បន្តមក អង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមចំពោះឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ A6-A20 ។

## ២) ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តី

ពាក់ព័ន្ធនឹងការជំទាស់ចំពោះឯកសារនៃឧបសម្ព័ន្ធ A6 រហូតដល់ឧបសម្ព័ន្ធ A20 សហព្រះរាជអាជ្ញាបានឆ្លើយតបជារួមទៅក្រុមមេធាវីការពារក្តីបីក្រុម ដោយធ្វើការបែងចែកចំពោះការឆ្លើយតបនឹងការជំទាស់ទូទៅ និងការជំទាស់ជាក់លាក់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុម ។

### ក) ការឆ្លើយតបនឹងការជំទាស់ទូទៅ

### ក.១) *គោលការណ៍ច្បាប់*

ឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តីទាំងបីក្រុម លោកតំណាងសហព្រះរាជអាជ្ញាជាតិ វេង ហ៊ត់ បានលើកឡើងនូវទិដ្ឋភាពផ្លូវច្បាប់ទាក់ទងនឹងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងដែលចែងពីភាពអាចទទួលយកបាននៃភស្តុតាង ។ លោកតំណាងសហព្រះរាជអាជ្ញាបានលើកឡើងពីអនុស្សារណៈ E១៦២ របស់អង្គជំនុំជម្រះដែលធ្លាប់បានធ្វើទាក់ទងនឹងការទទួលយកភស្តុតាង និងការទទួលយកភស្តុតាងមួយក្រឡេកភ្នែកដែលមានន័យថា មិនតម្រូវឲ្យឯកសារទាំងអស់ត្រូវតែមានឯកសារដើម និងត្រូវតែបញ្ជាក់គ្រប់ចំណុចទេ ។

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តទៀតថា ក្រុមមេធាវីការពារក្តីបានលើកឡើងពីទម្ងន់នៃឯកសារ ជាជាងភាពអាចទទួលយកបាននៃឯកសារទាំងនោះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនតម្រូវឲ្យមានឯកសារច្បាប់ដើមនោះទេ ទោះបីជាច្បាប់ដើមអាចប្រើប្រាស់ដោយមានទម្ងន់ជាងឯកសារថតចម្លងក៏ដោយ ។ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់រួចហើយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកន្លងមក ដោយបញ្ជាក់ថា មិនចាំបាច់ទាល់តែមានការកោះហៅអ្នកជំនាញដែលមានចំណេះដឹងមកធ្វើសក្ខីកម្ម និងមានការបញ្ជាក់អំពីការរក្សាទុកនៃឯកសារទាំងអស់ឡើយ ។ លោកតំណាងសហព្រះរាជអាជ្ញាបានអះអាងថា បញ្ហាជាច្រើនទាក់ទងនឹងឯកសារដែលលើកឡើងដោយមេធាវីការពារក្តី គឺធ្វើយ៉ាងណាដើម្បីដកឯកសារចេញ ជាជាងការដាក់បញ្ចូលឯកសារ ។ លោកក៏បានបញ្ជាក់ទៀតថា អង្គជំនុំជម្រះបានបកស្រាយហើយថាឯកសារថតចម្លងនឹងត្រូវយកមកប្រើប្រាស់

ជំនួសឯកសារដើម ។ ម្យ៉ាងវិញទៀត ក្នុងសវនាការនាពេលកន្លងទៅ មានមន្ត្រីជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺលោក ឆាំង យុ និងលោក វ៉ាន់ថាន់ ពៅដារ៉ា ធ្លាប់បានផ្តល់សក្ខីកម្ម និងបញ្ជាក់យ៉ាងច្បាស់លាស់រួចហើយទាក់ទងនឹងយថាភាព ភាពគួរឲ្យជឿជាក់បាន និងខ្សែសង្វាក់រក្សាទុកនៃឯកសារ ។

### ក.២) ភាពអាចទទួលយកបាននៃឯកសារ

លោកតំណាងសហព្រះរាជអាជ្ញា វេង ហ៊ត់ បានលើកឡើងអំពីគោលការណ៍វាយតម្លៃដោយសេរីចំពោះភស្តុតាងតាមប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំងដែលមានឥទ្ធិពលខ្លាំងមកលើអង្គជំនុំជម្រះ ។ សហចៅក្រមស៊ើបអង្កេតក៏ធ្លាប់បានបដិសេធឯកសារមួយចំនួនដែលខ្លួនយល់ថា ឯកសារទាំងនោះមិនមានភាពជាប់ពាក់ព័ន្ធ ដូច្នេះឯកសារដែលនៅចំពោះមុខអង្គជំនុំជម្រះគឺជាឯកសារភស្តុតាងដែលបានទទួលយកដោយចៅក្រមស៊ើបអង្កេត ។ ចៅក្រមនៃអង្គជំនុំជម្រះនាពេលនេះ ក៏ជាចៅក្រមដែលមានវិជ្ជាជីវៈ ។ លោកសហព្រះរាជអាជ្ញា ក៏បានលើកឡើងពីយុត្តិសាស្ត្រអន្តរជាតិ ដើម្បីបង្ហាញទៅអង្គជំនុំជម្រះពីការទទួលយកភស្តុតាងដោយមិនតម្រូវពីលក្ខខណ្ឌខ្ពស់ហួសហេតុក្នុងការទទួលយកភស្តុតាង ។

### ក.៣) ប្រភពនៃឯកសារ

ដោយយោងទៅលើសក្ខីកម្មរបស់លោក ឆាំង យុ និងលោក ពៅដារ៉ា ដែលធ្វើឡើងនៅអំឡុងពេលសវនាការ និងសក្ខីកម្មរបស់លោក ឆាំង យុ ធ្វើឡើងជាមួយសហចៅក្រមស៊ើបអង្កេតកាលពីឆ្នាំ២០០៩ ។ លោកតំណាងសហព្រះរាជអាជ្ញាជាតិបានលើកឡើងពីភាពជាក់លាក់នៃប្រភពឯកសារដែលមន្ត្រីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងពីររូបបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកន្លងទៅ ដែលមានដូចជាប្រភពឯកសារមកពីក្រសួងមហាផ្ទៃ ឯកសារមកពីទួលស្លែង មកពីបណ្ណសារដ្ឋានជាតិ កម្រងឯកសារដែលចងក្រងដោយប្រទេសស៊ុយអែដ ជាដើម ។

### ខ) ការឆ្លើយតបនឹងការជំទាស់ជាក់លាក់

លោកតំណាងសហព្រះរាជអាជ្ញាជាតិ វេង ហ៊ត់ បានបដិសេធការលើកឡើងរបស់លោក ម៉ៃឃើល ខាណាវ៉ាស់ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី ដែលបានអះអាងថាព្រះរាជអាជ្ញាកំពុងតែព្យាយាម "លួចបញ្ចូល" ឯកសារ ។ លោកបានបញ្ជាក់ថា សហព្រះរាជអាជ្ញាមិនបាន "លួចបញ្ចូល" ភស្តុតាងនៅចំពោះមុខតុលាការទេ តែព្រះរាជអាជ្ញាបានស្នើមើលឯកសារទាំងអស់តាមរយៈបទដ្ឋាននៃការបញ្ចូលភស្តុតាងរបស់អង្គជំនុំជម្រះ ។



សិស្សានុសិស្សចាកចេញពីបន្ទប់សវនាការ

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាជាតិបានបញ្ចប់ការឆ្លើយតប តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តឆ្លើយតបនឹងការជំទាស់របស់មេធាវីការពារក្តីទាំងបីក្រុម ។ ឆ្លើយតបនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី អៀង សារី នួន ជា និង ខៀវ សំផន ដែលអះអាងថា ឯកសារភាគច្រើនដែលដាក់ដោយសហព្រះរាជអាជ្ញាមិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃសវនាការដំណាក់កាលដំបូង ។ លោក ថារីក អាប់ឌុលហាក់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ឯកសារដែលសហព្រះរាជអាជ្ញាបានបញ្ចូលទៅក្នុងបញ្ជីឯកសារភស្តុតាង គឺពាក់ព័ន្ធនឹងអង្គ

ហេតុដែលក្រឡាបញ្ជីបានអាននៅពេលចាប់ផ្ដើមសវនាការថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១២ ។ ឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដី នួន ជា ទាក់ទងនឹងបញ្ហាការដាក់ឯកសារមុនពេលអង្គជំនុំជម្រះសាលាដំបូងចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី និងការទទួលយកឯកសារដែលមិនជាប់ពាក់ព័ន្ធនឹងសវនាការ លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានអះអាងថា ការបំបែកកិច្ចដំណើរការនីតិវិធីមិនមែនជាការកម្រិតនៃការដាក់ឯកសារនោះទេ ។ ប៉ុន្តែជាការធ្វើកិច្ចដំណើរការនីតិវិធីអាចធ្វើឡើងទៅតាមលំដាប់លំដោយ និងដើម្បីបំបែកឲ្យទៅជាវគ្គតូចៗងាយស្រួលក្នុងការគ្រប់គ្រង និងអាចពិនិត្យដោយលម្អិតលើបទចោទនីមួយៗ ដោយយោងទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ។ នៅក្នុងដីកានេះមិនបានហាមឃាត់ការដាក់បញ្ចូលបទចោទប្រកាន់ថ្មីនោះទេ ដូច្នេះសហព្រះរាជអាជ្ញាអាចដាក់បញ្ចូលឯកសារដែលទាក់ទងនឹងទីតាំងនៃបទល្មើសបន្ថែមជូនអង្គជំនុំជម្រះបាន ។ ទាក់ទងនឹងការដាក់បញ្ជីឯកសារនៅមុនពេលអង្គជំនុំជម្រះចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះក៏បានជូនដំណឹងឲ្យភាគីធ្វើការកែប្រែបញ្ជីឯកសាររបស់ខ្លួនរួចមកហើយដែរ ។

លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានអះអាងថា អ្វីដែលមេធាវីកំពុងធ្វើគឺជាការចងដៃរបស់សហព្រះរាជអាជ្ញាមិនឲ្យបង្ហាញពីឯកសារនានាទាក់ទងនឹងឧក្រិដ្ឋកម្មរបស់ជនជាប់ចោទចំពោះសហឧក្រិដ្ឋកម្មរួមដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ ។

លោកបានបន្តលើកឡើងទាក់ទងនឹងការបង្ហាញដោយសហភាតារបស់ខ្លួន ចំពោះបញ្ហាឯកសារដើម, ឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដីកាបញ្ជូនរឿងឲ្យស៊ើបសួរជំនួស, ឯកសារបណ្ណសារដ្ឋានជាតិ និងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា សុទ្ធសឹងជាឯកសារដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ។ នៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក៏មានចែងដូចគ្នានឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ទាក់ទងនឹងការទទួលយកភស្តុតាង ដោយចែងថាអង្គជំនុំជម្រះអាចទទួលយកឯកសារភស្តុតាងក្នុងករណីដែលឯកសារនោះអាចបង្ហាញភាពគួរឲ្យទុកចិត្តបាន ។

លោកតំណាងសហព្រះរាជអាជ្ញា បានលើកឡើងពីយុត្តិសាស្ត្រអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលបានកំណត់យ៉ាងច្បាស់អំពីការទទួលយកចម្លើយរបស់សាក្សី ។ លោកបានអះអាងថា មានឯកសារជាច្រើនអាចទទួលយកបាន ដោយមិនចាំបាច់កោះអញ្ជើញសាក្សីឲ្យចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ ព្រោះសហព្រះរាជអាជ្ញាបានបង្ហាញពីភាពស៊ីចង្វាក់គ្នានៃឯកសារទាំងអស់នោះរួចទៅហើយ ដូចជាឯកសារសារព័ត៌មានជាដើម ។ ឆ្លើយតបចំពោះសំណើសុំរបស់ក្រុមមេធាវីការពារក្ដី ចំពោះការកោះហៅអ្នកជំនាញ និងអ្នកសរសេរអត្ថបទមកធ្វើការសាកសួរនៅក្នុងសវនការ លោក ថារីក បានអះអាងថា ប្រសិនបើមានការកោះហៅអ្នកជំនាញ និងអ្នកនិពន្ធទាំងអស់ទៅតាមការស្នើសុំរបស់ក្រុមមេធាវីការពារក្ដី អង្គជំនុំជម្រះនឹងត្រូវចំណាយពេលវេលាយ៉ាងយូរដើម្បីអនុវត្តកិច្ចដំណើរការនីតិវិធី និងចេញសេចក្ដីសម្រេច ។ បន្ទាប់មកលោក ថារីក អាប់ឌុលហាក់ បានប្រគល់វេទិកាជូនសហភាតារបស់ខ្លួន គឺលោក វ៉ាំងសង់ វ៉ាយ ដេស្មាឯល ដើម្បីបន្តធ្វើការឆ្លើយតបចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្ដីទាំងបីក្រុម ។

មុនពេលចាប់ផ្ដើមធ្វើការឆ្លើយតបចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្ដីទាំងបីក្រុម លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដេស្មាឯល បានជម្រាបជូនអង្គជំនុំជម្រះថា លោកនឹងឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដីទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A14 A20 និង A17 ។

ឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដីពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A14 លោកតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ថា ក្រុមមេធាវីការពារក្ដីបានលើកឡើងជាច្រើនលើក ពាក់ព័ន្ធនឹងបញ្ហាការបញ្ជូនរឿងឲ្យស៊ើបសួរជំនួស ។ ត្រង់ចំណុចនេះ លោកបានអះអាងថា អ្នកដែលសហចៅក្រមស៊ើបអង្កេតបានចាត់ឲ្យធ្វើការស៊ើបសួរជំនួស គឺសុទ្ធតែជាអ្នកដែលមានជំនាញនិងវិជ្ជាជីវៈច្បាស់លាស់ ហើយថែមទាំងបានធ្វើ

សម្បថរួចរាល់ថែមទៀតផង ។ លោកក៏បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការព្រមានចំពោះក្រុមមេធាវីការពារក្តីរបស់ នួន ជា ដែលបានលើកយកឈ្មោះសាក្សីមកបង្ហាញនៅក្នុងសវនាការ ។ បន្ទាប់មកលោកបានធ្វើការបង្ហាញពីភាពត្រឹមត្រូវនៃរូបថតទាក់ទងនឹងអគារនិងទីកន្លែងផ្សេងៗដែលមានភាពច្បាស់លាស់ និងបង្ហាញពីទីតាំងនៃកន្លែងធ្វើការនៃរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអះអាងថា គឺមានភាពជាប់ពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង ព្រោះវាមានបង្ហាញទាំងរចនាសម្ព័ន្ធនៃក្រសួងការបរទេស ទាំងតួនាទីនិងការទទួលខុសត្រូវរបស់ជនជាប់ចោទ អៀង សារី ។ ឆ្លើយតបនឹងសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលស្នើឲ្យកោះអញ្ជើញសាក្សីចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះលោកតំណាងសហព្រះរាជអាជ្ញាបានអះអាងថា ត្រូវរង់ចាំមើលលើឯកសាររបាយការណ៍សួរយកចម្លើយជាមុនសិន ថាតើអង្គជំនុំជម្រះអាចទទួលយកឯកសារទាំងនោះបានដែរឬយ៉ាងណា ។

ឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី និង ខៀវ សំផន ទាក់ទងនឹងខបសម្ព័ន្ធ A20 ដែលបានចោទប្រកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថាមានភាពលម្អៀង លោក ដេស្មាឯល បានបញ្ជាក់ថា នៅពេលសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃ១០ ខែមករា ឆ្នាំ២០១២ កន្លងទៅ មេធាវីការពារក្តី អៀង សារី ក៏បានប្រើប្រាស់ឯកសាររបស់សហចៅក្រមស៊ើបអង្កេតដែរ ។ ដូច្នេះការសម្រេចទទួលយក ឬមិនទទួលយកឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះដោយពិនិត្យមើលលើភាពពាក់ព័ន្ធរបស់វា ។

ទាក់ទងនឹងឯកសារនៃខបសម្ព័ន្ធ A17 ដែលជាឯកសារទំនាក់ទំនងអន្តរជាតិ លោកតំណាងសហព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារដែលក្រុមមេធាវីការពារក្តីបានជំទាស់គឺធ្លាប់ត្រូវបានធ្វើការដេញដោលរួចហើយកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ។ លោកបានបន្តថា ការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះយថាភាពនៃឯកសារទាំងអស់នោះ គឺជាការមិនសមហេតុផលនោះទេ ព្រោះឯកសារទាំងនោះមានការបញ្ជាក់ត្រឹមត្រូវពីបណ្ណសារដ្ឋាននៃក្រសួងការបរទេសរបស់ប្រទេសបារាំង ។ លោកតំណាងសហព្រះរាជអាជ្ញាក៏បានលើកឡើងពីឯកសារដែលទទួលបានក្រសួងការបរទេសនៃប្រទេសបារាំង ដែលមួយចំនួននៃឯកសារទាំងនោះក៏មាននៅក្នុងបញ្ជីឯកសាររបស់ជនជាប់ចោទ ខៀវ សំផន និងស្នើដោយក្រុមមេធាវីខ្លួនឯងផងដែរ ។ ដូច្នេះ ឯកសារភាគច្រើននៃខបសម្ព័ន្ធ A17 គឺអាចទទួលយកបាន ។ លោកបានបន្ថែមថា សវនាការនេះគឺពុំមែននិយាយពីយថាភាពនៃឯកសារនោះទេ ប៉ុន្តែគេនិយាយពីតម្លៃនៃឯកសារ ។

ដើម្បីបង្ហាញពីភាពជាប់ពាក់ព័ន្ធ និងភាពស៊ីចង្វាក់គ្នានៃឯកសារទំនាក់ទំនងអន្តរជាតិទាំងអស់នោះ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តលើកឡើងពីប្រភពឯកសារទូរលេខនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនិយាយពីការធ្វើដំណើររបស់ថ្នាក់ដឹកនាំនៃរបបនេះទៅកាន់ប្រទេសនៅតំបន់អឺរ៉ុប និងការវិលត្រឡប់មកប្រទេសចិនវិញ ។ មានឯកសារមួយចំនួនទៀតក៏បានលើកឡើងទាក់ទងនឹងដំណើរទស្សនកិច្ចរបស់ជនជាប់ចោទ ខៀវ សំផន នៅប្រទេសរូម៉ានី និងយូហ្គោស្លាវី ជាដើម ។ បន្ទាប់មកលោកបានលើកយកឯកសារទូរលេខរបស់ស្ថានកុងស៊ុលប្រទេសបារាំង ទាក់ទងនឹងការចាប់ខ្លួនរបស់ព្រះអង្គម្ចាស់ សិរិមតៈ នៅក្នុងស្ថានទូតបារាំងក្នុងប្រទេសកម្ពុជា ហើយដំណឹងនេះក៏ត្រូវបានចុះផ្សាយនៅក្នុងអត្ថបទសារព័ត៌មានជាច្រើនទៀត ។

ទាក់ទងនឹងជនជាប់ចោទ អៀង សារី លោកតំណាងសហព្រះរាជអាជ្ញាបានអះអាងថា នៅក្នុងកាសែត ដឹ វ៉ាស៊ីនតោនប៉ុស្តិ៍ (The Washington Post) បានចុះផ្សាយអំពីការដកស្រង់សម្តីរបស់ អៀង សារី ដែលនិយាយថា សិរិមតៈ ត្រូវបានសម្លាប់ចោលភ្លាមៗបន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានរំដោះ ។ រីឯឯកសារមួយចំនួនទៀតទាក់ទងនឹងសារទូរលេខរបស់ក្រសួងការបរទេសបារាំង ដែលចុះផ្សាយពីដំណើរទស្សនកិច្ចរបស់ អៀង សារី នៅឯបរទេស ។ លោក ដេស្មាឯល ក៏បានលើកឡើងទាក់ទងនឹងអត្ថបទរបស់ប៉ុស្តិ៍ទូរទស្សន៍ និងវិទ្យុ ប៊ី.ប៊ី.ស៊ី (B.B.C) និងបណ្តាញផ្សាយព័ត៌មានផ្សេងៗទៀតដែរ ។ លោកបានបញ្ជាក់ថា ចំពោះយថាភាពនៃឯកសារទាំងអស់នេះ គឺសុទ្ធតែជាឯកសារផ្លូវការទាំងអស់ ។ បន្ទាប់ មកលោកបានលើកឡើងពីឯកសាររបស់សហរដ្ឋអាមេរិក និងកាសែត ដឹ ញូវយ៉កថែម (The NewYork Times) ដែលមាន

ចុះផ្សាយទាក់ទងនឹងដំណើរទស្សនកិច្ចរបស់ក្រុមមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាដំណើរទស្សនកិច្ចរបស់ អៀង សារី សារិន ឆាក និងជួន ប្រសិទ្ធិ នៅទីក្រុងលីម៉ា ប្រទេសប៉េរូ ជាដើម ។

លោកតំណាងសហព្រះរាជអាជ្ញា ដេស្មាឯល បានបញ្ជាក់ថា នៅក្នុងខបសម្ព័ន្ធ A17 ដែលមានឯកសារចំនួន៧០ ចេញមកពីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ៦៨ឯកសារជារបស់សហរដ្ឋអាមេរិក ៤ឯកសារបានមកពីអង្គការលើកលែងទោសអន្តរជាតិ និង២ឯកសារទៀត ចេញមកពីអង្គការសហប្រជាជាតិដែលទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន ។ ព្រមទាំងមានឯកសារ៣ទៀតចេញពីក្រសួងការបរទេសវៀតណាមទាក់ទងនឹងប្រវត្តិទំនាក់ទំនង និងជម្លោះរវាងកម្ពុជា និងវៀតណាម ។ លោកបានអះអាងថា ការលើកឡើងរបស់ក្រុមមេធាវីការពារក្តីដែលថាឯកសារទាំងនេះមិនមានយថាភាព គឺពិបាកនឹងទទួលយកណាស់ ដោយសារឯកសារភាគច្រើននៃខបសម្ព័ន្ធនេះ គឺត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿង០០១រួចហើយ ។ បន្ទាប់មកលោក ដេស្មាឯល បានប្រគល់វេទិកាទៅសហភាគារបស់ខ្លួនទាក់ទងនឹងខបសម្ព័ន្ធ A8 ដែលជាសេចក្តីរាយការណ៍ផ្សេងៗទាក់ទងនឹងស្រុកត្រាំកក់ ។

ឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A8 លោកសហព្រះរាជអាជ្ញារងជាតិ ច័ន្ទ តារាវស្មី បានលើកឡើងពីគោលការណ៍មួយក្រឡេកភ្នែក ដើម្បីធ្វើការឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តី ។ លោកបានលើកឡើងថា យថាភាពនៃឯកសារ គឺយោងទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះផ្ទាល់តែម្តង ។ រីឯភាពជឿទុកចិត្តបាននៃឯកសារ គឺមានចរិតលក្ខណៈទាំងខាងក្នុង និងខាងក្រៅ ។ លោកបានបញ្ជាក់ថា នៅក្នុងខបសម្ព័ន្ធ A8 មានឯកសារចំនួន ៥៨ ដែលត្រូវបានសម្រិតសម្រាំងយ៉ាងល្អិតល្អន់ពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង ។ ឯកសារទាំងនេះបានបង្ហាញពីរបាយការណ៍នានាដែលសហករណ៍ និងស្រុក ផ្ញើទៅមន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្នុងតំបន់១០៥ និងជាឯកសារតែមួយគត់ដែលមានការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរនៅក្នុងតំបន់តែមួយ ។ ការប្រាស្រ័យទាក់ទងនេះ គឺស្របទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយមានការជាប់ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងការប្រាស្រ័យទាក់ទងគ្នា ។

ឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីដែលទាមទារឯកសារដើម លោកសហព្រះរាជអាជ្ញារង តារាវស្មី បានរំឭកពីការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ និងការលើកឡើងរបស់ការិយាល័យរបស់ចៅក្រមស៊ើបអង្កេត ដែលបញ្ជាក់ថា ឯកសារដើមត្រូវបានលោក ឆាំង យុ ទទួលបានពីលោក ស៊ូ ភិរិន្ទ ដើម្បីយកមកថតចម្លង ហើយបន្ទាប់មកលោកបានប្រគល់ទៅលោក ស៊ូ ភិរិន្ទ វិញ ។ ក្រោយមក ឯកសារដើមនោះត្រូវបានលោក ស៊ូ ភិរិន្ទ អះអាងថា ឯកសារដើមទាំងនោះបានបាត់បង់អស់ទៅហើយ ។ សហព្រះរាជអាជ្ញាទទួលស្គាល់ថា ខ្លួនពិតជាមិនមានឯកសារដើមនោះទេ ប៉ុន្តែអង្គជំនុំជម្រះក៏មិនបានតម្រូវឲ្យសហព្រះរាជអាជ្ញាត្រូវតែបង្ហាញឯកសារដើមដែរ ។ លោក តារាវស្មី បានលើកឡើងពីឯកសារមួយចំនួនទៀត និងបញ្ជីឈ្មោះប្រជាជនខ្មែរក្រោមដែលត្រូវបានចាប់ខ្លួន និងកម្ទេចដោយមន្ទីរក្រាំងតាចាន់ ដែលព្រះរាជអាជ្ញាមានចេតនាបង្ហាញថា ឯកសារដែលខ្លួនបានដាក់ពិតជាមានការជាប់ទាក់ទងនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ ។ លោកបានអះអាងថា ឯកសារទាំងនោះ ពិតជាមានភាពស៊ីចង្វាក់គ្នាទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានដាក់ចេញ ដែលតម្រូវឲ្យកម្ទេចខ្មែរក្រោម និងទាហានរបស់របបសាធារណរដ្ឋខ្មែរ ។ ឯកសារភាគច្រើននៅក្នុងខបសម្ព័ន្ធ A8 គឺមានរបាយការណ៍ចាប់ខ្លួនទាហានរបបសាធារណរដ្ឋខ្មែរ ការបញ្ជាឲ្យចាប់ខ្លួន និងចម្លើយសារភាពរបស់ទាហានរបបសាធារណរដ្ឋខ្មែរនៅឃុំក្រាំងតាចាន់ និងស្រុក១០៥ ថែមទាំងមានរបាយការណ៍ដែលបញ្ជាឲ្យចាប់ខ្លួនទាហានវៀតណាមថែមទៀត ។ ជាទូទៅឯកសារទាំងនោះ គឺសរសេរដោយដៃ និងមានភាពស្រដៀងគ្នាដោយសារធនធានមានកម្រិតរបស់គម្មាភិបាលនៅទីនោះ ។ ម្យ៉ាងវិញទៀត ពាក្យដែល ប្រើប្រាស់នៅក្នុងអត្ថបទទាំងអស់នោះ គឺជាពាក្យរបស់របបកម្ពុជាប្រជាធិបតេយ្យ ដូចជាពាក្យមិត្ត មិត្តបង អង្គការ យួន កម្ទេច ជាដើម ។

លោកបានសន្និដ្ឋានថា ឯកសារទាំង៥៧ ដែលសហព្រះរាជអាជ្ញាបានលើកឡើងយកមកបង្ហាញ គឺមានភាពជាប់ទាក់ទងនឹង

អង្គហេតុដំណាក់កាលដំបូង ទោះបីជាឯកសារទាំងអស់នោះមិនមានឯកសារដើមក៏ដោយ ក៏ឯកសារទាំងនោះគឺពិតជាអាចទុកចិត្តបាន ។ បន្ទាប់ពីលោកសហព្រះរាជអាជ្ញា ច័ន្ទ តារាវស្មី បានបញ្ចប់សេចក្តីសន្និដ្ឋានតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A8 លោក ដេស្នាឯល បានបន្តធ្វើការឆ្លើយតបជាថ្មីពាក់ព័ន្ធនឹងឯកសារទំនាក់ទំនងអន្តរជាតិ ។

លោក ដេស្នាឯល បានលើកឡើងពីបណ្តាញសារព័ត៌មានអន្តរជាតិជាច្រើនដែលបានចុះផ្សាយទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារនោះក៏បានចុះទៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយដែរ មានតម្រុយនៃភាពអាចគួរឲ្យជឿជាក់បាន ។ សហព្រះរាជអាជ្ញាធ្លាប់បានលើកឡើងពីបញ្ហាសារព័ត៌មាននៅក្នុងសវនាការកាលពីខែកុម្ភៈ រួចមកហើយទាក់ទងនឹងឧបសម្ព័ន្ធ A1 និងបានយោងទៅលើប្រតិចារិកនៃការលើកឡើងនៅក្នុងសវនាការនាពេលនោះ ។ ឯកសារទាំងអស់នោះមានជាប់ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ និងតួនាទីរបស់ជនជាប់ចោទនៅមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងការប្រាស្រ័យទាក់ទងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មានអត្ថបទសារព័ត៌មានមួយចំនួនបានចុះផ្សាយពីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ លោកបានបន្តទៀតថា នៅពេលដែលរបបនេះបានដឹងឮពីការចុះផ្សាយទាំងនោះ ហើយខ្លួននៅតែបន្តប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាសហឧក្រិដ្ឋកម្មរួមដដែល បើយោងតាមអ្នកដែលបានភៀសខ្លួនទៅក្រៅប្រទេស ។ ចំពោះការទទួលបាននៃឯកសារទាំងអស់នោះ លោកតំណាងសហព្រះរាជអាជ្ញាបានអះអាងថា ក្រុមមេធាវីការពារក្តីក៏បានប្រើប្រាស់ឯកសារទាំងនោះដែរ ។ ដូច្នេះឯកសារទាំងនោះ គឺពិតជាអាចគួរឲ្យជឿជាក់បាន ។ រីឯការកោះហៅអ្នកនិពន្ធអត្ថបទទាំងនោះមកផ្តល់សក្ខីកម្ម គឺមិនចាំបាច់នោះទេ ។ ចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ដែលថា អត្ថបទសារព័ត៌មានភាគច្រើនមិនមានដាក់ឈ្មោះអ្នកនិពន្ធនោះ លោកបានឆ្លើយតបថា ទោះបីជាមិនមានឈ្មោះអ្នកនិពន្ធនៅលើអត្ថបទខ្លះក៏ដោយ ប៉ុន្តែអត្ថបទទាំងនោះគឺមានដាក់ពីឈ្មោះស្ថាប័នរបស់ខ្លួន ដូចជាអត្ថបទរបស់កាសែតញូវយ៉កថែមជាដើម ។ ម្យ៉ាងទៀត ព្រឹត្តិការណ៍ដែលមានចុះផ្សាយនៅក្នុងអត្ថបទទាំងនោះ គឺមានភាពស៊ីចង្វាក់គ្នាទៅនឹងការចុះផ្សាយរបស់អត្ថបទសារព័ត៌មានផ្សេងទៀត ដូច្នេះអត្ថបទទាំងនោះពិតជាមានភាពអាចជឿទុកចិត្តបាន ។ ទាក់ទងនឹងការជំទាស់របស់មេធាវី អៀង សារី ចំពោះបណ្តាញផ្សព្វផ្សាយព័ត៌មានបរទេស (F.E.B.I.S) ប៊ី.ប៊ី.ស៊ី, អេហ្វ ដាប៊លយូ ប៊ី (F.W.B) ក្រុមមេធាវីមិនគួរធ្វើការជំទាស់នឹងប្រតិចារិករបស់ ហ្វីប៊ីស ទេ ព្រោះប្រតិចារិកទាំងអស់នោះគឺគ្រាន់តែចម្លងចេញពីប្រព័ន្ធផ្សព្វផ្សាយរបស់របបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាម្នាក់ទៀត គឺលោក ខេល លីសាក់ បានឡើងបន្តការឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី ។ លោកបានបញ្ជាក់ថាមានឧបសម្ព័ន្ធចំនួនប្រាំដែលលោកនឹងធ្វើការឆ្លើយតប ។

ដំបូង លោក ខេល លីសាក់ បានលើកយកឧបសម្ព័ន្ធ A6 ប្រវត្តិរូបនៃអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើការឆ្លើយតប ។ លោកបានជ្រើសរើសយកប្រវត្តិរូបនៃអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ មកពិភាក្សាដោយអះអាងថា ប្រវត្តិរូបប្រភេទនេះ គឺមានភាពងាយស្រួលក្នុងការកំណត់ ដោយសារតែវាមានចំនួនតែមួយទំព័រតែប៉ុណ្ណោះ ។ លោកបានស្នើទៅអង្គជំនុំជម្រះបង្ហាញពីប្រវត្តិរូបមួយរបស់ស្ត្រីម្នាក់ឈ្មោះ ឈូក យ៉ាន នៅលើអេក្រង់កុំព្យូទ័រ ដើម្បីបង្ហាញពីយថាភាពនៃឯកសារនោះ ។ លោកបានបញ្ជាក់ថា ប្រវត្តិរូបនោះគឺសរសេរដោយអង្គលីលេខ បន្ទាប់មកគេសរសេរដោយដៃនៅលើប្រវត្តិរូបនោះ ។ គេរៀបចំប្រវត្តិរូបទាំងអស់នោះដោយមានទម្រង់ដូចៗគ្នា ។ ប្រភេទប្រវត្តិរូបទី២ គឺគេធ្វើមុនពេលដែលគេបញ្ជូនអ្នកទោសទៅធ្វើទារុណកម្មដោយមិនមានការប្រាប់ពីទោសដែលនាំឲ្យគេចាប់ខ្លួនឡើយ ។ ទាក់ទងនឹងការបដិសេធរបស់ក្រុមមេធាវីការពារក្តីចំពោះប្រវត្តិរូបដែលធ្វើឡើងក្រោមការអំពើទារុណកម្មនោះ គឺមិនត្រឹមត្រូវទេ ព្រោះប្រវត្តិរូបទាំងអស់នោះធ្វើឡើងមុនពេលអ្នកទាំងនោះត្រូវបានយកទៅធ្វើទារុណកម្ម ។ ចំណែកឯការប្រើប្រាស់ប្រវត្តិរូបទាំងអស់នេះ គឺមិនធ្វើឲ្យប៉ះពាល់ដល់អនុសញ្ញាស្តីពីការទប់ស្កាត់ការធ្វើទារុណកម្មទេ ប៉ុន្តែប្រើប្រាស់ដើម្បីដឹងពីរចនាសម្ព័ន្ធរដ្ឋបាល

របស់របបកម្ពុជាប្រជាធិបតេយ្យ ដោយសារមានការចាប់ខ្លួនកម្មាភិបាលពីភូមិភាគ តំបន់ និងទីកន្លែងផ្សេងទៀត ដោយតម្រូវឲ្យធ្វើប្រវត្តិរូប ដូច្នេះគេអាចដឹងបានពីរចនាសម្ព័ន្ធនៅពេលនោះ ។ ចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្តីដែលអះអាងថា ឯកសារទាក់ទងនឹង អៀង ធីរិទ្ធ ពុំមានជាប់ទាក់ទងនឹងសវនាការក្នុងដំណាក់កាលដំបូង លោកបានឆ្លើយតបថា ការប្រើប្រាស់ឯកសាររបស់ អៀង ធីរិទ្ធ គឺដើម្បីដឹងពីការបង្កើតក្រសួង និងរចនាសម្ព័ន្ធនៅក្នុងរបបនោះ ដូចជាក្រសួងសង្គមកិច្ចដែលគ្រប់គ្រងដោយ អៀង ធីរិទ្ធ ជាដើម ។ រីឯការលើកឡើងរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលថាសហព្រះរាជអាជ្ញាបានបំពានវិជ្ជាជីវៈ គឺជាការមិនត្រឹមត្រូវទេ ។ លោកបានបន្តថា ក្រុមមេធាវី អៀង សារី មិនបានពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយអំពីឯកសាររបស់សហព្រះរាជអាជ្ញា ប៉ុន្តែបែរជាព្យាយាមមើលបញ្ឆឹងឯកសាររបស់សហព្រះរាជអាជ្ញាដើម្បីដាក់កំហុសទៅវិញ ។

ចំពោះឯកសារទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្ត និងប្រវត្តិរូបរបស់កម្មាភិបាល ដែលរបបកម្ពុជាប្រជាធិបតេយ្យតម្រូវឲ្យកម្មាភិបាលទាំងអស់ត្រូវតែធ្វើប្រវត្តិរូបរបស់ខ្លួនទៅតាមបទដ្ឋាន ។ លោកបានបដិសេធនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលបានអះអាងថា ការផ្តល់សក្ខីកម្មរបស់សាក្សីមួយរូបដែលធ្វើឡើងទាក់ទងនឹងប្រវត្តិរូប គឺមិនទាន់មានភាពគ្រប់គ្រាន់ ដោយលោកបញ្ជាក់ថា ការផ្តល់សក្ខីកម្មរបស់សាក្សីរូបនោះគឺមានភាពច្បាស់លាស់ ដោយសារចម្លើយនោះមានភាពស៊ីចង្វាក់គ្នានឹងការធ្វើប្រវត្តិរូបទាំងអស់នោះ ។ ភាពជាប់ពាក់ព័ន្ធទៅនឹងប្រវត្តិរូបគឺបើពិនិត្យមើលលើទម្រង់បែបបទនៃប្រវត្តិរូបទាំងអស់នោះ ឃើញថា សំណួរដែលសួរគឺធ្វើទៅតាមដំណាក់កាលដោយចាប់ផ្តើមពីតួនាទីរបស់ម្ចាស់ប្រវត្តិរូបនៅមុនពេលចូលបដិវត្ត ដើម្បីកំណត់អំពីអត្តសញ្ញាណរបស់សមាជិកបក្ស និងមិត្តភិក្ត ។ ប្រភេទប្រវត្តិរូបទី៣ គឺប្រវត្តិរូបដែលធ្វើនៅក្នុងក្រសួងការបរទេសនៃរបប



បន្ទប់អ្នកសារព័ត៌មាន

កម្ពុជាប្រជាធិបតេយ្យ ដែលជាប្រវត្តិរូបមានលក្ខណៈរៀបរាប់ច្រើនទំព័រ ។ លោកបានលើកឡើងពីការផ្តល់សក្ខីកម្មរបស់សាក្សីមួយរូប គឺលោក ឡុង នរិន្ទ នៅអំឡុងពេលសវនាការពេលកន្លងទៅ ដោយបញ្ជាក់ថា ការលើកឡើងនោះគឺគ្រប់គ្រាន់ហើយដើម្បីបញ្ជាក់ថាឯកសារទាំងអស់នោះពិតជាត្រូវបានធ្វើឡើងដោយកម្មាភិបាលនៃក្រសួងនោះផ្ទាល់ ។ដូច្នេះឯកសារទាំងអស់នោះពិតជាបានបង្ហាញយ៉ាងត្រឹមត្រូវអំពីតួនាទីរបស់ អៀង សារី ក្នុងការអប់រំកម្មាភិបាលខ្មែរក្រហម ការតម្រូវឲ្យធ្វើប្រវត្តិរូប និងការដឹងពីតួនាទីរបស់កម្មាភិបាលនៅក្នុងក្រសួងការបរទេស ។ លោកបានបន្តថា ការស្នើសុំរបស់ក្រុមមេធាវីការពារក្តី ដែលសុំឲ្យមានកោះហៅសាក្សីមកធ្វើការបញ្ជាក់នៅក្នុងសវនាការនោះ គឺជាការពុំចាំបាច់ ។ ប៉ុន្តែអ្វីដែលជាការចាំបាច់នោះ គឺការវាយតម្លៃរបស់អង្គជំនុំជម្រះក្នុងការទទួលយកឯកសារទាំងអស់នោះ ។ ចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន អំពីយថាភាពនៃឯកសារ និងខ្សែសង្វាក់នៃការរក្សាទុកឯកសារ លោកតំណាងសហព្រះរាជអាជ្ញា លីសាក់ បានលើកឡើងថា អង្គជំនុំជម្រះបានបញ្ជាក់ហើយអំពីភាពទទួលយកបាននៃឯកសារមួយក្រឡេកភ្នែក ។

ចំពោះឧបសម្ព័ន្ធ A9 ដែលក្រុមមេធាវី អៀង សារី បានអះអាងថា ជាឯកសារពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ត្រូវបានលោកសហព្រះរាជអាជ្ញាឆ្លើយតបថា ឯកសារទាំងអស់នេះគឺជាប់ពាក់ព័ន្ធនឹងការចាប់បញ្ជូនកម្មាភិបាលបួននាក់នៃក្រសួងសង្គមកិច្ចទៅមន្ទីស-២១ និងរចនាសម្ព័ន្ធរដ្ឋបាលចំពោះការបង្កើតក្រសួងនានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែកឯបញ្ជីអ្នកទោសនៅមន្ទីរស-២១ គឺបានដាក់តាំងពីមុនពេលចេញដីការបំបែកសំណុំរឿង បញ្ជីនេះមានភាពជាប់ពាក់ព័ន្ធនឹងបរិបទប្រវត្តិរូបដើម្បីកំណត់ទៅដល់អត្តសញ្ញាណរបស់អង្គការ ឬអង្គភាពផ្សេងៗគ្នា ហើយថាតើបុគ្គលនីមួយៗដែលមកពីអង្គភាពនោះជានរណា ។ ចំពោះកំណត់ត្រារបស់អ្នកទោសនៅមន្ទីរស-២១ ខ្ញុំក៏បានបញ្ជាក់ដែរអំពីគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកំណត់ទៅដល់មន្ត្រីនិងទាហានរបស់របប លន់ នល់ ។

ទាក់ទងនឹងខ្សែអាត់សំឡេង និងវីដេអូ លោកតំណាងសហព្រះរាជអាជ្ញា ខេល លីសាក់ បានផ្តល់ភាពច្បាស់លាស់ថា តុលាការធ្លាប់បានសម្រេចរួចហើយទាក់ទងនឹងបញ្ហានេះ គឺមិនចាំបាច់កោះហៅអ្នកធ្វើសម្ភាសន៍មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះឡើយ ។ លោកបានលើកឡើងពីឯកសារជាក់លាក់នីមួយៗដែលត្រូវបានជំទាស់ដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ និងបានធ្វើការបញ្ជាក់ពីការសម្រេចទទួលយក ឬមិនទទួលយកគឺស្ថិតនៅលើការពិចារណារបស់អង្គជំនុំជម្រះ ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គជំនុំជម្រះចាក់បញ្ចាំងវីដេអូមួយដែលជាបទសម្ភាសន៍របស់ ខៀវ សំផន ។ លោក លីសាក់ បានលើកឡើងថា សហព្រះរាជអាជ្ញាមិនបានដឹងថាតើនរណាជាអ្នកធ្វើសម្ភាសន៍ជាមួយនឹង ខៀវ សំផន នៅពេលនោះទេ ។ មានតែជនជាប់ចោទ ខៀវ សំផន ខ្លួនឯងទេ ដែលដឹងថាអ្នកណាជាអ្នកសម្ភាសន៍ខ្លួន ។ដូច្នេះប្រសិនបើជនជាប់ចោទខៀវសំផនចង់ធ្វើការបញ្ចេញយោបល់លើបញ្ហានេះ គឺអាចធ្វើបាន ។ ហេតុនេះខ្សែវីដេអូនោះ គឺមានភាពគួរឲ្យជឿជាក់ មិនមែនដូចជាការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ឡើយ ។ លោកបានបញ្ជាក់ថា វត្តមានរបស់ជនជាប់ចោទ ខៀវ សំផន ដែលមាននៅក្នុងខ្សែវីដេអូនោះ គឺជាភស្តុតាងមួយក្រលេកភ្នែក ដែលគួរឲ្យជឿជាក់បានដោយមិនចាំបាច់មានការដេញដោលឡើយ ។

ទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A10 ដែលជាចម្លើយសារភាពនៅមន្ទីរស-២១ លោក លីសាក់ បានបញ្ជាក់ថា គឺមានតម្រុយយថាភាពជាច្រើន ដោយមានស្នាមម្រាមដៃ ចំណារ និងឈ្មោះនៅលើចម្លើយសារភាពទាំងនោះ ។ លោកបានបន្ថែមថា សូម្បីតែ ឌុច ដែលជាប្រធានមន្ទីរស-២១ ក៏ធ្លាប់បានផ្តល់សក្ខីកម្មទាក់ទងនឹងបញ្ហានេះ ដោយ ឌុច បានលើកឡើងថានៅលើចម្លើយសារភាពទាំងនោះមានចំណាររបស់ ឌុច ខ្លួនឯង ចំណាររបស់ សុន សេន និងចំណាររបស់អ្នកសួរចម្លើយផ្សេងទៀត ។ ដូច្នេះមិនមានបញ្ហាចំពោះយថាភាពនៃឯកសារចម្លើយសារភាពទាំងអស់នោះឡើយ ។ ចំពោះការលើកឡើងទាក់ទងនឹងការរំលោភទៅលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មរបស់ក្រុមមេធាវី ការពារក្តី ដោយចោទប្រកាន់សហព្រះរាជអាជ្ញាប្រើប្រាស់ចម្លើយសារភាព ដែលទទួលបានដោយសារការធ្វើទារុណកម្ម ត្រូវបានតំណាងសហព្រះរាជអាជ្ញាឆ្លើយតបថា បញ្ហា

នេះមិនមែនជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទនោះទេ ទោះបីជាវាផ្ទុយទៅនឹងគោលបំណងនៃអនុសញ្ញានោះក៏ដោយ ។ ការប្រើប្រាស់ឯកសារចម្លើយសារភាពនៅចំពោះមុខអង្គជំនុំជម្រះនេះអាចធ្វើបាន ដោយសារអ្វីដែលគេត្រូវដឹង គឺពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារមិនពាក់ព័ន្ធនឹងការទទួលយកឯកសារនោះទេ ។ ដូចនេះវាមិនបានរំលោភលើអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មឡើយ ។ រីឯការពាក់ព័ន្ធនៃឯកសារនេះ គឺដោយសារវាបានបង្ហាញពីសិទ្ធិអំណាចរបស់ប្រធានក្រសួង ស្ថាប័ន ប្រធានភូមិភាគ តំបន់ និងស្រុក ហើយទំព័រមុខនៃចម្លើយសារភាព គឺមានចំណារសរសេរដោយដៃរបស់ ឌុច ឬ សុន សេន ដែលសម្រេចថាត្រូវផ្ញើទៅណា ឬបញ្ជូនមកពីខាងណា ។ ឯកសារខ្លះទៀតក៏មានចំណាររបស់ជនជាប់ចោទ នួន ជា និងចំណាររបស់ ឌុច ដែលផ្ញើជូនទៅ នួន ជា និងផ្ញើទៅ អៀង សារី ថែមទៀត ។ ដូច្នេះវាបង្ហាញថានរណាដែលមានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យចាប់ខ្លួនភ្លាមៗ និងនរណាជាអ្នកទទួលខុសត្រូវចំពោះការទទួលបានចម្លើយសារភាពទាំងអស់នោះ ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានអានចំណារដែលធ្វើឡើងដោយ ឌុច នៅលើចម្លើយសារភាព ដើម្បីបញ្ជាក់អំពីសិទ្ធិអំណាចរបស់ជនជាប់ចោទនីមួយៗក្នុងរបបនោះ ។ លោក លីសាក់ បានលើកឡើងពីចម្លើយសារភាពរបស់ ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីនៃក្រសួងឃោសនាការ និងបានអានចម្លើយសារភាពនោះជូនទៅអង្គជំនុំជម្រះពីសម្តីរបស់ ហូ នឹម ដែលបានបដិសេធថា ខ្លួនមិនដែលបានក្បត់បក្សម្តងណាឡើយ ។ ហ៊ូ នឹម បានសរសេរថា៖

*“បង ប៉ុល បងនួន បងវ៉ាន់ បងវ៉ន កម្មាភិបាលខៀវ និងហែម ជាទីគោរព ។ ថ្ងៃនេះជាថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ខ្ញុំកំពុងតែរវល់រៀបចំការផ្សព្វផ្សាយដើម្បីរំឭកអំពីបុណ្យខួបដ៏មហាអស្ចារ្យ ១៧ មេសា ។ កម្មាភិបាល ប៉ិន (ប្រធានមន្ទីរស-៧១) បានហៅខ្ញុំតាមទូរស័ព្ទ ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលទីមួយខ្ញុំមិនជឿថាក្រុមយោធាដែលដឹកនាំដោយប៉េងនេះ ខ្ញុំគ្មានទោសពៃរ៍អីទេ ខ្ញុំមិនបានក្បត់អង្គការទាល់តែសោះ ។ ខ្ញុំបានស្មោះអង្គការជាមួយអង្គការបំផុត ។ ខ្ញុំគិតថាប្រហែលជាមានខ្មាំងខ្លះបានឆ្លើយទម្លាក់កំហុសមកលើខ្ញុំ ។ ខ្ញុំសូមបញ្ជាក់ជូនបក្សថា ខ្ញុំមិនដែលក្បត់បក្សម្តងណាទាល់តែសោះ ។ ខ្ញុំមិនដែលពាក់ព័ន្ធជាមួយសេអ៊ីអា ភ្នាក់ងារវៀតណាមស៊ីង៉ុកថាញ់អីនោះទេ» ។*

ទាក់ទងនឹងចម្លើយសារភាពនេះលោកតំណាងសហព្រះរាជអាជ្ញា លីសាក់ បានលើកឡើងថា ការសរសេរនេះ បញ្ជាក់ឲ្យឃើញថា ហ៊ូ នឹម សរសេរលិខិតនេះទៅ ប៉ុល ពត, នួន ជា, អៀង សារី, វ៉ន វ៉េត, សុន សេន និង ខៀវ សំផន ដែលជាមនុស្សដែលគាត់យល់ថាអាចឆ្លើយតប និងទទួលខុសត្រូវចំពោះការចាប់ខ្លួនរបស់គាត់បាន ។ នេះបង្ហាញឲ្យឃើញថាគណៈអចិន្ត្រៃយ៍ និងសមាជិកគណៈមជ្ឈិមទទួលខុសត្រូវផ្នែកសន្តិសុខ ។ លោកតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ថា ឯកសារទាំងអស់នោះ គឺមានការជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ការប្រាស្រ័យទាក់ទងគ្នា និងសិទ្ធិសម្រេចរបស់ស្ថាប័ននានានៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំពោះរបាយការណ៍របស់ហ្វេបបីស គឺមានការស៊ីចង្វាក់គ្នាទៅនឹងការផ្សព្វផ្សាយរបស់បណ្តាញសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យដែលចុះផ្សាយពីចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ដោយសារមានការអានចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាមទាំងអស់នោះដោយបុគ្គលិករបស់មន្ទីរស-២១ និងមានការត្រួតពិនិត្យដោយប្រុងប្រយ័ត្នពីមេដឹកនាំនៃមន្ទីរស-២១នោះ ហើយត្រូវបានហ្វេបបីស ចាប់បានតាមរយៈបណ្តាញផ្សព្វផ្សាយនោះ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តលើកឧទាហរណ៍ទាក់ទងនឹងការផ្សព្វផ្សាយរបស់បណ្តាញផ្សព្វផ្សាយរបស់ប្រទេសអង់គ្លេស ដែលដកស្រង់ចេញពីវិទ្យុកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើការផ្សព្វផ្សាយពីចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ។ ដូច្នេះឃើញថាអត្ថបទដែលទទួលបានពីបណ្តាញផ្សព្វផ្សាយរបស់ប្រទេសអង់គ្លេសនេះមានភាពស៊ីចង្វាក់គ្នាទៅនឹងចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាមដែលមាននៅក្នុងមន្ទីរស-២១ ។

## ៣) ការឆ្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានឆ្លើយតបទៅនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា ទាក់ទងនឹងឯកសារថតចម្លង និងផ្ទៀងផ្ទាត់ឯកសារទាំងនោះជាមួយឯកសារដើម ។ លោកបានធ្វើការឆ្លើយ

តបដោយផ្តោតទៅលើឯកសារដែលផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ណសារដ្ឋានជាតិថា វាគឺជាការតម្រូវធ្ងន់ធ្ងរដែលមិនអាចធ្វើបាន ។ លោកបានបន្តទៀតថា សម្រាប់យថាភាពនៃឯកសារទាំងអស់នោះ គឺមានសាក្សីពីររូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានមកផ្តល់សក្ខីកម្មរួចហើយ ។ រីឯការលើកឡើងដែលថា ឌុច គ្រាន់តែមានឋានៈជាប្រធាន គុកមួយរូបហេតុអ្វីបានជា ឌុច ដឹងពីរឿងរ៉ាវរបស់គណៈអចិន្ត្រៃយ៍ច្រើនម្ល៉េះ លោកមេធាវីនាំមុខជាតិបានលើកឡើងថា វាមិនមែនជាបញ្ហានោះទេ ចំពោះឋានៈរបស់ ឌុច ប៉ុន្តែត្រូវមើលថាតើសម្តីរបស់ ឌុច មានភាពពិតប្រាកដដែរឬទេ ។ បន្ថែមពីលើនេះ ឌុច ក៏បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០១រួចហើយ ព្រមទាំងបានចេញសេចក្តីសម្រេចស្ថាពរថែមទៀត ដូច្នេះមិនគួរបដិសេធសក្ខីកម្មរបស់ ឌុច ឡើយ ។ ទាក់ទងនឹងបញ្ហាសក្ខីកម្មរបស់បុគ្គលិកនៃការិយាល័យសហព្រះរាជអាជ្ញាដែលមានរហ័សនាម TCW ៧២៩ ដែលក្រុមមេធាវីការពារក្តីបានលើកឡើងថាឯកសារដែលរៀបចំដោយបុគ្គលរូបនេះ គឺជាឯកសារចោទប្រកាន់ហើយ ដែលធ្វើដោយសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដែលមានវិមតិសង្ស័យ ហើយមិនអាចយកមកធ្វើឯកសារយថាភូតបានទាល់តែសោះ ។ ត្រង់ចំណុចនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ថាឲ្យតែមានភាពពាក់ព័ន្ធគឺមិនតម្រូវឲ្យមានភាពច្បាស់លាស់ខ្លាំងពេកទេ ។ លោកបានបន្តទៀតថា វិមតិសង្ស័យមិនមែនយកមកប្រើប្រាស់ក្នុងសវនាការដំណាក់កាលនេះទេ គឺយកមកប្រើនៅពេលដែលអង្គជំនុំជម្រះពិចារណាទៅលើភស្តុតាងទាំងឡាយថាតើភស្តុតាងទាំងនោះអាចឲ្យជឿជាក់លើសពីភាពសង្ស័យធម្មតាដែរឬទេ ។ ដូចនេះឯកសារដែលធ្វើដោយបុគ្គលខាងលើ ទោះជាឯកសារថតចម្លងក្តី ឬជាឯកសារស្កេនក្តី គឺពិតជាបញ្ជាក់ថាមានភាពពាក់ព័ន្ធដែលអាចទទួលយកបាន ។ រីឯការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន មេធាវី អង់តា ហ្គីសេ ដែលថាត្រូវតែកោះហៅអ្នកដែលផ្តល់បទសម្ភាសន៍ ឬអ្នកធ្វើសម្ភាសន៍មកផ្តល់សក្ខីកម្មនៅក្នុងសវនាការ គឺជាការមិនត្រឹមត្រូវ ។ គ្រប់ឯកសារមិនមែនតម្រូវឲ្យសាក្សីមកធ្វើសក្ខីកម្មគ្រប់ទាំងអស់ទេ លុះត្រាតែមានភាពចាំបាច់ ឬឯកសារនោះតម្រូវឲ្យបញ្ជាក់បន្ថែមទើបមានការមកបំភ្លឺបន្ថែម ។



(រូបថត : អ.វ.ត.ក)

បន្ទាប់ពីលោកមេធាវីនាំមុខ ពេជ អង្គ លោកស្រីមេធាវីនាំមុខអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ុណូហ្វ បានបន្តឆ្លើយតបទៅក្រុមមេធាវីការពារក្តី ។ លោកស្រីបានលើកឡើងពីវិធាន៨៧(៣) ដែលបានចែងអំពីការដាក់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ដោយអះអាងថា ភាគីទាំងអស់ត្រូវតែគោរពវិធាននេះក្នុងការដាក់ភស្តុតាងរបស់ខ្លួន ។ លោកស្រីមេធាវីក៏បានលើកឡើងពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងការបំបែកនីតិវិធី ដែលលើកឡើងពីគោលនយោបាយទាំងប្រាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលថាគោលនយោបាយផ្សេងទៀតមិនអាចលើកឡើងបានទេក្រៅពីគោលនយោបាយជម្លៀសដោយបង្ខំ ប៉ុន្តែគេអាចលើកយកចំណុចខ្លះៗទៀតបាន ។

លោកស្រីបានធ្វើការជំទាស់ជាពីរសណ្ឋាន ទីមួយ គឺការជំទាស់ដែលមានគោលការណ៍ច្បាប់ជាមូលដ្ឋាន និងទីពីរ គឺការជំទាស់ដែលកំណត់លក្ខខណ្ឌនៃការទទួលយកនៃឯកសារ ។ ឆ្លើយតបទៅនឹងការលើកឡើងទាក់ទងនឹងការប្រើប្រាស់ចម្លើយសារភាពដែលធ្វើឡើងក្រោមការធ្វើទារុណកម្មលោកស្រីមេធាវីបានគាំទ្រចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា ។ លោកស្រីបាន

បញ្ជាក់ថា ការលើកឡើងថា ការិយាល័យសហចៅក្រមស៊ើបអង្កេតមានភាពលម្អៀងនោះ គឺជាការមិនត្រឹមត្រូវទេ ដោយសារសហចៅក្រមស៊ើបអង្កេតបានដាក់ឯកសារដែលពាក់ព័ន្ធចូលទៅក្នុងសំណុំរឿងទាំងអស់ ។ ដូច្នេះសហចៅក្រមស៊ើបអង្កេតមិនមានភាពលម្អៀងឡើយ ។ ចំពោះការជំទាស់ទាក់ទងនឹងបញ្ហាបកប្រែ មេធាវីការពារក្តី គ្រាន់តែលើកឡើងថា មិនអាចយល់បាន ហើយ មេធាវីការពារក្តីក៏ធ្វើការជំទាស់នោះ គឺមិនអាចទទួលបានទេ ព្រោះមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានព្យាយាមស្នើសុំឲ្យមានការបកប្រែឲ្យបានទាន់ពេល ។ ប៉ុន្តែដោយសារឯកសារមានច្រើន ដូច្នេះធ្វើឲ្យវាមានភាពយឺតយ៉ាវ ។ ពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការ ដែលក្រុមមេធាវីការពារក្តីអះអាងថា ទាំងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនជាប់ពាក់ព័ន្ធនឹងសវនាការនាពេលនេះ លោកស្រីមេធាវីបានឆ្លើយតបថា អង្គជំនុំជម្រះធ្លាប់បានលើកឡើងហើយអំពីការពង្រីកវិសាលភាពនៃសវនាការ ហើយអង្គជំនុំជម្រះក៏បានសម្រេចដែលថាគេអាចសួរដេញដោលសាក្សីលើសពីវិសាលភាពនេះបាន ។ ចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលបដិសេធអត្ថបទដែលសរសេរដោយនិស្សិតដែលទើបតែមានអាយុ២២ឆ្នាំ មិនគួរឲ្យទុកចិត្តបាននោះ ។ លោកស្រីបានលើកឡើងថា វាមិនមែនជាបញ្ហានោះទេ ចំពោះអ្នកដែលបានសរសេរអត្ថបទអាយុប៉ុន្មាននោះ ព្រោះនៅក្នុងកាលៈទេសៈខ្លះ អ្នកដែលមានអាយុ២២ឆ្នាំ អាចមានគំនិតដូចជាមនុស្សដែលមានអាយុ៣០ឬ៥០ឆ្នាំក៏ថាបាន ។ ដូច្នេះការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន គឺជាការលើកឡើងដោយមិនមានមូលដ្ឋានច្បាស់លាស់ ។ លោកស្រី បានស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការបដិសេធចោលនូវការជំទាស់របស់ក្រុមមេធាវីការពារក្តីដែលបានធ្វើការជំទាស់ចំពោះឯកសារទាំង១០របស់ខ្លួន ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងដំណាក់កាលនេះ ។

## ៤) ការឆ្លើយតបរបស់ក្រុមមេធាវីទាំងបីក្រុមចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

### ក) ការឆ្លើយតបរបស់ក្រុមមេធាវី នួន ជា

មេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា លោក អេនឌ្រូ អ៊ីនូហ្ស៊ី បានលើកឡើងថា លោកមានចំណុចចំនួនដើម្បីឆ្លើយតបនឹងការលើកឡើងទូទៅរបស់សហព្រះរាជអាជ្ញា ។

ដំបូងគឺទាក់ទងនឹងការវិធាន៨៧នៃវិធានផ្ទៃក្នុងទាក់ទងនឹងការដាក់ឯកសារ និងកម្រាស់នៃឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថា ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះមានចំនួនច្រើនសន្ធឹកសន្ធាប់ដែលមិនអាចពិនិត្យមើលបាន ។

ទាក់ទងនឹងបញ្ហាដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលសហព្រះរាជអាជ្ញាបានលើកឡើង ក្រុមមេធាវីមិនជំទាស់នោះទេ ។ ប៉ុន្តែក្រុមមេធាវីការពារក្តីសុំធ្វើការជំទាស់នឹងការលើកឡើងទាក់ទងនឹងបញ្ហាសហឧក្រិដ្ឋកម្មរួមនៃរបបកម្ពុជាប្រជាធិបតេយ្យដែលសហព្រះរាជអាជ្ញាលើកយកគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យមកបង្ហាញថាជាសហឧក្រិដ្ឋកម្មរួម ។ លោកមេធាវីបានបន្តថា ការគ្រាន់តែយកគោលនយោបាយរបស់របបនេះមកបង្ហាញ ហើយចោទប្រកាន់កូនក្តីរបស់ខ្លួនថាត្រូវតែទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួមនោះគឺមិនគ្រប់គ្រាន់ទេ ចាំបាច់ត្រូវតែមានការបង្ហាញភស្តុតាងឲ្យបានច្បាស់លាស់ ។

ពាក់ព័ន្ធនឹងសកម្មភាព និងតួនាទីរបស់ជនជាប់ចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លោកមេធាវីបានលើកឡើងថា អង្គជំនុំជម្រះត្រូវតែពិនិត្យឲ្យបានដិតដល់បញ្ហាការប្រើប្រាស់ចម្លើយរបស់សាក្សីដោយការិយាល័យសហចៅក្រមស៊ើបអង្កេតចំពោះឯកសារបទសម្ភាសន៍ជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើយ៉ាងណាឲ្យមានការគោរពដល់សិទ្ធិជនជាប់ចោទ ។

ទាក់ទងនឹងឯកសារចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម លោកមេធាវីបានលើកឡើងថា អនុសញ្ញាស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម បានហាមឃាត់មិនឲ្យលើកយកឯកសារដែលប្រហាក់ប្រហែលដោយការធ្វើទារុណកម្មមកប្រើប្រាស់នៅក្នុងសវនាការបានទេ ។

ចំពោះឯកសារដែលទទួលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកមេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួនធ្លាប់បានលើកឡើងរួមមកហើយ នៅក្នុងសេចក្តីជំទាស់ផ្ទាល់មាត់ និងសេចក្តីជំទាស់

ដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

រីឯបញ្ហាទាក់ទងនឹងឈ្មោះរបស់សាក្សី គឺភាគីទាំងអស់ធ្លាប់បានប្រើប្រាស់រួចហើយ ដូច្នេះលោកគិតថាក្រុមមេធាវីអាចលើកយក ឈ្មោះទាំងអស់នោះនៅក្នុងសវនាការបាន ។

ពាក់ព័ន្ធនឹងសហចៅក្រមស៊ើបអង្កេត លោកមេធាវីបានអះអាងថា អ្នកអង្កេតការណ៍ទាំងឡាយយល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតជាស្ថាប័នមួយដែលមានលក្ខណៈដោយលម្អៀង រួមទាំង បុគ្គលិករបស់ការិយាល័យនេះផង ។ ដូច្នេះអង្គជំនុំជម្រះត្រូវតែពិនិត្យពិច័យទៅលើការងាររបស់សហចៅក្រមស៊ើបអង្កេតឲ្យបានល្អិតល្អន់ ។

## ២) ការឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស់ បានឆ្លើយតបនឹងការលើកឡើងដោយសហព្រះរាជអាជ្ញា ដោយអះអាងថា សហព្រះរាជអាជ្ញាបានលើកឡើងពីការដាក់បញ្ចូលឯកសារថ្មីៗ ទៅក្នុងបញ្ជីឯកសារដែលធ្វើឲ្យក្រុមមេធាវីការពារក្តីមានភាពច្របូកច្របល់ ។

ចំពោះការលើកយកអង្គហេតុដែលមាននៅក្នុងសំណុំរឿង ០០១ មកប្រើប្រាស់នៅក្នុងសំណុំរឿង០០២ លោកមេធាវីបានអះអាងថា គឺជាការមិនអាចទទួលយកបាន ។

ទាក់ទងនឹងភាពលម្អៀងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លោកមេធាវីយល់ស្របនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តីរបស់ នួន ជា ដោយសារតែលោកចៅក្រមម៉ាកសែល ឡឺម៉ុង (Marcel Lemond) ស្វែងរកតែភស្តុតាងដាក់បន្ទុក ដោយមិនបានស្វែងរកភស្តុតាងដោះបន្ទុក ។ លោកមេធាវីបានបន្ថែមថាភាពលម្អៀងបានបង្ហាញឡើងតាមរយៈការជ្រើសរើសបុគ្គលិកពីការិយាល័យសហព្រះរាជអាជ្ញា (ធ្វើការដើម្បីស្វែងរកភស្តុតាងចោទប្រកាន់ជនជាប់ចោទ) ទៅធ្វើការនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត (ធ្វើការដើម្បីស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះ បន្ទុកសម្រាប់ជនជាប់ចោទ) ។

លោកមេធាវី ខាណាវ៉ាស់ បានបន្តថា ការដែលយកឯកសារដែលមិនជាប់ទាក់ទងចូលក្នុងសវនាការដំណាក់កាលដំបូង គឺជាការមិនអាចទទួលយកបាន ។ លោកមេធាវីបានរំឭកសម្តីរបស់លោកតំណាងសហព្រះរាជអាជ្ញា ឌេល លីសាក់ ដែលទទួលស្គាល់ថាឯកសារមួយចំនួនមិនជាប់ពាក់ព័ន្ធនឹងសវនាការវគ្គដំបូង ។ លោកបានលើកឧទាហរណ៍អំពីការយកព្រះរាជក្រឹត្យលើកលែងទោស អៀង សារី ដាក់ចូលទៅក្នុងសំណុំរឿងនៃសវនាការ ដោយលោកបានចោទសួរថា តើព្រះរាជក្រឹត្យលើកលែងទោសនោះមានការជាប់ពាក់ព័ន្ធនឹងសវនាការដំណាក់នេះដោយរបៀបណា ។

លោកមេធាវីក៏បានឆ្លើយតបចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិជ្ជាជីវៈរបស់ចៅក្រមថា ចៅក្រមដែលមានវិជ្ជាជីវៈត្រូវតែមានចំណេះដឹងថាតើភស្តុតាងណាដែលគួរទទួលយក និងភស្តុតាងណាដែលមិនគួរទទួលយក ។ លោកបានបន្ថែមថា ប្រសិនបើលោក លោកស្រីចៅក្រម ចង់ទទួលយកឯកសារណាមួយ លោក លោកស្រី ត្រូវតែបង្ហាញឲ្យក្រុមមេធាវីការពារក្តីអាចទុកចិត្តបាន ហើយលោកបានស្នើឲ្យចៅក្រមប្រើប្រាស់ឆន្ទានុសិទ្ធិទទួលយកឯកសារក្នុងកម្រិតអប្បបរមា ដោយសារឯកសារដែលមាននៅក្នុងសំណុំរឿងមានចំនួនច្រើនពេក ។

ពាក់ព័ន្ធនឹងដីកាចាត់ឲ្យស៊ើបសួរជំនួស លោកមេធាវីបានលើកឡើងថា លោក ឡុង នរិន្ទ ធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរួចហើយ ដូច្នេះតើហេតុអ្វីបានជាអង្គជំនុំជម្រះចាំបាច់ហៅគាត់មកធ្វើជាសាក្សីនៅក្នុងសវនាការម្តងទៀតធ្វើអ្វី ។ លោកបានសង្កត់ធ្ងន់ថា ការណ៍ដែលអង្គជំនុំជម្រះកោះហៅម្តងទៀតនេះ គឺដើម្បីធ្វើជាភស្តុតាង ។ ដូច្នេះសាក្សីត្រូវតែស្បថ ដើម្បីអាចឲ្យក្រុមមេធាវីការពារក្តីជឿជាក់ថាសម្តីរបស់សាក្សីគឺជាការពិត ។

ទាក់ទងនឹងចម្លើយដែលសាក្សីបានឆ្លើយ ហើយអង្គជំនុំជម្រះយកចម្លើយនោះដាក់ចូលទៅក្នុងសំណុំរឿង លោកមេធាវីបានស្នើថា អង្គជំនុំជម្រះចាំបាច់ត្រូវតែកោះហៅសាក្សីរូបនោះមកធ្វើការសាកសួរនៅក្នុងតុលាការដើម្បីឲ្យសក្ខីកម្មរបស់សាក្សីអាចទទួលយកបាន ។ លោកមេធាវី ខាណាវ៉ាស់ បានលើកឡើងនូវឧទាហរណ៍ពាក់ព័ន្ធនឹងប្រតិចារិកនៃសវនាការសំណុំរឿង០០១ ដែលមាននៅក្នុងរយៈពេលវែង ប៉ុន្តែនៅពេល ឌុច មកធ្វើសក្ខីកម្មគឺក្រុមមេធាវីការពារក្តីមានពេលត្រឹមតែ១ ឬ២ម៉ោងតែប៉ុណ្ណោះ ។ ដូច្នេះតើក្រុមមេធាវីត្រូវតែលើកយកអង្គហេតុទាំងអស់នៃសំណុំ

រឿង០០១ មកសួរដេញដោលឬយ៉ាងណា? នៅក្នុងសំណុំរឿង ០០១ ការផ្តល់សក្ខីកម្មរបស់អ្នកជំនាញមួយចំនួនក៏មិនមានជាប់ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមដែលត្រូវសួរដេញដោល នៅក្នុងសំណុំរឿង០០២ទេ ដូច្នេះតើហេតុអ្វីត្រូវយកប្រតិចារិករបស់អ្នកទាំងនោះមកប្រើប្រាស់នៅក្នុងសំណុំរឿង០០២ នៅក្នុងសវនាការពេលនេះទៅវិញ ។

### គ) ការឆ្លើយតបរបស់មេធាវី ខៀវ សំផន

លោក គង់ សំអុន មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បានឆ្លើយតបនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ដោយបានលើកឡើងថា ភាគច្រើននៃឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ចូលក្នុងសំណុំរឿង គឺមិនមានភាពជាប់ពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងទេ ។ អង្គជំនុំជម្រះបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលធ្វើឲ្យឯកសារខ្លះរបស់សហព្រះរាជអាជ្ញាមិនមានជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២ ដំណាក់កាលទី១ ។ ដូច្នេះសហព្រះរាជអាជ្ញាត្រូវតែដាក់តែឯកសារណាដែលពាក់ព័ន្ធដើម្បីធ្វើការសួរដេញដោលនៅក្នុងសវនាការវគ្គដំបូងនេះ ។

លោកមេធាវីបានលើកឡើងពីការបង្ហាញខ្សែវីដេអូស្តីពីការសម្ភាសន៍ជាមួយជនជាប់ចោទ ខៀវ សំផន ដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ខេល លីសាក់ បានបង្ហាញជូនអង្គជំនុំជម្រះ និងអះអាងថាគឺមានតែជនជាប់ចោទ ខៀវ សំផន តែម្នាក់គត់ដែលបានដឹងថានរណាជាអ្នកសម្ភាសន៍ខ្លួន ។ ឆ្លើយតបនឹងការលើកឡើងនេះ លោកមេធាវី គង់ សំអុន បានបញ្ជាក់ថាសហព្រះរាជអាជ្ញាបានភ្លេច ហើយថាខ្លួនគឺជាអ្នកដែលមានតួនាទីបង្ហាញភស្តុតាងឲ្យលើសពីវិមតិសង្ស័យ មិនមែនក្រុមមេធាវីការពារក្តីត្រូវទៅរកភស្តុតាងដើម្បីដោះបន្ទុកឲ្យកូនក្តីរបស់ខ្លួនទេ ។ បន្ទាប់មកលោកមេធាវីបានប្រគល់វេទិកាជូនសហភាគារបស់ខ្លួនធ្វើការលើកឡើងបន្ត ។

មេធាវីការពារក្តីអន្តរជាតិ អង់តា ហ្គីសេ បានឆ្លើយតបនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងបញ្ហាវិជ្ជាជីវៈរបស់ចៅក្រម ការពង្រីកវិសាលភាពនៃសវនាការដើម្បីអាចសួរដេញដោលលើសពីអង្គហេតុដែលបានកំណត់, ថាយភាព និងភាពគួរឲ្យជឿជាក់បាននៃឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា, ការបញ្ចូលឯកសារថ្មីៗចូលទៅក្នុងបញ្ជីឯកសារ ដែលខ្លួនចាត់ទុកថាមិនជាប់ពាក់ព័ន្ធនឹងសវនាការនាដំណាក់កាលដំបូង ។

បន្ទាប់ពីបញ្ចប់ការឆ្លើយតបរបស់ក្រុមមេធាវីការពារក្តីទាំងបីក្រុម អង្គជំនុំជម្រះបានបន្តនីតិវិធីរបស់ខ្លួនដោយចាប់ផ្តើមសវនាការស្តីពីសំណើសុំរបស់ជនជាប់ចោទ នួន ជា ដើម្បីចូលរួមសវនាការស្តីពីការសួរដេញដោល ឌុច ។

## III. នួន ជា ស្នើសុំអង្គជំនុំជម្រះចូលរួមក្នុងសវនាការស្តីពីការសួរដេញដោលលើ ឌុច

នៅអំឡុងពេលសវនាការពេលព្រឹក ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ត្រូវបានផ្តល់ឱកាសឲ្យលើកឡើងពីសំណើសុំផ្ទាល់មាត់របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងការចូលរួមរបស់ជនជាប់ចោទ នួន ជា នៅក្នុងសវនាការស្តីពីការសួរដេញដោលលើទណ្ឌិត ឌុច ។ គួរកត់សម្គាល់ថា ឌុច ត្រូវបានអង្គជំនុំជម្រះសាលាដំបូងកោះហៅឲ្យចូលខ្លួនមកធ្វើជាសាក្សីនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទីមួយ ដោយសារ ឌុច គឺជាសាក្សីសំខាន់មួយរូបសម្រាប់សំណុំរឿង០០២ ។ សូមបញ្ជាក់ថា ការណ៍ដែលនាំឲ្យជនជាប់ចោទ នួន ជា ធ្វើសំណើសុំដូច្នេះ គឺដោយសារអង្គជំនុំជម្រះបានកំណត់នៅក្នុងសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនថា អង្គជំនុំជម្រះនឹងបើកសវនាការសួរដេញដោលលើរូប នួន ជា នៅពេលព្រឹក និងបន្តសួរដេញដោលលើរូបទណ្ឌិត ឌុច នៅពេលរសៀល ។ ដោយបារម្ភថាកូនក្តីរបស់ខ្លួនមិនអាចអនុវត្តសិទ្ធិដោយប្រសិទ្ធភាពក្នុងការតទល់ជាមួយនឹងសាក្សី ឌុច ក្រុមមេធាវីការពារក្តីរបស់ នួន ជា ស្នើឲ្យអង្គជំនុំជម្រះធ្វើសវនាការសួរដេញដោល ឌុច នៅពេលព្រឹកវិញ ព្រោះកូនក្តីរបស់ខ្លួនមិនអាចចូលរួមសវនាការឲ្យបានពេញលេញនៅពេលរសៀលទេ ។

### ១) សំណើសុំរបស់មេធាវីការពារក្តីអន្តរជាតិ នួន ជា

មេធាវីការពារក្តីអន្តរជាតិឲ្យជនជាប់ចោទ នួន ជា គឺលោក ម៉ៃឃើល ផេស្តមេន បានធ្វើសំណើសុំទៅអង្គជំនុំជម្រះស្តីពីការព្រួយបារម្ភរបស់ខ្លួនអំពីលទ្ធភាពរបស់កូនក្តីខ្លួនដើម្បីតទល់ជាមួយនឹងទណ្ឌិត ឌុច នៅពេលដែល ឌុច ត្រូវចូលមកធ្វើសក្ខីកម្មនៅក្នុង

សវនាការនាពេលខាងមុខ ។ លោកមេធាវីបានកត់សម្គាល់ថា ឌុច គឺពិតជាសាក្សីដ៏សំខាន់មួយរូបសម្រាប់សំណុំរឿង ប៉ុន្តែ ឌុច នឹងមិនអាចផ្តល់សក្ខីកម្មឲ្យបានលម្អិតនៅក្នុងសវនាការនៃសំណុំរឿង០០២នេះបានទេ ។ ជាពិសេសគឺចំពោះសវនាការដំណាក់កាលទីមួយនេះតែម្តង ។ ទោះបីជាយ៉ាងណា កូនក្តីរបស់ខ្លួនចង់ស្នើសុំអង្គជំនុំជម្រះដើម្បីនៅតទល់ដោយផ្ទាល់ជាមួយនឹង ឌុច ដែលនឹងត្រូវធ្វើសក្ខីកម្មនៅក្នុងសវនាការនាពេលខាងមុខ ។ លោកមេធាវីក៏បានយោងលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានចែងពីសិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនីតិវិធីនៅក្នុងសវនាការ ។ លោកមេធាវីបានស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការសួរដេញដោលលើ ឌុច នាពេលព្រឹកដើម្បីឲ្យកូនក្តីរបស់ខ្លួនអាចចូលរួមនៅក្នុងសវនាការដោយមានប្រសិទ្ធភាព ដោយសារនៅពេលរសៀល នួន ជា មិនមានកម្លាំងគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដោយផ្ទាល់ ហើយនៅពេលចូលរួមសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ នួន ជា តែងតែសម្រាន្តលក់ ។ ដូច្នេះបើធ្វើសវនាការដេញដោល ឌុច នៅពេលរសៀល ហើយកូនក្តីរបស់ខ្លួនមិនអាចតទល់ជាមួយ ឌុច ដែលជាសាក្សីសំខាន់ដោយផ្ទាល់បាន នោះវាគឺជាការរំលោភមកលើសិទ្ធិកូនក្តីរបស់ខ្លួន ។ លោកមេធាវី ដេស្តមេន បានបន្តថា ជនជាប់ចោទមិនអាចចូលរួមដោយមានប្រសិទ្ធភាពពីបន្ទប់រង់ចាំទេ និងផ្តល់យោបល់ថា អង្គជំនុំជម្រះគួរតែដោះស្រាយនូវបញ្ហានេះ ដោយប្តូរការសួរដេញដោលសាក្សីសំខាន់ដូចជារូប ឌុច មកសវនាការនាពេលព្រឹកវិញ ។

## ២) ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើសុំរបស់ នួន ជា

ឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ឌេល លីសាក់ បានកត់សម្គាល់ថា អង្គជំនុំជម្រះបានជូនដំណឹងដល់គ្រប់ភាគីទាំងអស់ជាមុនរួចហើយអំពីពេលវេលាដែល ឌុច ត្រូវផ្តល់សក្ខីកម្ម និងពេលវេលាដែលត្រូវបានបែងចែកសម្រាប់ការផ្តល់សក្ខីកម្មនេះ ។ លោកបានបញ្ជាក់បន្ថែមថា អង្គជំនុំជម្រះបានកំណត់រួចហើយ គឺនឹងសួរជនជាប់ ចោទ នួន ជា នៅពេលព្រឹក និងសួរដេញដោលសាក្សី ឌុច នៅពេលរសៀលដែលចំណុចទាំងអស់នេះគឺមានបានសរសេរច្បាស់លាស់ទៅហើយនៅក្នុងសេចក្តីជូនដំណឹងរបស់អង្គជំនុំជម្រះកាលពី២ទៅ៣សប្តាហ៍មុន ។ ដូច្នេះលោកតំណាងសហព្រះរាជអាជ្ញាមិនយល់ថាហេតុអ្វីបានមេធាវីការពារក្តីរបស់ នួន ជា លើកបញ្ហា ឌុច នៅពេលនេះទេ ។ ចំពោះការលើកឡើងរបស់លោកមេធាវី ដេស្តមេន ដែលថា ប្រសិនបើមិនសួរដេញដោល ឌុច នៅពេលព្រឹក គឺជាការរំលោភលើសិទ្ធិរបស់ នួន ជា ដោយសារជនជាប់ចោទមានសិទ្ធិក្នុងការមានវត្តមាននៅក្នុងសវនាការ និងសិទ្ធិក្នុងការសួរដេញដោលសាក្សីត្រូវបានលោកតំណាងសហព្រះរាជអាជ្ញាឆ្លើយតបថា គឺជារឿងមិនត្រឹមត្រូវនោះទេ ។ លោកបានបន្តថា គេត្រូវមើលថាតើជនជាប់ចោទ នួន ជា មានកាយសម្បទា បញ្ញា ស្មារតីគ្រប់គ្រាន់អាចចូលរួមសវនាការបាន ទាំងពេលព្រឹក និងពេលរសៀលបានដែរឬទេ ។ ចំពោះបញ្ហាសម្បទា លោកតំណាងព្រះរាជអាជ្ញាបានលើកឡើងថាអង្គជំនុំជម្រះធ្លាប់បានអញ្ជើញអង្គជំនាញឲ្យធ្វើការវាយតម្លៃពីបញ្ហាសម្បទារបស់ជនជាប់ ចោទ នួន ជា រួចទៅហើយកាលពីពេលមុន ហើយនៅក្នុងនោះអ្នកជំនាញបានរកឃើញថាជនជាប់ចោទ នួន ជា គឺមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ ។ លោកតំណាងសហព្រះរាជអាជ្ញាក៏បានរំឭកអំពីការចូលរួមនៅក្នុងសវនាការពេញមួយថ្ងៃកាលពីពេលមុន និងបញ្ជាក់ថាជំហររបស់សហព្រះរាជអាជ្ញា គឺមិនគួរមានការផ្លាស់ប្តូរអ្វីដែលអង្គជំនុំជម្រះបានគ្រោងទុកទេ រហូតដល់ពេលជនជាប់ចោទ នួន ជា ត្រូវបានរកឃើញដោយក្រុមគ្រូពេទ្យថា មានបញ្ហាសុខភាពធ្ងន់ធ្ងរមិនអាចបន្តចូលរួមនៅក្នុងដំណើរការសវនាការបាន ។

## ៣) ការឆ្លើយតបរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើសុំរបស់ នួន ជា

សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានជំទាស់នឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ដោយបានគាំទ្រទាំងស្រុងចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ។ លោកមេធាវី ពេជ អង្គ បានបន្ថែម

ថាជនជាប់ចោទ នួន ជា អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការចូលរួមដោយប្រយោលតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់រង់ចាំដែលស្ថិតនៅពីក្រោមនៃបន្ទប់សវនាការ ។ ម៉្យាងវិញទៀត ជនជាប់ចោទក៏អាចទូរស័ព្ទទាក់ទងជាមួយមេធាវីរបស់ខ្លួនបានគ្រប់ពេលវេលា ។ ដូច្នេះអង្គជំនុំជម្រះមិនគួរអនុញ្ញាតឲ្យមានការផ្លាស់ប្តូរកិច្ចដំណើរការនីតិវិធីដែលបានគ្រោងទុកឡើយ ។ ប្រសិនបើមានអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា នោះ នួន ជា នឹងស្នើសុំឲ្យធ្វើដូច្នេះជាថ្មីទៀតជាមួយនឹងសាក្សីផ្សេងនៅពេលក្រោយដែលនឹងធ្វើឲ្យកិច្ចដំណើរការនីតិវិធីមិនអាចដំណើរការទៅមុខបានដោយរលូន ។

ភ្លាមៗក្រោយពីការលើកឡើងរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីអន្តរជាតិ ការពារក្តី នួន ជា គឺលោក ម៉ៃឃើល ផេស្តមេន បានបញ្ជាក់ទៅក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ក្រុមមេធាវីការពារក្តី នួន ជា មិនបានស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យលើសម្បទារបស់ជនជាប់ចោទនោះទេ គឺគ្រាន់តែចង់បង្ហាញថា នួន ជា មានភាពលំបាកក្នុងការចូលរួមនៅក្នុងសវនាការដោយផ្ទាល់នៅពេលរសៀល និងចង់ស្នើសុំឲ្យមានការផ្លាស់ប្តូរពេលវេលានៃការសួរដេញដោលលើរូប ឌុច ពីពេលព្រឹកមកពេលរសៀលវិញប៉ុណ្ណោះ ។

គ្រាន់តែលោកមេធាវី ផេស្តមេន និយាយចប់ភ្លាម លោក ម៉ៃឃើល ខាណាវ៉ាស់ មេធាវីការពារក្តីឲ្យ ជនជាប់ចោទ អៀង សារី បានក្រោកឈរឡើងស្នើសុំអង្គជំនុំជម្រះដើម្បីធ្វើការកត់សម្គាល់ចំពោះការលើកឡើងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ។ អង្គជំនុំជម្រះបានអនុញ្ញាតចំពោះសំណើនេះ ។ លោកមេធាវី ខាណាវ៉ាស់ បានធ្វើការកត់សម្គាល់ទាក់ទងនឹងការលើកឡើងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលថា បន្ទប់រង់ចាំគឺជាកន្លែងសមស្របបំផុតដែលជនជាប់ចោទអាចទាក់ទងជាមួយនឹងមេធាវីការពារក្តីរបស់ខ្លួន នៅពេលដែលជនជាប់ចោទមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។ លោកមេធាវីបានរំឭកពីសម្តីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក អេនឌ្រូ ខេលី ដែលធ្លាប់បានអះអាងនៅក្នុងសវនាការថ្ងៃបើកការចោទប្រកាន់ថា ជនជាប់ចោទគួរតែបន្តស្ថិតនៅក្នុងបន្ទប់សវនាការ ព្រោះជនជាប់ចោទមិនអាចផ្តល់ការណែនាំដល់មេធាវីមេធាវី ការពារក្តីរបស់ខ្លួនបានទេ ប្រសិនបើជនជាប់ចោទតាមដាននីតិវិធីសវនាការនៅក្នុងបន្ទប់រង់ចាំនោះ ។ បន្ថែមពីលើនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានអះអាងនៅពេលនោះដែរថា ជនជាប់ចោទត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ ។ ដូច្នេះទាំងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគួរត្រឡប់ទៅមើលកាលជំទាស់របស់ខ្លួនកាលពីពេលមុន ។ លោកក៏បានស្នើសុំអង្គជំនុំជម្រះគួរតែទទួលស្គាល់ថា ជនជាប់ចោទមិនអាចចូលរួមដោយប្រសិទ្ធភាពពីបន្ទប់រង់ចាំនៅអំឡុងពេលសវនាការដែលមានលក្ខណៈសំខាន់ដូចជាសវនាការនាពេលនេះទេ បន្ថែមពីលើការលើកឡើងនេះ លោកមេធាវីក៏បានកត់សម្គាល់ពីការបដិសេធរបស់អង្គជំនុំជម្រះដែលមិនអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនគឺជនជាប់ចោទ អៀង សារី ទៅតាមដាននីតិវិធីសវនាការពីបន្ទប់រង់ចាំដោយអង្គជំនុំជម្រះផ្តល់ហេតុផលថា អៀង សារី ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ ដើម្បីស្តាប់ការចោទប្រកាន់ដាក់លាក់ប្រឆាំងនឹងរូបខ្លួនដែលអានចេញពីដីកាដំណោះស្រាយដោយក្រឡាបញ្ជី ។ បន្ទាប់មកលោកបានលើកឡើងពីមូលដ្ឋានយុត្តិសាស្ត្រអន្តរជាតិមួយចំនួន ដូចជារឿងក្តីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងរឿងក្តីរបស់តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ករណីស្រូហ្គា ដោយលោកបានបង្ហាញពីការលះបង់សិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមដោយផ្ទាល់នៅក្នុងសវនាការ ហើយទៅចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់រង់ចាំ គឺដោយសារតែជនជាប់ចោទចង់ដំណើរការនីតិវិធីនៅតែបន្ត ។ លោកមេធាវីបានបញ្ចប់ការលើកឡើងរបស់ខ្លួន ដោយរំឭកអង្គជំនុំជម្រះពីសិទ្ធិជាមូលដ្ឋានចាំបាច់របស់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ។

ចំណែកឯតំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក ឌេល លីសាក់ បានក្រោកឈរឡើង និងបញ្ជាក់ទៅក្រុមមេធាវីការពារក្តីរបស់ នួន ជា និង អៀង សារី វិញថា ក្រុមមេធាវីការពារក្តីមិនត្រូវចេះតែលើកឡើងដោយមិនមានភស្តុតាងបញ្ជាក់អំពីស្ថានភាពសុខភាពរបស់កូនក្តីរបស់ខ្លួននោះទេ គឺចាំបាច់ត្រូវតែមានរបាយការណ៍

បញ្ជាក់ពីគ្រូពេទ្យដើម្បីបង្ហាញថាស្ថានភាពសុខភាពជនជាប់ចោទ អាចចូលរួមបានឬមិនបាន ។

ដើម្បីដោះស្រាយបញ្ហាខាងលើ លោកស្រីចៅក្រម ស៊ីលវៀ ខាតព្រ៉ាយត៍ បានស្នើសុំឲ្យភាគីធ្វើការបញ្ជាក់ខ្លីៗចំពោះបញ្ហាដែល មេធាវីការពារក្ដី នួន ជា ស្នើសុំ ។

លោកមេធាវី ជេស្ដមេន បានលើកឡើងថា ខ្លួនគ្រាន់តែចង់ឲ្យសវនាការធ្វើឡើងនៅពេលព្រឹក ដើម្បីឲ្យកូនក្ដីរបស់ខ្លួនបានសម្រាកខ្លះប៉ុណ្ណោះ ។ មេធាវីការពារក្ដីរបស់ អៀង សារី បានគាំទ្រការលើកឡើងរបស់មេធាវីការពារក្ដី នួន ជា ។

រីឯ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួននឹងគាំទ្រចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលថា ត្រូវធ្វើពេលព្រឹក ឬពេលរសៀល ។

## IV. ការស្នើសុំរបស់សហព្រះរាជអាជ្ញាដើម្បីស្ដាប់សក្ខីកម្មអ្នកជំនាញ ប៉ែន យៀវនិន តាមរយៈប្រព័ន្ធសោតទស្សន៍

នៅក្នុងសវនាការពេលរសៀលថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាលើកឡើងនូវសំណើសុំរបស់ខ្លួនទាក់ទងនឹងការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញមួយរូប គឺសាស្ត្រាចារ្យ ប៉ែន យៀវនិន តាមរយៈប្រព័ន្ធសោតទស្សន៍ ដែលធ្វើឡើងពីចម្ងាយ ។ ការស្នើសុំស្ដាប់សក្ខីកម្មរបស់អ្នកជំនាញរូបនេះតាមរយៈប្រព័ន្ធសោតទស្សន៍ត្រូវបានសហព្រះរាជអាជ្ញាផ្ដល់អំណះអំណាងថា គឺដោយសារសាស្ត្រាចារ្យ ប៉ែន យៀវនិន មានការជាប់រវល់ក្នុងអាជីពការងាររបស់សាស្ត្រាចារ្យដែលមិនអាចអនុញ្ញាតឲ្យលោកចូលរួមដោយផ្ទាល់នៅក្នុងសវនាការបាន ។ ប៉ុន្តែក្រុមមេធាវីការពារក្ដីទាំងបីក្រុមបានជំទាស់នឹងសំណើនេះ ។

### ១) សំណើសុំរបស់សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញារងជាតិ លោក ច័ន្ទ គារាវស្មី បានឡើងជម្រាបជូនអង្គជំនុំជម្រះអំពីសំណើសុំរបស់ខ្លួនទាក់ទងនឹងការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញ គឺសាស្ត្រាចារ្យ ប៉ែន យៀវនិន តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយសារលោកមិនអាចចូលរួមផ្ដល់សក្ខីកម្មនៅក្នុងសវនាការដោយផ្ទាល់បាន ។ លោកសហព្រះរាជអាជ្ញារងជាតិបានបញ្ជាក់ថា សហព្រះរាជអាជ្ញាបានទាក់ទងទៅសាស្ត្រាចារ្យ ប៉ែន យៀវនិន តាមរយៈការបង្គាប់របស់អង្គជំនុំជម្រះដើម្បីអញ្ជើញលោកឲ្យមកផ្ដល់សក្ខីកម្មនៅដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែសាស្ត្រាចារ្យ យៀវនិន បានបញ្ជាក់ថា លោកមិនអាចចូលរួមដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះបានទេ ដោយសារលោកជាប់រវល់នឹងអាជីពការងារ ។ ឆ្លើយតបនឹងការបញ្ជាក់របស់សាស្ត្រាចារ្យ យៀវនិន ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំឲ្យលោកធ្វើលិខិតជាលាយលក្ខណ៍អក្សរបញ្ជាក់ពីហេតុផលដែលនាំឲ្យលោកមិនអាចចូលរួមដោយផ្ទាល់បាននៅក្នុងសវនាការ ។ បន្ទាប់មកសាស្ត្រាចារ្យ យៀវនិន បានផ្ញើលិខិតមួយឆ្លើយតបនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ដោយបង្ហាញពីភាពមមាញឹកនៃអាជីពការងាររបស់លោក ។ លោកសហព្រះរាជអាជ្ញារងជាតិបានលើកឡើងថា ការប្រើប្រាស់ការចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍ គឺមិនបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទឡើយ ។ លោកបានបន្តទៀតថា វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងអង្គជំនុំជម្រះផងមិនបានហាមឃាត់សហព្រះរាជអាជ្ញាឲ្យប្រើប្រាស់មធ្យោបាយផ្សេង ក្រៅពីការចូលរួមដោយផ្ទាល់នោះឡើយ ។ លោក គារា វស្មី បានលើកឡើងពីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់


លោកស្រី ជា លាង
ច័ន្ទ គារាវស្មី
(រូបថត : អ.វ.ត.ក)

ប្រទេសវ៉ាន់ដា ទាក់ទងនឹងការប្រើប្រាស់មធ្យោបាយសោតទស្សន៍ នៅពេលដែលសាក្សី ឬអ្នកជំនាញមានហេតុផលគ្រប់គ្រាន់ដែលបញ្ជាក់ថា ខ្លួនពិតជាមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។ លោកបានបង្ហាញពីវិធាន២៦(១) និង(២) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានភាពស្រដៀងគ្នានឹងយុត្តិសាស្ត្រអន្តរជាតិនានា និងមានសារសំខាន់ក្នុងការអនុវត្តនូវភាពបត់បែន នៅពេលដែលមានបញ្ហានៃការចូលរួមដោយផ្ទាល់របស់អ្នកជំនាញ ឬសាក្សី ។ បន្ទាប់មក លោកសហព្រះរាជអាជ្ញារងជាតិ គារ សេរី បានផ្ទេរវេទិកាជូនសហភាគីអន្តរជាតិរបស់ខ្លួន ដើម្បីធ្វើការបង្ហាញពីលទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍នៅក្នុងសវនាការ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក វ៉ាំងសង់ វ៉ាយដេស្វាឯល បានលើកឡើងថា សាស្ត្រាចារ្យ ប៉ែន ឃៀវនិន ធ្លាប់បានឆ្លើយតបនឹងការស្នើរបស់សហព្រះរាជអាជ្ញាដែលបានអញ្ជើញលោកឲ្យចូលផ្តល់សក្ខីកម្ម នៅក្នុងសវនាការរួចហើយ ។ ដោយសាស្ត្រាចារ្យ ឃៀវនិន បានបញ្ជាក់ថា លោកមិនអាចចូលរួមសវនាការដោយផ្ទាល់ នៅក្នុងឆ្នាំ២០១២បានទេ ដោយសារតែបញ្ហាមមារញឹកនៃអាជីពការងាររបស់លោកនៅសាកលវិទ្យាល័យយ៉េល នៅសហរដ្ឋអាមេរិក ។ ប៉ុន្តែលោកអាចនឹងចូលរួមផ្តល់សក្ខីកម្មដោយផ្ទាល់ នៅក្នុងសវនាការ បាននៅក្នុងឆ្នាំ២០១៣ ។ សាស្ត្រាចារ្យ ប៉ែន បានធ្វើលិខិតបង្ហាញពីមូលហេតុនៃភាពមមារញឹកនៅក្នុងអាជីពរបស់ខ្លួន និងផ្ញើជូនមកការិយាល័យសហព្រះរាជអាជ្ញារួចហើយ ។ ការិយាល័យសហព្រះរាជអាជ្ញាក៏បានបញ្ជូនលិខិតនោះទៅអង្គភាពគាំពារអ្នកជំនាញ និងសាក្សីហើយដែរ ។ ដូច្នេះការស្នើសុំផ្តល់សក្ខីកម្មរបស់សាស្ត្រាចារ្យ ប៉ែន ពិតជាមានហេតុផលគ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យលោកផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីចម្ងាយដោយមិនចាំបាច់ចូលរួមដោយផ្ទាល់នៅក្នុងសវនាការឡើយ ។

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងពីការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ដើម្បីផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង០០១ និងការផ្តល់សក្ខីកម្មរបស់លោក ឡុង នរិន្ទ នាពេលកន្លងទៅដោយមិនមានបញ្ហា និងពុំបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទដូចជាការលើកឡើងរបស់ក្រុមមេធាវីការពារក្តី អៀង សារី ទេ ។ ដូច្នេះការអះអាងរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលថាការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ដើម្បីធ្វើសក្ខីកម្មជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ គឺជាការលើកឡើងដោយគ្មានមូលដ្ឋានអ្វីសោះឡើយ ។ លោកតំណាងសហព្រះរាជអាជ្ញាបានស្នើឲ្យភាគីទាំងអស់ គប្បីធ្វើបញ្ជីមួយបង្ហាញពីអ្វីដែលខ្លួនចង់សួរដេញដោលទៅអ្នកជំនាញ សាស្ត្រាចារ្យ ប៉ែន ឃៀវនិន ដើម្បីបង្កភាពងាយស្រួលដល់លោកក្នុងការត្រៀមខ្លួនឆ្លើយតបនឹងសំណួរទាំងអស់របស់ភាគី ។ លោកបានស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធចោលការលើកឡើងរបស់ក្រុមមេធាវីការពារក្តីដែលធ្វើការជំទាស់ ដោយមិនមានមូលដ្ឋានត្រឹមត្រូវ ។

## ២) មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រការស្នើសុំរបស់សហព្រះរាជអាជ្ញា

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីមេធាវី ស៊ីមូណូហ្វុត បានធ្វើកត់សម្គាល់ថា សាស្ត្រាចារ្យ ប៉ែន ឃៀវនិន មិនមែនជាសាក្សីរបស់សហព្រះរាជអាជ្ញាទេ ប៉ុន្តែគឺជាអ្នកជំនាញមួយរូបដែលអង្គជំនុំជម្រះអញ្ជើញមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការ ។ លោកស្រីបានបន្ថែមថា អង្គជំនុំជម្រះធ្លាប់បានធ្វើសេចក្តីសម្រេចរួចហើយថា ការសួរដេញដោលត្រូវធ្វើឡើងដោយផ្ទាល់ ប៉ុន្តែប្រសិនបើមិនអាចធ្វើឡើងដោយផ្ទាល់បានគឺត្រូវធ្វើឡើងដោយប្រយោលតាមរយៈប្រព័ន្ធសោតទស្សន៍ ។ ការណ៍ដែលសាស្ត្រាចារ្យ ប៉ែន ឃៀវនិន មិនអាចចូលរួមសវនាការដោយផ្ទាល់ គឺលោកបានផ្តល់ហេតុផលច្បាស់លាស់រួចហើយ ។ ហេតុនេះការប្រើប្រាស់ប្រាស់ប្រព័ន្ធសោតទស្សន៍នៅក្នុងសវនាការសួរដេញដោលលើរូបសាស្ត្រាចារ្យ ប៉ែន ជាមធ្យោបាយមួយប្រសើរបំផុត ។

## ៣) ក្រុមមេធាវីការពារក្តីទាំងបីក្រុមជំទាស់នឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា

មុនពេលអង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីដើម្បីបង្ហាញពីការជំទាស់របស់ខ្លួននឹងសំណើសុំរបស់សហព្រះរាជអាជ្ញា លោកប្រធានអង្គជំនុំជម្រះ និល ណុន បានធ្វើការកត់សម្គាល់លើការប្រើប្រាស់ពាក្យថា “*សវនាការខ្នាតតូច*” (Mini-

Trial) ដែលក្រុមមេធាវីការពារក្តី នួន ជា បានប្រើប្រាស់នៅក្នុងសវនាការដោយប្រគល់ភារៈជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ធ្វើការបញ្ជាក់ ។ លោកស្រីចៅក្រម ខាតវ៉្រាយត៍ បានធ្វើការកត់សម្គាល់ថា លោកស្រីយល់ស្របជាមួយនឹងការជំទាស់របស់សហព្រះរាជអាជ្ញាចំពោះការប្រើប្រាស់ពាក្យថា "សវនាការខ្នាតតូច" នៅក្នុងបន្ទប់សវនាការ ព្រោះពាក្យនេះគឺជាពាក្យដែលមិនសមរម្យ និងធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់ភាគីដទៃដែលរងគ្រោះដោយសារឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ។ លោកស្រីបានណែនាំឲ្យភាគីទាំងអស់គឺគប្បីមិនគួរបន្តប្រើប្រាស់ពាក្យនេះទៀតទេ ។

បន្ទាប់មក អង្គជំនុំជម្រះបានប្រគល់វេទិកាទៅក្រុមមេធាវីការពារក្តី អៀង សារី លើកឡើងការជំទាស់ចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាមុនក្រុមមេធាវីការពារក្តីផ្សេងទៀត ។

### ក) ការជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីការពារក្តីអន្តរជាតិឲ្យជនជាប់ចោទ អៀង សារី គឺលោក ខាណាវ៉ាស់ បានលើកឡើងថា ទោះបីជាសាស្ត្រាចារ្យ ប៉ែន ឃៀវនិន អះអាងថា លោកមិនអាចមកចូលរួមផ្តល់សក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះដោយសារតែបញ្ហាអាជីពវិជ្ជាជីវៈរបស់លោកក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះត្រូវមើលថា តើលោកមានការជាប់រវល់នៅពេលណា ហើយទំនេរនៅពេលណា មិនមែនលោកគ្មានពេលទំនេរសោះនោះទេ ។ ម្យ៉ាងវិញទៀត ទោះបីសាស្ត្រាចារ្យ ឃៀវនិន លើកឡើងថាលោកជាប់រវល់បង្រៀនកូនសិស្សថ្នាក់បណ្ឌិតរបស់លោកនៅសាកលវិទ្យាល័យយ៉េល ក៏នៅមានជំនួយការសាស្ត្រាចារ្យអាចជួយលោកក្នុងការពិនិត្យមើល ឬជំនួសភារកិច្ចរបស់លោកបានដែរ ។ បន្ថែមពីលើនេះ លោកមេធាវីបានបញ្ជាក់ថា ការបង្រៀនកូនសិស្សថ្នាក់បណ្ឌិតមិនសូវជាប់រវល់ខ្លាំងនោះទេ ព្រោះថ្នាក់បណ្ឌិតគឺជាពេលវេលាដែលសិស្សត្រូវចំណាយពេលស្រាវជ្រាវច្រើន ។ ទាក់ទងនឹងការធ្វើការសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ លោកមេធាវីបានអះអាងថា ការធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍គឺធ្វើឲ្យមេធាវីការពារក្តីរបស់ជនជាប់ចោទ និងជនជាប់ចោទមិនអាចមើលឃើញពីអាកប្បកិរិយារបស់អ្នកជំនាញ ឬសាក្សីនៅអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់អ្នកទាំងនោះ ។ ការធ្វើដូច្នេះនឹងធ្វើឲ្យកូនក្តីរបស់ខ្លួនមិនអាចតទល់ដោយផ្ទាល់ជាមួយនឹងអ្នកជំនាញ ឬសាក្សីដែលវានឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ។ លោកមេធាវីបានបន្តថាការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងកាលៈទេសៈនេះនឹងធ្វើឲ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការផ្តល់សក្ខីកម្មរបស់សាស្ត្រាចារ្យ ប៉ែន ឃៀវនិន ដោយសារតែពេលវេលានៅក្នុងប្រទេសកម្ពុជា និងនៅសហរដ្ឋអាមេរិកមានភាពខុសគ្នារហូតដល់១២ម៉ោង ។ ហេតុនេះការផ្តល់សក្ខីកម្មរបស់លោកតាមរយៈប្រព័ន្ធសោតទស្សន៍អាចនឹងប្រព្រឹត្តទៅមិនបានល្អ ដោយសារលោកអស់កម្លាំងពីការងាររបស់លោកមួយថ្ងៃពេញ ហើយត្រូវមកផ្តល់សក្ខីកម្មរហូតដល់ពេលវេលាពាក់កណ្តាលអាធ្រាត្រ ។ គួរកត់សម្គាល់ថា នៅពេលដែលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការកិច្ចនីតិវិធីសវនាការនៅវេលាព្រឹក ម៉ោង៩នៅប្រទេសកម្ពុជានៅឯសហរដ្ឋអាមេរិក គឺនឹងត្រូវតាមដានសវនាការនេះនៅម៉ោង៩ ឬម៉ោង១០នាពេលយប់ ។ លោកមេធាវីបានទទូចឲ្យសាស្ត្រាចារ្យ ឃៀវនិន គួរតែចូលមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងសវនាការនាពេលខាងមុខ ឬមួយក៏លោកអាចធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងឆ្នាំ២០១២នេះ និងមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងឆ្នាំ២០១៣ ។



(រូបថត ៖ អ.វ.ត.ក)

### ខ) ការជំទាស់របស់ក្រុមមេធាវីការពារក្ដី នួន ជា

លោកមេធាវី ម៉ៃឃើល ផេស្ដមេន បានលើកឡើងថា ក្រុមមេធាវីការពារក្ដី នួន ជា គាំទ្រចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្ដី អៀង សារី ។ លោកយល់ថា វត្តមានរបស់សាស្ត្រាចារ្យ ប៉ែន ឃៀរនិន នៅក្នុងសវនាការគឺជារឿងសំខាន់ និងអះអាងថាប្រសិនបើលោកមិនអាចមកចូលរួមដោយផ្ទាល់នៅក្នុងសវនាការបានទេ ក្រុមមេធាវីការពារក្ដី នួន ជា មានបំណងចង់ស្នើសុំអង្គជំនុំជម្រះបញ្ជូនសមាជិកក្រុមរបស់ខ្លួនណាម្នាក់ទៅសួរដេញដោលដោយផ្ទាល់នៅសហរដ្ឋអាមេរិកតែម្ដង ។

### គ) ការជំទាស់របស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន

មេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ ខៀវ សំផន កញ្ញា អង់គា ហ្គីសេ បានលើកឡើងថា ក្រុមរបស់ខ្លួនសុំគាំទ្រចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្ដី អៀង សារី និងថាវត្តមានរបស់សាស្ត្រាចារ្យ ឃៀរនិន នៅក្នុងសវនាការដោយផ្ទាល់ គឺជារឿងសំខាន់ និងចាំបាច់ ដើម្បីឲ្យជនជាប់ចោទ និងមេធាវីការពារអាចសួរដេញដោល និងតទល់ដោយផ្ទាល់នៅក្នុងសវនាការ ។ ម្យ៉ាងវិញទៀត សាស្ត្រាចារ្យ ប៉ែន ឃៀរនិន គឺជាអ្នកជំនាញមួយរូបទាក់ទងនឹងបញ្ហាប្រល័យពូជសាសន៍ ហើយលោកក៏បានសរសេរអត្ថបទរហូតជិតទៅដល់១០០អត្ថបទពាក់ព័ន្ធនឹងបញ្ហាប្រល័យពូជសាសន៍ និងត្រូវបានចាត់ទុកថាជាអ្នកជំនាញមួយរូបទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជាទៀតផង ។ ដូច្នេះសាស្ត្រាចារ្យ ឃៀរនិន គួរតែចូលរួមផ្ដល់សក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ។

លោក គង់ សំអុន សហមេធាវីជាតិការពារក្ដី ខៀវ សំផន បានស្នើសុំទៅអង្គជំនុំជម្រះបីចំណុច ទី១ គឺអង្គជំនុំជម្រះត្រូវកោះអញ្ជើញសាស្ត្រាចារ្យ ឃៀរនិន ចូលមកផ្ដល់សក្ខីកម្មដោយផ្ទាល់នៅក្នុងសវនាការដើម្បីឲ្យក្រុមមេធាវីការពារអាចសួរដេញដោលដោយផ្ទាល់ និងស្នើឲ្យអង្គជំនុំជម្រះឲ្យពិនិត្យមើលទៅលើមូលដ្ឋាននៃការដែលសាស្ត្រាចារ្យ ឃៀរនិន មិនអាចចូលរួមនៅក្នុងសវនាការបាន ថាតើអាចទទួលយកបានទេ បើគ្រាន់តែលើកហេតុផលថារវល់នៅក្នុងវិជ្ជាជីវៈ ។ ទី២ ស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យមើលលើឧបសគ្គនិងផលវិបាកផ្សេងៗដែលអាចកើតឡើងតាមរយៈការធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ។ ទី៣ គឺស្នើសុំឲ្យមានការជូនដំណឹងដល់ភាគីទាំងអស់បានដឹងអំពីការទាក់ទងទៅសាក្សី ឬអ្នកជំនាញ ដើម្បីជៀសវាងកុំឲ្យមានការទាក់ទងតែភាគីម្ខាង ហើយភាគីម្ខាងទៀតមិនបានដឹង ។

ឆ្លើយតបចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលថាការផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ គឺដើម្បីពន្លឿនដល់នីតិវិធីសវនាការ លោកមេធាវី សំអុន បានអះអាងថា វាអាចធ្វើបានតែក្នុងករណីមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទតែប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើនីតិវិធីដំណើរការទៅមុខលឿន ហើយធ្វើឲ្យប៉ះពាល់ដល់យុត្តិធម៌ដែលអាចកើតមានឡើងនោះ ដំណើរនីតិវិធីនឹងប្រព្រឹត្តទៅមុខ លឿនដោយឥតប្រយោជន៍ ។

បន្ទាប់ពីការដេញដោលចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ អង្គជំនុំជម្រះបានបន្តដេញដោលលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី អៀង សារី ទាក់ទងនឹងការស្នើឲ្យអ្នកជំនាញ ប៉ែន ឃៀរនិន ផ្ដល់ឯកសារបន្ថែម ។

## V. សំណើរបស់ អៀង សារី សុំឱ្យសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ផ្ដល់ឯកសារបន្ថែមមុនពេលចូលផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ

ដោយសារអ្នកជំនាញ សាស្ត្រាចារ្យ ប៉ែន ឃៀរនិន នឹងត្រូវផ្ដល់សក្ខីកម្មពេលខាងមុខ ក្រុមមេធាវី ការពារក្ដីឲ្យជនជាប់ចោទ អៀង សារី បានស្នើសុំឲ្យសាស្ត្រាចារ្យ ឃៀរនិន ផ្ដល់ឯកសាររបស់លោកបន្ថែមមកដល់ភាគីក្រុមមេធាវីការពារ មុនពេលលោកត្រូវចូលមកផ្ដល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះ ។ ប៉ុន្តែសហព្រះរាជអាជ្ញានិងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានជំទាស់ចំពោះសំណើនេះ ។

### ១) សំណើសុំរបស់ក្រុមមេធាវីការពារក្ដី អៀង សារី

លោកមេធាវី ខាណាវ៉ាស់ បានលើកឡើងថា ការស្នើសុំឲ្យសាស្ត្រាចារ្យ ប៉ែន ឃៀរនិនដាក់ឯកសារបន្ថែម គឺមិនបានប៉ះពាល់អ្វីដល់សាស្ត្រាចារ្យ ឃៀរនិន នោះទេ ។ ការស្នើសុំនេះ គឺដោយសារគាត់បានសរសេរសៀវភៅជាច្រើន ហើយគាត់ជាអ្នកជំនាញមួយរូប ដូច្នេះក្រុមមេធាវីការពារក្ដី អៀង សារី គ្រាន់តែចង់ស្នើសុំឲ្យសាស្ត្រាចារ្យ ឃៀរនិន ចែករំលែកអត្ថបទរបស់លោកមកអង្គជំនុំ

ជម្រះបន្ថែម ។ ម្យ៉ាងវិញទៀត ការលើកឡើងរបស់ក្រុមមេធាវីការពារក្តី គឺគ្រាន់តែជាសំណើសុំប៉ុណ្ណោះ មិនមែនជាការបង្ខំឲ្យសាស្ត្រាចារ្យ ឃៀរនិន ត្រូវតែផ្តល់ឯកសារទាំងនោះដល់អង្គជំនុំជម្រះទេ ។ ចំណែកឯសេចក្តីសម្រេចថាតើលោកគួរផ្តល់ឯកសារបន្ថែម ឬអត់នោះ គឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះគឺជាអ្នកសម្រេច ។ គួរកត់សម្គាល់ថា សំណើសុំជាលាយលក្ខណ៍អក្សររបស់ក្រុមមេធាវីការពារក្តី អៀង សារី បានដាក់ជូនទៅអង្គជំនុំជម្រះរួចហើយទាក់ទងនឹងបញ្ហានេះ ។

## ២) សហព្រះរាជអាជ្ញាជំទាស់ចំពោះសំណើសុំរបស់ក្រុមមេធាវី អៀង សារី

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ដេស្មាឯល



ដេស្មាឯល (រូបថត: អ.វ.ត.ក)

បានអះអាងថា ក្រុមមេធាវីការពារក្តី អៀង សារី បានស្នើសុំឲ្យសាស្ត្រាចារ្យ ឃៀរនិន ផ្តល់ឯកសារទាំងអស់ដែលទាក់ទងនឹងសំណុំរឿង០០២មកឲ្យខ្លួន ក្នុងនោះរួមមាន ឯកសារបោះពុម្ពផ្សាយចំនួន១០ កំណត់សម្គាល់សរសេរដោយដៃ ឬខ្សែអាត់សំឡេងជាដើម ។ លោកបានជំទាស់នឹងការស្នើសុំនេះ ដោយលើកឡើងថា ការស្នើសុំនេះគឺធ្វើឡើងដោយមិនត្រឹមត្រូវ និងថាមេធាវីការពារក្តីមិនបានបង្ហាញពីមូលហេតុជាក់លាក់ចំពោះសំណើសុំរបស់ខ្លួន ថាតើឯកសារដែលខ្លួនបានស្នើសុំនោះមានជាប់ពាក់ព័ន្ធនឹងគោលបំណងនៃសវនាការដែរឬយ៉ាងណានោះទេ ។ ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្តីធ្លាប់បានលើកឡើងថាឯកសារនៅក្នុងសំណុំរឿងមានចំនួនច្រើនហួសហេតុ ប៉ុន្តែពេលនេះក្រុមមេធាវីការពារក្តីបែរជាស្នើឲ្យមានការដាក់បន្ថែមឯកសារទៅវិញ ។ ហេតុនេះអង្គជំនុំជម្រះគួរតែបដិសេធសំណើសុំរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលមិនមានមូលដ្ឋានច្បាស់លាស់ ។

## ៣) សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ចំពោះសំណើសុំរបស់ក្រុមមេធាវី អៀង សារី

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹង លោកស្រី ស៊ីមូណូហ្គត បានធ្វើការជំទាស់ពាក់ព័ន្ធនឹងការស្នើសុំរបស់ក្រុមមេធាវីការពារក្តី អៀង សារី ឲ្យសាស្ត្រាចារ្យ បែន ឃៀរនិន បង្ហាញឯកសារសរសេរផ្សេងៗដាក់ជូនមបន្ថែមមកអង្គជំនុំជម្រះ ។ លោកស្រីមេធាវីបានអះអាងថា ការស្នើសុំរបស់ក្រុមមេធាវីការពារក្តី អៀង សារី គឺធ្វើឡើងដោយមិនមានមូលដ្ឋានជាក់លាក់ និងមិនអាចទទួលយកបាន ។ ហេតុនេះអង្គជំនុំជម្រះគួរតែបដិសេធសំណើទាំងអស់របស់ក្រុមមេធាវីការពារក្តី ។

## កំណត់សម្គាល់ផ្សេងៗ

នៅក្នុងសវនាការទាំងបួនថ្ងៃជនជាប់ចោទ អៀង សារី តែងតែស្នើសុំអង្គជំនុំជម្រះចាកចេញពីបន្ទប់សវនាការមកតាមដានកិច្ចដំណើរការនីតិវិធីនៅបន្ទប់រង់ចាំ បន្ទាប់ពីអង្គជំនុំជម្រះប្រកាសសម្រាកនៅម៉ោង១០និង៣០នាទីព្រឹក ដោយសារបញ្ហាសុខភាព ។ អង្គជំនុំជម្រះយល់ស្របសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី លើកលែងតែថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ ដែលជាសវនាការថ្ងៃដំបូង ដោយអង្គជំនុំជម្រះផ្តល់ហេតុផលថា អៀង សារី ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការដើម្បីស្តាប់ការចោទប្រកាន់ជាក់លាក់ប្រឆាំងនឹងរូបខ្លួនដែលអានចេញពីដីកាដំណោះស្រាយដោយក្រឡាបញ្ជី ។ ប៉ុន្តែនៅសវនាការថ្ងៃទីមួយនេះដដែល អង្គជំនុំជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី ទៅតាមដានដំណើរការនីតិវិធីសវនាការពីបន្ទប់រង់ចាំ បន្ទាប់ពីពេលសម្រាកពិសារអាហារថ្ងៃត្រង់ ។ រីឯជនជាប់ចោទ នួន ជា តែងតែស្នើសុំអង្គជំនុំជម្រះតាមដានដំណើរការនីតិវិធីនាពេលរសៀលពីបន្ទប់រង់ចាំ ។ មានតែជនជាប់ចោទ ខៀវ សំផន ម្នាក់គត់ដែលតាមដានកិច្ចដំណើរការនីតិវិធីពេញមួយថ្ងៃនៅក្នុងបន្ទប់សវនាការ ។

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ភូមិភាគ ៖ លំដាប់ខ្ពស់បំផុតនៃការគ្រប់គ្រងរដ្ឋបាលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

គណៈកម្មាធិការមជ្ឈិម ៖ អង្គការគ្រប់គ្រងអំណាចរបស់បក្សកុម្មុយនិស្តកម្ពុជា ។

កម្ទេច ៖ ពាក្យដែលប្រើប្រាស់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានន័យថាជាការសម្លាប់ឬការប្រហារជីវិតបុគ្គលណាមួយ ។


មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ dccam@online.com.kh

គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | ខៀវ ធីរិទ្ធ | អៀង ធីរិទ្ធ, ភា | (អត់ដឹង) | D427 |
| ៦ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

**ឈុនលី** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យវ័ត្ត**

**ជ័យវ័ត្ត** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យវ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ចាន់ ប្រាថ្នា**

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។



ខៀវ សំផន ក្នុងបន្ទប់សវនាការ ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមេសា ឆ្នាំ២០១២